# កម្ពុជា

KAMBUJA

លេខ២៣៦ ខែ តុលា ២០២២



ឯកឧត្តមអគ្គលេខាធិការអង្គការ សហប្រជាជាតិទទួល ស្វាគមន៍វត្តមានសម្តេចតេជោ ហ៊ុន សែន ក្នុងឱកាសដែលសម្តេច អញ្ជើញចូលរួមសម័យប្រជុំលើកទី៧៧ នៃកិច្ចពិភាក្សាទូទៅរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលរៀបចំធ្វើឡើងនៅទីក្រុងញូវយ៉ក ថ្ងៃទី២១-២៣ ខែកញ្ញា ឆ្នាំ២០២២

រូបថត : អនឃួន សំអូន ( TVK )

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

លេខ ១៣៧០ ព.ម

# សារលិខិតថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**បពិត្រព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង**

ក្នុងទិវាដ៏មហានក្ខត្តឫក្ស នៃព្រះរាជពិធីខួបលើកទី១៨ នៃការយាងគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ នៅថ្ងៃសៅរ៍ ៥កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២ ទូលព្រះបង្គំ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងព័ត៌មានទាំងមូល សូមព្រះបរមរាជានុញ្ញាត សម្តែងថ្វាយនូវមនោសញ្ចេតនាសាទរយ៉ាងក្លៀវក្លា និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះមហាករុណាទិគុណរបស់ព្រះករុណាថ្លៃវិសេស ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យគង់នៅជាម្លប់ដ៏សុខក្សេមក្សាន្ត និងដ៏ត្រជាក់ត្រជុំរបស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ។

ទូលព្រះបង្គំ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវស្វាមីភក្តិឥតងាករេ ដង្ហែតាមព្រះរាជកិច្ចដឹកនាំដ៏ភ្លឺស្វាងរបស់ព្រះករុណាថ្លៃវិសេស និងមានជំនឿយ៉ាងមុតមាំលើព្រះបញ្ញាញាណ ប្រកបដោយព្រះទសពិធរាជធម៌ និងព្រះសក្តានុពល យ៉ាងត្រចះត្រចង់ក្នុងព្រះរាជបេសកកម្មបម្រើជាតិមាតុភូមិអង្គរដ៏បវរនៃយើង។

**ព្រះករុណា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

នេះគឺជាមោទនភាពមួយដ៏ឧត្តុង្គឧត្តម សម្រាប់ទូលព្រះបង្គំ យើងខ្ញុំទាំងអស់គ្នា ក៏ដូចជាប្រជារាស្ត្រកម្ពុជាទាំងមូល ដែលមានព្រះអគ្គមគ្គុទ្ទេសក៏ដ៏ប្រសើរថ្លៃថ្លាមួយព្រះអង្គ ប្រកបដោយព្រះបញ្ញាញាណឈ្លាសវៃ និងស្នេហាស្មោះស្ម័គ្រ ចំពោះជាតិមាតុភូមិ យកព្រះទ័យទុកដាក់បម្រើប្រជានុរាស្ត្ររបស់ព្រះអង្គ គ្រប់ទិសទី គ្រប់កាលៈទេសៈ។

ឆ្លៀតឱកាសដ៏មហោឡារិកនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី និងព្រះមហាវីរក្សត្រ ព្រះវររាជបិតា ព្រះបរមរតនកោដ្ឋ សូមប្រសិទ្ធពរជ័យបវរមហាប្រសើរ ថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមព្រះអង្គប្រកបដោយព្រះរាជសុខភាពពេញបរិបូរ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ដើម្បីព្រះអង្គគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ត្រជុំរបស់ប្រជារាស្ត្រជាយូរអង្វែងតរៀងទៅ។

សេចក្តីគួរពុំគួរ សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ទ្រង់ព្រះមេត្តាប្រោស

សូមក្រាបបង្គំទូលថ្វាយនៅថ្ងៃចន្ទ ១៤ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

Building62, Monivong BLVD,Sangkat Srah Chork, Khan Daun Penh, PhnomPenh E-mail:information@info.gov.kh

# កម្ពុជា

លេខ ២៣៦
ខែតុលា ២០២២

KAMBUJA


## មាតិកា


- ព្រះមហាក្សត្រ និងសម្តេចម៉ែ ប្រារព្ធព្រះរាជពិធីឧទ្ទិសព្រះមហាកុសលគម្រប់ខួប១០ព្រះវស្សា ថ្វាយដួងព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ ........ ៣
- សម្តេចព្រះមហាសុមេធាធិបតីកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត ទទួលបានពានរង្វាន់ " សៅសេមាធម្មចក្រ " ពីព្រះអង្គម្ចាស់ក្សត្រីយ៍ មហាចក្រី សិរិន ថន នៃព្រះរាជាណាចក្រថៃ ........ ៩
- សម្តេចតេជោ ហ៊ុន សែន ណែនាំមន្ត្រីកសិកម្មនិងអាជ្ញាធរដែនដីត្រូវនៅជាប់ជាមួយប្រជាជនដោះស្រាយនូវបញ្ហារបស់ពួកគាត់ដែលរងគ្រោះដោយទឹកជំនន់ ........ ១២
- សម្តេចតេជោ ហ៊ុន សែន ជំរុញឱ្យជួយអន្តរាគមន៍បន្ទាន់ចំពោះប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ ប្រមាណ ២ម៉ឺនគ្រួសារ ........ ១៤
- សេចក្តីប្រកាសព័ត៌មាន ស្តីពីលទ្ធផលដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ប្រធានាធិបតីទីម័រខាងកើត នៅកម្ពុជា ........ ១៨
- តបតាមការអញ្ជើញរបស់ ព្រះមហាក្សត្រកម្ពុជា ប្រធានាធិបតី នៃប្រទេសទីម័រខាងកើត ឯកឧត្តម ចូហ្សេ ម៉ានុយអែល រ៉ាមូស (JOSÉ MANUEL RAMOS-HORTA ) បានធ្វើទស្សនកិច្ចជាផ្លូវរដ្ឋនៅប្រទេសកម្ពុជា  កាលពីថ្ងៃទី១៩  ដល់ ថ្ងៃទី២១ ខែតុលា  ឆ្នាំ២០២២ ........ ២០
- នាយករដ្ឋមន្ត្រីគុយបា សន្យាប្រឹងប្រែងពង្រឹងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ឱ្យកាន់តែរឹងមាំថែមទៀត ........ ២១
- រដ្ឋសភាបើកសម័យប្រជុំលើកទី៨ នីតិកាលទី៦ ........ ២៥
- ទំហំពាណិជ្ជកម្ម កម្ពុជា-វៀតណាម រំពឹងថា កើនដល់ ១២ពាន់លានដុល្លារ នៅឆ្នាំ២០២២ ........ ២៧
- កម្ពុជាកំពុងព្យាយាមចូលរួមជាមួយអង្គការសហប្រជាជាតិគាំទ្រសន្តិភាព និងសន្តិសុខអន្តរជាតិ លើកកម្ពស់លើគោលការណ៍ គុណតម្លៃជាមូលដ្ឋាននៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ ........ ៣២
- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ផ្តើមធ្វើបុណ្យកឋិនទានដង្ហែចូលវត្តព្រះឥន្ទកោសីយ៍ ឃុំស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ........ ៤១
- ក្រសួងព័ត៌មានរាយការណ៍ពីដំណើរការវិវឌ្ឍនៃវិស័យព័ត៌មាន និងសោតទស្សន៍នៅកម្ពុជា ជូនគណៈកម្មការទី៥ នៃព្រឹទ្ធសភា ........ ៤៥
- ពិធីចុះហត្ថលេខាកិច្ចសហប្រតិបត្តិការ ផ្លាស់ប្តូរ ព័ត៌មាន រវាងទីភ្នាក់ងារ សារព័ត៌មានកម្ពុជា និងទីភ្នាក់ងារសារព័ត៌មានគុយបា ........ ៥០
- ឯកឧត្តមរដ្ឋមន្ត្រី ខៀវ កាញារីទ្ធ ប្រគល់រថយន្ត ៣គ្រឿងដល់អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP និងអគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ........ ៥៣
- គម្រោងសាងសង់ប្រព័ន្ធស្រោចស្រព និងការពារទឹកជំនន់ស្ទឹងព្រែកត្នោត បានសម្រេចការសាងសង់ប្រមាណ

៧០ភាគរយ ........................................................ ៥៧
- ឯកឧត្តមឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត ជួបសម្ដែងការគួរសមជាមួយប្រធានាធិបតីទីម័រខាងកើត .............. ៦០
- ឯកឧត្តម ថោង ខុន ទទួលគ្រឿងឥស្សរិយយស «ខ្សែកមាស» ពីក្រុមប្រឹក្សាអូឡាំពិកអាស៊ី(OCA) ................ ៦៣
- ឯកអគ្គរដ្ឋទូតជប៉ុន៖ ទឹកផឹកសុវត្ថិភាពធានាបាននូវគុណភាពជីវិត ........................................ ៦៥
- ធនាគារពិភពលោកព្យាករកំណើនសេដ្ឋកិច្ចកម្ពុជាមាន៤,៨% ក្នុងឆ្នាំ២០២២ ........................................ ៦៧
- សមាគម TYDA ចុះពិនិត្យព្យាបាលជំងឺទូទៅ និងជំងឺមាត់ធ្មេញ ជូនប្រជាជនក្នុងតំបន់ទួលសំបូរ សង្កាត់ព្រៃវែង ខណ្ឌដង្កោ ........................................ ៦៩
- ឯកឧត្តម ណុប ចាន់ណារិទ្ធ៖ ភាពរឹងមាំនៃការងាររីកចម្រើនមិនអាចឃ្លាតចេញពីការធ្វើអធិការកិច្ចនោះបានឡើយ ........................................ ៧២
- កីឡាវ៉ូវីណាមកម្ពុជាប្ដេជ្ញាឆ្លោះដណ្ដើមមេដាយមាស ៩គ្រឿង ក្នុងឋានៈជាម្ចាស់ផ្ទះ ស៊ីហ្គេម ២០២៣ ............ ៧៤
- សភាពាណិជ្ជកម្មខេត្តព្រះសីហនុផ្សព្វផ្សាយពីកាតព្វកិច្ចគណនេយ្យ សវនកម្មនិងបទបញ្ញត្តិពាក់ព័ន្ធ .............. ៧៩
- ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ បាននិងកំពុងជំរុញការអនុវត្តគម្រោងសាងសង់ស្ថិតនៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល ........................................ ៨១
- ប្រទះឃើញបំណែកចម្លាក់ក្បាលនាគមួយផ្ទាំងមានរចនាប័ទ្មបាយ័ន រលើងចេញតាមឫសដើមស្រឡៅដែលបានរលំ ........................................ ៨៣
- គិតចាប់ពីខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ រថយន្តគ្មានពន្ធចំនួន ១៥ ៩៥០គ្រឿង ត្រូវបានម្ចាស់យកមកបង់ពន្ធ ........................................ ៨៦
- គណៈប្រតិភូជាតិ និងអន្តរជាតិអញ្ជើញទស្សនាប្រាសាទកោះកេរនិងរូបតំណាងព្រះស្កន្ទកុមារ ....................... ៨៩
- ឯកឧត្តម ឆាយ ឫទ្ធិសែន អបអរសាទរសម្ដេចតេជោទទួលបានយុត្តិធម៌ពីតុលាការបារាំង ............................. ៩២
- បញ្ជីរាយនាមសប្បុរសជនចូលរួមបច្ច័យកាន់បិណ្ឌទី១១ ពិធីបុណ្យភ្ជុំបិណ្ឌនៅវត្តមង្គលវ័ន ហៅស្វាយបង្គំ ........... ៩៣
- ពិធីបុណ្យសពព្រឹទ្ធមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៍ ទន់ ធី មាតាក្មេក ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី ........................................ ៩៤

ចេញផ្សាយដោយ
អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP
បោះពុម្ពដោយ រោងពុម្ពក្រសួងព័ត៌មាន
ទូរស័ព្ទ : ០១២ ៨២៨ ៤០៥
E-mail : Sath.Sophal@gmail.com

# ព្រះមហាក្សត្រ និងសម្តេចម៉ែ ប្រារព្ធព្រះរាជពិធីឧទ្ទិស ព្រះមហាកុសលគម្រប់ខួប១០ព្រះវស្សា ថ្វាយដួងព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ

អត្ថបទ៖ ស៊ីម មង្គល , រូបថត៖ ព្រះបរមរាជវាំង,សាម៉ាន



ព្រះរាជពិធីឧទ្ទិសព្រះមហាកុសលគម្រប់ខួប១០ព្រះវស្សាថ្វាយដួងព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២ ជាខួបគម្រប់ ១០ព្រះវស្សា នៃការយាងសោយទិវង្គតរបស់ព្រះករុណា ព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** អតីតព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។ នៅឯព្រះបរមរាជវាំង ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **មុនិនាថ នរោត្តម សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត រួមទាំងថ្នាក់ដឹកនាំជាតិសំខាន់ៗ បានប្រារព្ធព្រះរាជពិធី ឧទ្ទិសព្រះមហាកុសលគម្រប់ខួប១០ព្រះវស្សា ថ្វាយដួងព្រះវិញ្ញាណក្ខន្ធ **ព្រះបរមរតនកោដ្ឋ** ដោយមានការអញ្ជើញចូលរួមសម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា,សម្តេចវិបុល









*ថ្នាក់ដឹកនាំជាតិសំខាន់ៗ អញ្ជើញចូលរួមប្រារព្ធ ព្រះរាជពិធី ឧទ្ទិសព្រះមហាកុសល គម្រប់ខួប១០ព្រះវស្សា ថ្វាយដួងព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ*

សេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា,សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងថ្នាក់ដឹកនាំ ជាឥស្សរជនជាន់ខ្ពស់មួយចំនួនទៀត។ ចំណែកសហភាពសហព័ន្ធយុវជនកម្ពុជាក៏បានរៀបចំកម្មវិធីសមាធិរលឹកដួងវិញ្ញាណក្ខន្ធ ព្រះករុណា **ព្រះបរមរតនកោដ្ឋ** នៅសាលាធម្មសភា ក្នុងវត្តបរទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ យាងនិងអញ្ជើញចូលរួមក្នុងកម្មវិធីសមាធិរលឹកដួងវិញ្ញាណក្ខន្ធព្រះករុណា **ព្រះបរមរតនកោដ្ឋ** មានសម្ដេចរាជបុត្រី ព្រះអានុច **នរោត្ដម អរុណរស្មី** ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ឯកឧត្ដម **ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា មន្ត្រីអ្នកមុខអ្នកការសំខាន់ៗ និងពុទ្ធបរិស័ទ្ធជាច្រើនរូបចូលរួម និងមន្ត្រីតាមបណ្ដាក្រសួងស្ថាប័ននានា ក៏បានអញ្ជើញគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះបរមរតនកោដ្ឋ** នាបរិវេណមណ្ឌបសួនច្បារខាងកើតវិមានឯករាជ្យផងដែរ។

នៅថ្ងៃទី១៥ ខែតុលា កាលពី១០ឆ្នាំមុន គឺជាពេលវេលាដ៏សែនសោកសៅ និងសោកសង្រេងបំផុត សម្រាប់ជាតិខ្មែរទាំងមូល ជាពេលវេលា ដែលបានបាត់បង់ នូវព្រះមហាវីរក្សត្រដ៏ឆ្នើមមួយអង្គ គឺសម្ដេច **ព្រះបរមរតនកោដ្ឋ នរោត្ដម សីហនុ**។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបនៅតែចងចាំជាប់មិនអាចបំភ្លេចនូវស្នាព្រះហស្ត **ព្រះបរមរតនកោដ្ឋ** គឺព្រះអង្គយាងបំពេញព្រះរាជបូជនីយកិច្ច យ៉ាងអង់អាចក្លាហាន ក្នុងការទាមទារ





*ព្រះរាជពិធីឧទ្ទិសព្រះមហាកុសលគម្រប់ខួប១០ព្រះវស្សាថ្វាយដួងព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ*

និងដណ្ដើមសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋខ្មែរ តាមរយៈស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ព្រះករុណា ព្រះមហាវីរក្សត្រ **ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតក្នុងមួយព្រះជន្មរបស់ ព្រះអង្គបានគិតគូរពីឧត្តមប្រយោជន៍ជាតិលើសអ្វីទាំងអស់ ព្រះអង្គបានបំពេញព្រះរាជបូជនីយកិច្ចទាមទារបានមកវិញនូវឯករាជ្យ និងបូរណភាពទឹកដីខ្មែរឱ្យបានគង់វង្ស។ ព្រះរាជតម្រិះភ្លឺស្វាងបំផុតរបស់ព្រះអង្គក្នុងព្រះរាជកិច្ចផ្សះផ្សា





*ថ្នាក់ដឹកនាំជាតិសំខាន់ៗ អញ្ជើញចូលរួមប្រារព្ធ ព្រះរាជពិធី ឧទ្ទិសព្រះមហាកុសល គម្រប់ខួប១០ព្រះវស្សា ថ្វាយដួងព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ*



*សហភាពសហព័ន្ធយុវជនកម្ពុជារៀបចំកម្មវិធីសមាធិរំលឹកដួងវិញ្ញាណក្ខន្ធព្រះករុណា ព្រះបរមរតនកោដ្ឋ*





*សហភាពសហព័ន្ធយុវជនកម្ពុជាចូលរួមសមាធិរំលឹកដួងវិញ្ញាណក្ខន្ធព្រះករុណា ព្រះបរមរតនកោដ្ឋ*



ឯកភាពជាតិ និងព្រះរាជកិច្ចស្ថាបនាព្រះរាជសមិទ្ធផលកសាងជាតិ ឱ្យមានភាពរីកចម្រើនតាំងពីសម័យសង្គមរាស្ត្រនិយមរុងរឿងរហូតដល់សម័យបច្ចុប្បន្ន។ ក្រោយការទាមទារឯករាជ្យពីបារាំងបានជោគជ័យហើយនោះ ការបំពេញព្រះរាជកិច្ចដឹកនាំប្រទេសក្នុងសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) បានធ្វើឱ្យប្រជាពលរដ្ឋខ្មែរស្ញប់ស្ញែង និងចងចាំមិនអាចបំភ្លេចបានឡើយចំពោះភាពរីកចម្រើន និងលេចធ្លោរបស់ជាតិកម្ពុជា។ ក្រោមការដឹកនាំរបស់ព្រះមហាវីរក្សត្រព្រះបាទ **នរោត្តម សីហនុ** ជាព្រះប្រមុខរដ្ឋរបបសង្គមរាស្ត្រនិយម កម្ពុជាត្រូវបានគេចាត់ទុកថាជា«គុជអាស៊ី» ដោយសារមានការរីកចម្រើនលើគ្រប់វិស័យ និងនាំមកនូវឧត្តមប្រយោជន៍សម្រាប់ប្រជារាស្ត្ររបស់









ព្រះអង្គ។ គំរូវីរភាពដ៏អង់អាចក្លាហានក្នុងការទាមទារឯករាជ្យពីបារាំង និងស្នាព្រះហស្តដឹកនាំកសាងសង្គមកម្ពុជា ក្នុងសម័យសង្គមរាស្ត្រនិយម ល្បីរន្ទឺនៅអាស៊ីនោះហើយជាការសាងនូវភាពល្បីល្បាញ និងអន្ទងដួងចិត្ត និងបេះដូងរាស្ត្រខ្មែរនៅតែនឹករឭក និងចងចាំគ្មានថ្ងៃបំភ្លេច ដូចពាក្យសុភាសិតខ្មែរមួយឃ្លាបានពោលថា «ទូកទៅ កំពង់នៅ»។ បើទោះបីព្រះកាយរបស់ព្រះអង្គបានរសាត់បាត់ពីភពផែនដី តែព្រះកិត្តិនាមរបស់ព្រះអង្គនៅតែបន្តក្រអូបឈ្ងុញឈ្ងប់ក្រាលគ្របលើផែនពសុធានៃរដ្ឋកម្ពុជា។

ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** អតីតព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គប្រសូត្រនៅថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំចចត្វាស័ក ព.ស.២៤៦៥ ត្រូវនឹង



*ថ្នាក់ដឹកនាំជាតិសំខាន់ៗ តាមក្រសួងស្ថាប័ននានា អញ្ជើញគោរពព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ*

ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។ ព្រះអង្គបានយាងចូលព្រះទិវង្គតនៅថ្ងៃចន្ទ ១៥រោច ខែភទ្របទ ឆ្នាំរោង ចត្វាស័កព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ ក្នុងជន្មាយុ៩០ព្រះវស្សានៅរដ្ឋធានីប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន វេលាម៉ោង១:២០នាទីយប់ ដោយព្រះជរាពាធ។ ព្រះសពរបស់អតីតព្រះមហាក្សត្រត្រូវបានដឹកតាមជើងយន្តហោះពិសេសពីប្រទេសចិនមកកម្ពុជា នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ នៅវេលាម៉ោង៣រសៀល។ ដើម្បីតបស្នងព្រះមហាករុណា ទិគុណ និងព្រហ្មវិហារធម៌ដ៏ថ្លៃថ្លាឧត្តុង្គឧត្តម វិសេសវិសាលរបស់ព្រះអង្គ ដែលបានលះបង់ព្រះកាយពល ព្រះបញ្ញាញាណរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាបានយកថ្ងៃទី១៥ខែតុលា ជាថ្ងៃបុណ្យជាតិ និងជាថ្ងៃកាន់មរណទុក្ខរបស់ប្រជាពលរដ្ឋខ្មែរទាំងមូល។ នៅថ្ងៃទី១៥តុលាទៀតសោត ទាំងព្រះរាជវង្សានុវង្ស ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ គ្រប់ក្រសួងស្ថាប័ន និងប្រជារាស្ត្រទូទាំងប្រទេសតែងតែប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា **ព្រះបរមរតនកោដ្ឋ**។

សហភាពសហព័ន្ធយុវជនកម្ពុជា បានរៀបចំកម្មវិធីសមាធិរំលឹកដួងវិញ្ញាណក្ខន្ធព្រះករុណា **ព្រះបរមរតនកោដ្ឋ** នៅសាលាធម្មសភា វត្តបុទុមវត្តី ដែលមានការយាង និងនិមន្តព្រះសង្ឃ និងអញ្ជើញពុទ្ធបរិស័ទចូលរួមចំនួន៥០០អង្គនាក់ មានសម្តេចសង្ឃ និងព្រះសង្ឃចំនួន ១០០អង្គ ក្នុងនោះមានគណៈធម្មយុត្តិកនិកាចំនួន ៥០អង្គ និងគណៈមហានិកាយចំនួន ៥០អង្គ។ បន្ថែមពីនេះទៀតតាជី និងយាយជី ចំនួន ១០០នាក់ គណៈកម្មាធិការអចិន្ត្រៃយ៍ សហភាពសហព័ន្ធយុវជនកម្ពុជា និងយុវជនសហភាពសហព័ន្ធយុវជនកម្ពុជា តាមវិស័យចំនួន ២០០នាក់ ព្រមទាំងពុទ្ធបរិស័ទចំនួន ១៥០នាក់។ កម្មវិធីសមាធិរលឹកដួងវិញ្ញាណក្ខន្ធ ព្រះករុណា **ព្រះបរមរតនកោដ្ឋ** ត្រូវបានរៀបចំឡើងក្នុងគោលបំណង ទី១៖ ចូលរួមរលឹកគម្រប់ខួប១០ព្រះវស្សា នៃការយាងសោយព្រះទិវង្គតរបស់ព្រះករុណាមហាវីរក្សត្រ **ព្រះបរមរតនកោដ្ឋ** ។ ទី២៖ បង្ហាញពីទឹកចិត្ត និងស្មារតី នៃការចងចាំចំពោះព្រះរាជបណ្តាំដ៏ថ្លៃថ្លា និងពោពេញដោយអត្ថន័យទូន្មាន ដែលបានឆ្លាក់លើផ្ទាំងសិលា ដែលជាព្រះរាជអង្គការរបស់ព្រះករុណាមហាវីរក្សត្រ **ព្រះបរមរតនកោដ្ឋ** បានឆ្លាក់លើផ្ទាំងសិលានៅសួនច្បារព្រះរាជបណ្តាំ និង ទី៣៖ រំលឹកពីគុំរូវីរភាព និងការសម្តែងនូវមនោសញ្ចេតនា កតញ្ញូកតវេទី ប្រកបដោយការគោរពដ៏ខ្ពស់ខ្ពស់ ថ្វាយព្រះមហាករុណាទិគុណ ដ៏ប្រសើរថ្លៃថ្លា ប្រកបដោយសេចក្តី នឹករលឹក សោកស្តាយរកអ្វីប្រៀបផ្ទឹមពុំបាន និងសេចក្តីអំណរព្រះរាជគុណជាអនេកគ្មានថ្ងៃបំភ្លេចបាន៕



*ថ្នាក់ដឹកនាំជាតិសំខាន់ៗ តាមក្រសួងស្ថាប័ននានា អញ្ជើញគោរពព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ*

# សម្តេចព្រះមហាសុមេធាធិបតីកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត ទទួលបានពានរង្វាន់ "សៅសេមាធម្មចក្រ" ពីព្រះអង្គម្ចាស់ក្សត្រីយ៍មហាចក្រី សិរិន ថន នៃព្រះរាជាណាចក្រថៃ

*អត្ថបទ ៖ សៅ សុវណ្ណ , រូបថត ៖ ក្រសួងធម្មការ និងសាសនា*



ឯកឧត្តម ប៉ាន់យ៉ារាក់ ភូនសាប់ ឯកអគ្គរដ្ឋទូតថៃប្រចាំកម្ពុជា ថ្វាយប្រកាសនីយប័ត្រពានរង្វាន់ " សៅសេមាធម្មចក្រ " ដល់ សម្តេចកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត

សម្តេចព្រះមហាសុមេធាធិបតីកិត្តិឧទ្ទេសបណ្ឌិត **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា ជាវីរៈសង្ឃមួយព្រះអង្គ ដែលបានលះបង់កម្លាំងកាយចិត្ត និងបញ្ញាញាណក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនាកម្ពុជាចេញពីបាតដៃទទេ រហូតមានភាពល្បីល្បាញពាសពេញតំបន់និងសកលលោក ត្រូវបានព្រះអង្គម្ចាស់ក្សត្រីយ៍មហាចក្រី **សិរិន ថន** នៃព្រះរាជាណាចក្រថៃឡង់ដ៍ ថ្វាយពានរង្វាន់ "**សៅសេមាធម្មចក្រ**" ប្រគេនដល់សម្តេចព្រះមហាសុមេធាធិបតី កិត្តិឧទ្ទេសបណ្ឌិត **នន្ទ ង៉ែត** កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ ដែលពិធីប្រគល់ថ្វាយ និងទទួលត្រូវបានប្រារព្ធធ្វើនៅក្នុងស្ថានទូតថៃប្រចាំព្រះរាជាណាចក្រកម្ពុជា ក្រោមវត្តមានពីសំណាក់ ឯកឧត្តម **ឈិត សុខុន** រដ្ឋមន្ត្រីក្រសួងធម្មការ



ទីតាំងកន្លែងប្រារព្ធពិធីថ្វាយប្រគេនពានរង្វាន់" សៅសេមាធម្មចក្រ " ដល់ សម្តេចកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត ស្ថិតនៅក្នុងបរិវេណស្ថានទូតថៃ ប្រចាំកម្ពុជា





ថ្នាក់ដឹកនាំ និងភ្ញៀវកិត្តិយសអញ្ជើញចូលរួម



និងសាសនាឯកឧត្តម **ប៉ាន់យ៉ារាក់ ត្ងនសាប់** ឯកអគ្គរដ្ឋទូតថៃប្រចាំកម្ពុជា ជាព្រះរាជតំណាង និងមានការយាងនិមន្តអញ្ជើញចូលរួមពីសម្តេចព្រះសង្ឃនាយក សម្តេចព្រះសង្ឃនាយករង សម្តេចព្រះរាជាគណៈ ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ និងថ្នាក់ដឹកនាំជាច្រើនរូបទៀត ។

ថ្លែងក្នុងឱកាសនោះ ឯកឧត្តម **ឈិត សុខុន** រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា បានសម្តែងនូវការអបអរសាទរនិងអនុមោទនាចំពោះការ ទទួលបាននូវពានរង្វាន់ដ៏ឧត្តុង្គឧត្តម



ឯកឧត្តម ឈុត សុខុន ថ្វាយកន្ត្រកផ្កាដល់សម្តេចកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត



ឯកឧត្តម ឯកអគ្គរដ្ឋទូតថៃ ថ្វាយកន្ត្រកផ្កាដល់សម្តេចកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត

នេះ របស់សម្តេចព្រះមហាសុមេធាធិបតីជាអង្គម្ចាស់ ហើយក៏បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅជាមួយនឹងការកោតសរសើរ និងវាយតម្លៃខ្ពស់ ព្រមទាំងការគាំទ្រយ៉ាងមុតមាំ ចំពោះការសម្រេចចិត្តរបស់ព្រះអង្គម្ចាស់ក្សត្រីយ៍មហាចក្រី **សិរិន ធន** នៃព្រះរាជាណាចក្រថៃ ក្នុងការថ្វាយពានរង្វាន់ដ៏ខ្ពស់បំផុតនេះ ដែលជា មហាកិត្តិយសដ៏ធំធេងក្រៃលែង ។ឯកឧត្តមរដ្ឋមន្ត្រី ក៏បានមានប្រសាសន៍បន្តទៀតថា ដើម្បីអភិរក្សនិងការពារព្រះពុទ្ធសាសនាឱ្យបានស្ថិតស្ថេរយូរអង្វែងនៅក្នុងប្រទេសទាំងពីរ កម្ពុជា-ថៃ និងនៅលើពិភពលោកចាំបាច់យើងត្រូវរួមគ្នា ធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងមិត្តភាព សាមគ្គីភាព ជំហររឹងមាំសំដៅរក្សាឱ្យបាននូវតម្លៃព្រះពុទ្ធសាសនា និងរិះរកគ្រប់មធ្យោបាយផ្សព្វផ្សាយព្រះបរមពុទ្ធោវាទឱ្យបានទូលំទូលាយដល់ពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន ។

សូមបញ្ជាក់ថា ការទទួលពានរង្វាន់ដ៏មហាអស្ចារ្យនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ គឺកើតចេញពីការលះបង់ព្រះកាយពល ព្រះបញ្ញាញាណ ក្នុងមួយជីវិតរបស់សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** ជាអង្គម្ចាស់ក្នុងបុព្វហេតុសង្គមជាតិ និងព្រះពុទ្ធសាសនាដែលជាព្រះធម្មវិន័យ ដ៏មានគុណតម្លៃដល់មនុស្សលោកយកមកប្រណិបតន៍តាមគន្លងមាគ៌ា រហូតកើតភាពត្រជាក់ត្រជុំរស់នៅប្រកបដោយភាពសុខដុមរមនា៕



សម្តេចកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត ផ្តល់កិត្តិយសថតរូបអនុស្សាវរីយ៍ ដល់ឯកឧត្តម ឈិត សុខុន និងឯកឧត្តម ប៉ាន់យ៉ារាក់ ភូនសាប់ ឯកអគ្គរដ្ឋទូតថៃប្រចាំកម្ពុជា

# សម្តេចតេជោ ហ៊ុន សែន ណែនាំមន្ត្រីកសិកម្ម និងអាជ្ញាធរដែនដី ត្រូវនៅជាប់ជាមួយប្រជាជន ដោះស្រាយនូវបញ្ហា របស់ពួកគាត់ដែលរងគ្រោះដោយទឹកជំនន់

*អត្ថបទ៖ កែ ផុស , រូបថត៖ អង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស*




*ទិដ្ឋភាពរួមនៃពិធីផ្តល់សញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង*

សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានថ្លែងផ្តាំទៅមន្ត្រីកសិកម្មទាំងអស់រួមទាំងអាជ្ញាធរដែនដី មិនត្រូវអនុវត្តន៍សកម្មភាពការងាររបស់ខ្លួនបែប «ជិះសេះមើលផ្កា» នោះទេ គឺត្រូវនៅឱ្យជាប់កៀកកិតជាមួយប្រជាជន ដោះស្រាយភ្លាមៗនូវបញ្ហារបស់ពួកគាត់។ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក៏បានជំរុញឱ្យយន្តការដែលពាក់ព័ន្ធ ចុះជួយអន្តរាគមន៍បន្ទាន់ដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយមហន្តរាយទឹកជំនន់ ប្រមាណ២ម៉ឺនគ្រួសារ ដែលស្ថិតនៅ ២១ ខេត្ត រាជធានីនោះ។

សម្តេចតេជោ **ហ៊ុន សែន** បានផ្តាំផ្ញើបែបនេះ ពាក់ព័ន្ធទៅនឹងសកម្មភាពការងារវាយតម្លៃផលប៉ះពាល់ដោយទឹកជំនន់មកលើប្រជាកសិករ និងការចែកគ្រាប់ពូជ ជូនដល់ប្រជាពលរដ្ឋ ព្រមទាំងសកម្មភាពការងារផ្សេងៗទៀត របស់មន្ត្រីកសិកម្ម និងអាជ្ញាធរដែនដី នៅពេលដែលពលរដ្ឋជួយបញ្ហា ដែលការថ្លែងរបស់សម្តេចតេជោ ធ្វើឡើងក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធី ប្រគល់សញ្ញាបត្រជូននិស្សិត សាកលវិទ្យាល័យជាតិគ្រប់គ្រងជាង ៦ពាន់នាក់ កាលពីព្រឹកថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២២។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានថ្លែងបញ្ជាក់ថា ការវាយតម្លៃផលប៉ះពាល់ត្រូវធ្វើបន្ទាន់ នៅពេលវាយតម្លៃរួច ត្រូវដឹកជញ្ជូនគ្រាប់ពូជជូនប្រជាពលរដ្ឋភ្លាមៗ ហើយកន្លែងណាអាចធ្វើស្រូវបានឱ្យពួកគាត់ធ្វើស្រូវ ចំពោះកន្លែងណាដែលមិនអាចធ្វើស្រូវបាន ត្រូវផ្តល់គ្រាប់ពូជដំណាំរួមផ្សំជូនពួកគាត់។

សម្តេចតេជោ **ហ៊ុន សែន** បានគូសបញ្ជាក់ថារាជរដ្ឋាភិបាលកម្ពុជា មានស្តុកនូវគ្រាប់ពូជយុទ្ធសាស្ត្រ ដើម្បីការពារនូវហានិភ័យនានា ដែលអាចកើតឡើង សម្រាប់ការបង្កបង្កើនផល




*សម្តេចតេជោ ហ៊ុន សែន*

របស់បងប្អូនប្រជាពលរដ្ឋ មិនជួបបញ្ហាខ្វះខាតពូជនោះទេ។

សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា «អ្វីដែលខ្ញុំចង់បញ្ជាក់បន្ថែមនៅទីនេះ ហើយក៏បានដាក់វិធានការរួចមកហើយ គឺការវាយតម្លៃបន្ទាន់ អត់មានរង់ចាំវាយតម្លៃរួចបានផ្គត់ផ្គង់ទេ ដើម្បីឱ្យទាន់ពេលវេលានៃការបង្កបង្កើនផលរបស់ប្រជាជន កន្លែងណាវាយតម្លៃរួច ដឹកស្រូវពូជ ឬពូជដំណាំដទៃទៀត ទៅដល់ចែកជូនប្រជាជនតែម្តង ដោយអត់ត្រូវរង់ចាំទេ យើងមានពូជមានស្តុកយុទ្ធសាស្ត្រ កន្លែងខ្លះយើងអាចធ្វើស្រូវឡើងវិញ កន្លែងខ្លះអាចត្រូវប្រើពូជដំណាំផ្សេង យើងត្រូវផ្គត់ផ្គង់ពូជនោះ ដើម្បីពួកគាត់អាចមានលទ្ធភាព ដើម្បីស្តារឡើងវិញ»។

សម្តេចតេជោ **ហ៊ុន សែន** បញ្ជាក់ទៀតថា «អាជ្ញាធរខេត្តដែលជាប់ពាក់ព័ន្ធ ត្រូវនៅកៀកកិតជាមួយប្រជាជន យន្តការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែធ្វើសកម្មភាពនេះឱ្យបានលឿន ជាមួយគណៈកម្មការគោលនយោបាយសេដ្ឋកិច្ច ដែលក្នុងនោះមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ដើម្បីធ្វើការវាយតម្លៃអំពីការខូចខាត ហើយផ្គត់ផ្គង់ពូជភ្លាមសម្រាប់ប្រជាជន... ហើយសុំ ផ្តាំទៅមន្ត្រី កសិកម្ម ទាំងអស់ ក៏ដូចជាអាជ្ញាធរដែនដី មិនមែនជិះសេះមើលផ្កាទេ ត្រូវនៅឱ្យជាប់ជាមួយប្រជាពលរដ្ឋ វាយតម្លៃឱ្យត្រូវ ហើយនៅកៀកកិតជាមួយគាត់ ជូនកាលពូជដាក់ទៅវាមិនដុះ បើមិនដុះត្រូវដោះស្រាយបន្តទៀត អីចឹងបានកាលៈទេសៈនេះ ទាមទារឱ្យផ្នែកកសិកម្មយកចិត្តទុកដាក់ធ្វើអន្តរាគមន៍បន្ទាន់ អត់មានពេលត្រូវរង់ចាំនេះ រង់ចាំនោះ ធ្វើផង មិនធ្វើផង អត់ទេ»។

សម្តេចតេជោបានថ្លែងទៀតថា រយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ក្នុងតួនាទីជារដ្ឋមន្ត្រីស្តីទីក្រសួងកសិកម្ម បានរាយការណ៍ជូនសម្តេចនូវការវាយតម្លៃផលប៉ះពាល់ និងការចុះចែកគ្រាប់ពូជជូនប្រជាពលរដ្ឋជាប្រចាំ ខណៈដែលការផ្ទេរតំណែងរដ្ឋមន្ត្រីថ្មី ក្រសួងកសិកម្មធ្វើឡើងកាលពីរសៀលថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២នោះដែរ។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានឆ្លៀតក្នុងឱកាសនោះថ្លែងអំណរគុណដល់សប្បុរសជននានា រួមទាំងកាកបាទក្រហមកម្ពុជាផងដែរ ដែលបានចែកជូនជាជំនួយស្បៀងអាហារ ដល់បងប្អូនដែលមានផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់ ជាការជួយសម្រាល ដល់ការលំបាកមួយផ្នែករបស់បងប្អូនប្រជាពលរដ្ឋ។



*និស្សិតចូលរួមក្នុងពិធីចែកសញ្ញាបត្រ*

ជាមួយគ្នានេះ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានអំពាវនាវចំពោះធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផ្តល់នូវការអនុគ្រោះ សម្រាប់អ្នកដែលរងគ្រោះ និងទទួលផលប៉ះពាល់ពីគ្រោះមហន្តរាយដោយទឹកជំនន់ តាមរយៈនៃការពន្យារពេលសម្រាប់ការសងប្រាក់ បន្ធូរបន្ថយការប្រាក់ ឬតាមរយៈការរៀបចំឥណទានឡើងវិញ។ សូមយោគយល់ការលំបាករបស់ប្រជាពលរដ្ឋ។ សម្តេចតេជោ ក៏បានស្នើឱ្យធានាគារជាតិនៃកម្ពុជា ធ្វើការប្រជុំជាមួយម្ចាស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ការអនុគ្រោះ ដើម្បីចូលរួមសម្រាលបន្ទុកនេះ។

បើតាមការវាយតម្លៃប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ដោយទឹកជំនន់ ឆ្នាំ២០២២នេះ មានប្រមាណ២ម៉ឺនគ្រួសារ ដែលទាមទារដោយមានការដោះស្រាយ តាមរយៈការផ្តល់ជំនួយស្បៀង និងការផ្តល់គ្រាប់ពូជសម្រាប់ដាំដុះ។៚

# សម្តេចតេជោ ហ៊ុន សែន ជំរុញឱ្យជួយអន្តរាគមន៍បន្ទាន់ចំពោះ ប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ ប្រមាណ ២ម៉ឺនគ្រួសារ

*អត្ថបទ៖ កែ ផុស , រូបថត៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ*




*សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*

សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ជុំវិញបញ្ហាទឹកជំនន់ថា កន្លែងណាដែលវាយតម្លៃផលប៉ះពាល់រួច ត្រូវដឹកស្រូវពូជ ឬពូជដំណាំចុះជួយកសិករភ្លាមដោយមិនត្រូវរង់ចាំអ្វីទាំងអស់ ហើយបើកន្លែងខ្លះធ្វើស្រូវឡើងវិញបាន ក៏ធ្វើស្រូវ ហើយកន្លែងខ្លះដែលមិនអាចធ្វើស្រូវឡើងវិញបាន បើប្រជាជនត្រូវការពូជដំណាំអ្វី ត្រូវផ្គត់ផ្គង់ពូជនោះ ដើម្បីឱ្យពួកគាត់មានលទ្ធភាពស្តារឡើងវិញនូវដំណាំកសិកម្មរបស់ពួកគាត់។

សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងដូច្នេះ ក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង ចំនួន ៦ ៤១១នាក់ នៅមជ្ឈមណ្ឌលពិព័រណ៍ជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ខែតុលា ឆ្នាំ២០២២ ដោយគូសបញ្ជាក់ថា ព្រោះយើងមានស្តុកយុទ្ធសាស្ត្រស្រាប់ ហើយយន្តការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែធ្វើសកម្មភាពនេះឱ្យបានលឿន ជាមួយនឹងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច។

សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងឱ្យដឹងថា បើយោងទៅលើទិន្នន័យ ជនបទរបស់យើងមានប្រជាជនប្រមាណជា ១៨ភាគរយ ដែលរស់នៅក្រោមបន្ទាប់នៃភាពក្រីក្រ ឬក៏ស្ថានភាពមានហានិភ័យ បើយើងគិតជាគ្រួសារ មានជាង១០ម៉ឺនគ្រួសារ ហើយក្នុងនោះមានប្រហែលជា ១៩ ០០០គ្រួសារ ដែលរងផលប៉ះពាល់។ ដូច្នេះយើងត្រូវធ្វើអន្តរាគមន៍ ជួយស្បៀង ពូជស្រូវ ឬពូជដំណាំ នៅតាមទីកន្លែងដែលមានផលប៉ះពាល់ ដោយសម្តេចក៏បានអំពាវនាវឱ្យមានការយកចិត្តទុកដាក់ តាមរយៈយន្តការក្រុមការងាររបស់រាជរដ្ឋាភិបាលចុះជួយមូលដ្ឋាន កាកបាទក្រហមកម្ពុជា និងសប្បុរសជន ដើម្បីជួយទៅដល់បញ្ហាស្បៀង នៅតាមទីកន្លែងដែលមានការខូចខាតធ្ងន់ធ្ងរនិងប្រជាជនដែលទីទ័លក្រ។

យោងតាមប្រសាសន៍ សម្តេចតេជោ **ហ៊ុន សែន** កិច្ចប្រតិបត្តិការណ៍ជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ទឹកភ្លៀង ក៏ត្រូវបានឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រ ធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះ មហន្តរាយបានផ្តល់ជូននូវស្បៀង គ្រឿងឧបភោគ បរិភោគ និងស្រូវពូជ តាមរយៈគណៈកម្មការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា ជាបន្តបន្ទាប់ដល់ប្រជាជន ដែលមានផលប៉ះពាល់ដោយគ្រោះមហន្តរាយតាមបណ្តាខេត្តរាជធានី។

ជាក់ស្តែងឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ អមដំណើរដោយ អភិបាលខេត្ត និងឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត បានអញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកគ្រាប់ស្រូវពូជ របស់រាជរដ្ឋាភិបាល ជូនប្រជាកសិកររងការខូតខាតដោយគ្រោះទឹកជំនន់ ដែលត្រូវការស្តារឡើងវិញចំនួន ២ ៧០២ គ្រួសារ ស្មើនឹង ២០៥,៣៥០គីឡូក្រាម មកពីស្រុកឆ្លូង ស្រុកព្រែកប្រសព្វ ស្រុកសំបូរ ស្រុកចិត្របុរី និងក្រុងក្រចេះ កាលពីព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២។

ស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីរសៀល ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២។

របាយការណ៍ របស់រដ្ឋបាលខេត្តសៀមរាបវិញ បានបង្ហាញថា គិតចាប់ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២នេះ ការបែងចែកស្បៀង និងគ្រឿងឧបភោគ បរិភោគ ដល់ប្រជាពលរដ្ឋមានផលប៉ះពាល់ដោយគ្រោះមហន្តរាយពីគណៈកម្មការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជាមានចំនួនជាង៦ពាន់គ្រួសារ ក្នុងចំណោមប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់១ម៉ឺន៤៥០គ្រួសារ ក្នុងស្រុកចំនួន ៨ស្រុក នៃខេត្តសៀមរាប។



ឯកឧត្តម គន់ គីម ជួបសំណេះសំណាលនិងចែកស្រូវពូជ ដល់ពលរដ្ឋរងគ្រោះដោយទឹកជំនន់





ក្នុងពិធីផ្តល់ស្រូវពូជ អភិបាលនៃគណៈអភិបាលខេត្តក្រចេះ បានឱ្យដឹងថាជាការយកចិត្តទុកដាក់គិតគូរខ្ពស់ពីសម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** បានផ្តល់ស្រូវពូជចំនួន ២៨១,៦តោនហើយ ដល់ប្រជាកសិករចំនួន ៣ ៦៧៦គ្រួសារ ដើម្បីស្តារឡើងវិញ លើផ្ទៃដីដែលខូចខាតដោយជំនន់ទន្លេមេគង្គ ដោយកាលពីថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២២ រដ្ឋបាលខេត្តបានផ្តល់ជូនស្រូវពូជចំនួន ៧៦,២៥តោនរួចហើយ ដល់ប្រជាកសិករចំនួន៩៤០ គ្រួសារ មកពីក្រុងក្រចេះ ស្រុកព្រែកប្រសព្វ និងស្រុកចិត្របុរី។

ដោយឡែកពូជស្រូវស្រាលប្រមាណ ១០៧,៦០០តោន របស់សម្តេចតេជោ **ហ៊ុន សែន** ក៏ត្រូវបានឯកឧត្តម **គន់ គីម** ទេសរដ្ឋមន្ត្រី អមដំណើរដោយឯកឧត្តម **អ៊ុន ចាន់ដា** អភិបាលខេត្តកំពង់ចាម និងថ្នាក់ដឹកនាំក្នុងខេត្តយកទៅចែកជូនប្រជាពលរដ្ឋប្រមាណជាង ១ ៤៤៥គ្រួសារ មកពីឃុំចំនួន ៦ របស់ស្រុកស្ទឹងត្រង់ ដែលស្រូវវស្សាប្រមាជាង ៧០០ ហិកតា រងការខូចខាតទាំងស្រុង ដោយទឹកជំនន់ទន្លេមេគង្គក្នុងស្រុក

អ្នកនាំពាក្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយលោក **សុទ្ធ គឹមកុលមុន្នី** បានឱ្យដឹងថា គិតត្រឹមថ្ងៃទី ១៧ ខែតុលាឆ្នាំ ២០២២ ទឹកជំនន់បានបង្កឱ្យប៉ះពាល់ដល់ខេត្តចំនួន ២៣ លើកលែងរាជធានីភ្នំពេញ និងខេត្តស្វាយរៀងនិងប៉ះពាល់ដល់ផលដំណាំកសិកម្មជិត ៣០ម៉ឺនហិកតា ក្នុងនោះខូចខាតជិត ១៥ម៉ឺនហិកតា។

ក្នុងចំណោមដំណាំកសិកម្មជិត ៣០ម៉ឺនហិកតា ផលប៉ះពាល់ដោយទឹកជំនន់ ក្នុងនោះ ដំណាំស្រូវមានចំនួន ២១៨ ៦១១ ហិកតា ខូចខាត ១១៣ ៤៩៤ហិកតា អាចស្តារឡើងវិញចំនួន ៥៩ ០៩០ហិកតា។ ចំណែកដំណាំរួមផ្សំវិញ បានប៉ះពាល់ចំនួន ៦៥ ៨៦២ហិកតា ខូចខាត ៣៣ ៨៧៦ហិកតា។

ទឹកជំនន់បានបណ្តាលឱ្យប៉ះពាល់ដល់ប្រជាជនចំនួន ១៣៧ ១៩៣គ្រួសា រស្មើនឹង ៦១៧ ៣៩៦នាក់ ក្នុងនោះបានជម្លៀសទៅរកទីទួលសុវត្ថិភាពចំនួន ៥ ៤២៣គ្រួសារ ស្មើនឹង ២៤ ៤០៤នាក់ ជម្លៀសសត្វពាហនៈចំនួន ៣៦ ៥៦០ក្បាល និងងាប់ ១៤ក្បាល លិចផ្ទះប្រជាជនចំនួន ៦១ ៨៨០ខ្នង ខូច

ខាតចំនួន ១១៥ខ្នង លិចសាលារៀន ៣៤៩សាលា វត្តអារាម ១០៨វត្ត។ ទឹកជំនន់ក៏បណ្តាលឱ្យលិចផ្លូវជាតិផ្លូវខេត្ត ផ្លូវក្រួសក្រហមប្រវែង ១១១គីឡូម៉ែត្រ ផ្លូវលំប្រវែង ៤៨៩គីឡូម៉ែត្រ ផ្លូវលំខូចប្រវែង ២៨០គីឡូម៉ែត្រ ប៉ះពាល់ទំនប់ ៤៥គីឡូម៉ែត្រ។ នេះជាការបញ្ជាក់របស់លោក **សុទ្ធ គឹមកុលមុន្នី** ។

យោងតាមរបាយការណ៍បឋមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គិតត្រឹមថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ ក្រសួងត្រូវការស្រូវពូជប្រមាណជាង ៤ ៨២៤តោន សម្រាប់យកទៅចែកជូនប្រជាកសិករ ដែលរងគ្រោះដោយទឹកជំនន់


គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយចុះជួយប្រជាពលរដ្ឋ


ការប្រគល់អំណោយស្បៀង និងស្រូវពូជ ដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់

សម្រាប់ដាំដុះ និងស្តារផលដំណាំដែលរងការខូចខាត ឡើងវិញ។

របាយការណ៍ដដែលបន្តថា គ្រោះទឹកជំនន់បង្កឱ្យប៉ះពាល់ផលដំណាំជាង ២៥ម៉ឺនហិកតា នៅរាជធានី-ខេត្តចំនួន២១ ក្នុងនោះខូចខាតជាង ១០ម៉ឺនហិកតា។ ចំណោមផលដំណាំជាង ២៥ម៉ឺនហិកតា ក្នុងនោះដំណាំស្រូវមានចំនួន ២០៦ ៧៧២,៧០ ហិកតា ខូចខាត ៨៥ ១២៨,៥៥ហិកតា អាចស្តារឡើងវិញ ៤ ៨៤២,៣៦ហិកតា។ ចំណែកដំណាំរួមផ្សំវិញ ប៉ះពាល់ចំនួន ៤ ២៦៨,៧២ហិកតា ខូចខាត ៨៩៣,២២ហិកតា អាចស្តារឡើង


ឯកឧត្តម ទិត ឌីណា ជួបសំណេះសំណាល និងចែកស្រូវពូជដល់ពលរដ្ឋរងគ្រោះដោយទឹកជំនន់



*ឯកឧត្តម គន់ គីម ត្រៀមជំនួយសម្រាប់ជួយពលរដ្ឋ*

វិញ ៣៧៨ហិកតា និងដំណាំឧស្សាហកម្មប៉ះពាល់ ៤៩ ១៧១,៧០ ហិកតា ខូចខាត ២២ ៦០៦,២០ហិកតា អាចស្តារឡើងវិញ ២ ១៣២ហិកតា ដោយមានប្រជាពលរដ្ឋរងផលប៉ះពាល់សរុប ១០៧ ៧៦២នាក់។

របាយការណ៍ខាងលើបន្តទៀតថា ក្នុងចំណោមរាជធានី-ខេត្ត ២១ ដែលរងផលប៉ះពាល់ ខេត្តត្រូវការគ្រាប់ពូជរួមមាន ៖ ខេត្តកំពង់ធំ ប៉ះពាល់ដំណាំស្រូវ ២ ៤៩១៨ហិកតា ក្នុងនោះខូចខាត ១២ ២៣១ហិកតា និងអាចស្តារឡើងវិញបានចំនួន ៩ ៥៩០ហិកតា ហើយត្រូវការគ្រាប់ពូជដាំដុះឡើងវិញ ៩៥៩តោន។ ខេត្តបន្ទាយមានជ័យប៉ះពាល់ ៣៧ ២៣៨ហិកតា ខូចខាត ៦៥០៣ហិកតា ស្តារឡើងវិញ ៥ ៦៤៦ហិកតា ត្រូវការគ្រាប់ពូជ ៥៦៥តោន។ ខេត្តសៀមរាបប៉ះពាល់ ៣៧ ៧៨៥ហិកតា ខូចខាត ១៣ ០៦៣ហិកតា ស្តារឡើងវិញ ៣ ៧៧៤ ត្រូវការគ្រាប់ពូជ ៣៧៧តោន។ ខេត្តបាត់ដំបងប៉ះពាល់ ៤៣ ០១២ ហិកតា ខូចខាត ២៣ ៦៦៨ហិកតា ស្តារឡើងវិញ ១៨ ៧១៥ ហិកតា ត្រូវការគ្រាប់ពូជ ១ ៨៧២តោន។ ខេត្តក្រចេះប៉ះពាល់ ៣ ៤៥៩ហិកតា ខូចខាត២ ៧៩៨ហិកតា ស្តារឡើងវិញ២ ៧៨៤ ហិកតា ត្រូវការគ្រាប់ពូជ ២៧៨តោន។ ខេត្តព្រៃវែងប៉ះពាល់ ៦ ៥៥០ហិកតា ខូចខាត ៤ ៦៣៣ហិកតា ស្តារឡើងវិញ ៤ ៣៩៥ហិកតា ត្រូវការគ្រាប់ពូជ ៤៤០តោន។ ខេត្តកំពង់ឆ្នាំង ប៉ះពាល់ ៨៤៥ហិកតា ខូចខាត ៤៦ហិកតា ស្តារឡើងវិញ ៤៦ ហិកតា ត្រូវការគ្រាប់ពូជ៥តោន។ ខេត្តកំពង់ស្ពឺប៉ះពាល់ ៣០២ ហិកតា ខូចខាត ៦៣ហិកតា ស្តារឡើងវិញ ៤៦ហិកតា ត្រូវការគ្រាប់ពូជ ៥តោន។ ខេត្តពោធិ៍សាត់ប៉ះពាល់ ១៦ ៦៣៧ហិកតា ខូចខាត ៦ ១៤៧ហិកតា ស្តារឡើងវិញ ៣១ហិកតា ត្រូវការគ្រាប់ពូជ ៣តោន និងខេត្តត្បូងឃ្មុំប៉ះពាល់ ៣ ៩៩៣ហិកតា ខូចខាត ៣ ៧៣៩ហិកតា ស្តារឡើងវិញ ៣ ២១៤ហិកតា ត្រូវការគ្រាប់ពូជ ៣២១តោន ក្នុងនោះបានផ្តល់រួចហើយចំនួន ៥៦,៥៥តោន។

ទឹកជំនន់នេះបណ្តាលឱ្យប៉ះពាល់ដល់ប្រជាជនចំនួន ១១២ ៧៦០គ្រួសារ ស្មើនឹង ៥០៧ ៤២០នាក់ ក្នុងនោះបានជម្លៀសទៅរកទីទួលសុវត្ថិភាព ៤ ៥៥៦គ្រួសារ ស្មើនឹង ២០ ៥០២នាក់ លិចផ្ទះប្រជាជន ៥១ ២០០ខ្នង ខូចខាត ២៨៥ខ្នង លិចសាលារៀន ៣៣២សាលា វត្តអារាម ១០២វត្ត លិចស្រូវ ១៩៣ ៥៦២ ហិកតា ខូចខាតជាង៦ម៉ឺនហិកតា លិចដំណាំរួមផ្សំ ៤៤ ៣៩៣ ហិកតា និងលិចផ្លូវជាតិ ផ្លូវខេត្ត ផ្លូវក្រួសក្រហមប្រវែង ៦៩ គីឡូម៉ែត្រ ផ្លូវលំប្រវែង ១ ៤៣៣គីឡូម៉ែត្រ ប៉ះពាល់ទំនប់ ៤៥ គីឡូម៉ែត្រ និងច្រាំងទន្លេប៉ះពាល់ ២ ១៤៩ម៉ែត្រ៕

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ប្រធានាធិបតីទីម័រខាងកើត នៅកម្ពុជា

តបតាមការអញ្ជើញរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមបណ្ឌិត **ចូហ្សេ ម៉ានូអែល រ៉ាមូស អរតា** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ១៩ ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ។

ក្នុងអំឡុងពេលទស្សនកិច្ចផ្លូវរដ្ឋនេះ ឯកឧត្តមប្រធានាធិបតី ចូហ្សេ ម៉ានូអែល រ៉ាមូស អរតា បានចូលក្រាបបង្គំគាល់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ។ ឯកឧត្តមប្រធានាធិបតី ក៏មានជំនួបដោយឡែកពីគ្នាជាមួយ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា និង សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ផងដែរ។

ឯកឧត្តមប្រធានាធិបតី ចូហ្សេ ម៉ានូអែល រ៉ាមូស អរតា និង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជួបប្រជុំកំពូលទ្វេភាគី នៅថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០២២ ដើម្បីពិភាក្សាអំពីការពង្រឹងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានវាយតំលៃខ្ពស់ចំពោះដំណើរទស្សនកិច្ចផ្លូវរដ្ឋដ៏មានអត្ថន័យរបស់ ឯកឧត្តមប្រធានាធិបតី ចូហ្សេ ម៉ានូអែល រ៉ាមូស អរតា ក្នុងពេលដែលប្រទេសទាំងពីរប្រារព្ធខួបលើកទី២០ នៃការបង្កើតទំនាក់ទំនងការទូត។ ថ្នាក់ដឹកនាំទាំងពីរបានស្វាគមន៍ចំពោះការចូលជាធរមាននាពេលថ្មីៗនេះ នៃកិច្ចព្រមព្រៀងស្តីពីការលើកលែងទិដ្ឋាការសម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ ដែលត្រូវបានចុះហត្ថលេខាក្នុងឱកាសនៃដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ទៅកាន់ប្រទេសទីម័រខាងកើត កាលពីឆ្នាំ២០១៦ និងបានចាត់ទុកកិច្ចព្រមព្រៀងនេះថាជាការបោះជំហានមួយទៀតនៅក្នុងការពង្រឹងទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។

សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរំឭកឡើងវិញអំពីការពិភាក្សាប្រកបដោយផ្លែផ្កានាពេលថ្មីៗនេះរវាងថ្នាក់ដឹកនាំទាំងពីរនៅទីក្រុងញូវយ៉ក ជាពិសេស អំពីសារៈសំខាន់នៃការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានជំរុញឲ្យអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទាំងពីរបន្តអនុវត្តប្រកបដោយប្រសិទ្ធភាពនូវឯកសារចំនួនបី ដែលបានចុះហត្ថលេខារួច រួមមាន ៖ អនុស្សរណៈនៃការយោគយល់ស្តីពីកិច្ច

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (85[illegible]23 216 122
ទូរសារ : (855) 23 [illegible] 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

សហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងបច្ចេកទេស, កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យបច្ចេកទេស និងសេដ្ឋកិច្ច, និង អនុស្សរណៈនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការរវាងសភាពាណិជ្ជកម្មនៃប្រទេសទាំងពីរ។

**ឯកឧត្តមប្រធានាធិបតី ចូហ្សេ ម៉ានូអែល រ៉ាមូស អរតា** បានបង្ហាញចំណាប់អារម្មណ៍ និងទទួលយកទៅពិចារណាសំណើរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** សម្រាប់ការវិនិយោគដោយប្រទេសទីម័រខាងកើត លើវិស័យម៉ាស៊ីនកិនស្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់នាំចេញទៅកាន់ប្រទេសទីម័រខាងកើត ដើម្បីបំពេញតម្រូវការក្នុងប្រទេស។

ថ្នាក់ដឹកនាំទាំងពីរបានសំដែងការពេញចិត្តចំពោះកិច្ចព្រមព្រៀងសេវាកម្មអាកាសចរណ៍ ដែលនឹងត្រូវចុះហត្ថលេខាបន្ទាប់ពីកិច្ចប្រជុំនេះ ហើយសង្ឃឹមថាវានឹងនាំទៅដល់ការបង្កើតការតភ្ជាប់ជើងហោះហើររវាងប្រទេសទាំងពីរ។

**ឯកឧត្តមប្រធានាធិបតី ចូហ្សេ ម៉ានូអែល រ៉ាមូស អរតា** បានកោតសរសើរចំពោះទឹកចិត្តសប្បុរសរបស់កម្ពុជា ក្នុងការផ្តល់ម៉ាស់ និងឧបករណ៍វេជ្ជសាស្ត្រ ដើម្បីចូលរួមចំណែកដល់ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ របស់ប្រទេសទីម័រខាងកើត និងបានថ្លែងអំណរគុណកម្ពុជាដែលបានផ្តល់អាហារូបករណ៍ដល់និស្សិតទីម័រខាងកើតចំនួន១០នាក់។

ថ្នាក់ដឹកនាំទាំងពីរក៏បានពិភាក្សាផងដែរអំពីកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ ជាពិសេសក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន រួមទាំងការជួញដូរមនុស្សផងដែរ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានបញ្ជាក់ជាថ្មីអំពីការគាំទ្ររបស់កម្ពុជាចំពោះសំណើសុំចូលជាសមាជិកអាស៊ានរបស់ទីម័រខាងកើត រីឯ **ឯកឧត្តមប្រធានាធិបតី ចូហ្សេ ម៉ានូអែល រ៉ាមូស អរតា** បានវាយតម្លៃខ្ពស់ចំពោះការបន្តគាំទ្ររបស់កម្ពុជា។

នៅចុងបញ្ចប់នៃជំនួប **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** និង**ឯកឧត្តមប្រធានាធិបតី ចូហ្សេ ម៉ានូអែល រ៉ាមូស អរតា** បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារចំនួនពីរ រួមមាន៖ កិច្ចព្រមព្រៀងសេវាកម្មអាកាសចរណ៍ និងអនុស្សរណៈនៃការយោគយល់ស្តីពីពាណិជ្ជកម្មស្រូវ រវាងប្រទេសទាំងពីរ។

នៅក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ **ឯកឧត្តមប្រធានាធិបតី ចូហ្សេ ម៉ានូអែល រ៉ាមូស អរតា** បានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ និងកន្ត្រកផ្កានៅមណ្ឌបព្រះបរមរូប **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ»** អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ **ឯកឧត្តមប្រធានាធិបតី** ក៏បានអញ្ជើញធ្វើបាឋកថាសាធារណៈនៅសាកលវិទ្យាល័យចំនួនបី នៅក្នុងរាជធានីភ្នំពេញផងដែរ៕ ៚

ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែតុលា ឆ្នាំ២០២២

## តបតាមការអញ្ជើញរបស់ ព្រះមហាក្សត្រ កម្ពុជា ប្រធានាធិបតី នៃប្រទេសទីម័រខាងកើត ឯកឧត្តម ចូហ្សេ ម៉ានុយអែល រ៉ាមូស ( JOSÉ MANUEL RAMOS-HORTA ) បានធ្វើទស្សនកិច្ចជាផ្លូវរដ្ឋនៅប្រទេសកម្ពុជា កាលពីថ្ងៃទី១៩ ដល់ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២














# នាយករដ្ឋមន្ត្រីគុយបា សន្យាប្រឹងប្រែងពង្រឹងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជាឱ្យកាន់តែរឹងមាំថែមទៀត

*អត្ថបទ ៖ សៅ សុវណ្ណ , រូបថត ៖ ព្រឹទ្ធសភា*

ឯកឧត្តម **ម៉ានូអែល ម៉ារ៉េរ៉ូ គ្រុស** (Manuel Marrero Cruz) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋគុយបា សន្យាថា នឹងខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្តដើម្បីពង្រឹងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែរឹងមាំថែមទៀត។

តាមរយៈដំណើរទស្សនកិច្ចនៅកម្ពុជាពិតជាមានសារៈសំខាន់ណាស់ក្នុងការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ពិសេសការផ្សារភ្ជាប់ទំនាក់ទំនងខាងសេដ្ឋកិច្ច និងពាណិជ្ជកម្មនៃប្រទេសទាំងពីរ ដែលអាចរួមចំណែកដល់ការអភិវឌ្ឍប្រទេសគុយបានាពេលខាងមុខ។

ឯកឧត្តម **ម៉ានូអែល ម៉ារ៉េរ៉ូ គ្រុស** (Manuel Marrero Cruz) បានលើកឡើងបែបនេះ ក្នុងឱកាសដែលឯកឧត្តម និងប្រតិភូបានអញ្ជើញចូលជួបសម្តែងការគួរសមធ្វើសវនាការ



ជាមួយសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភា។

ក្នុងសវនការនោះ សម្តេចប្រធានព្រឹទ្ធសភា បានសម្តែង



សម្តេចវិបុលសេនាភក្តី សាយ ឈុំ ទទួលជួបសវនការជាមួយឯកឧត្តម ម៉ានូអែល ម៉ារ៉េរ៉ូស៍ គ្រុស នាយករដ្ឋមន្ត្រីគុយបា



រូបថតអនុស្សាវរីយ៍

ការស្វាគមន៍ដ៏កក់ក្តៅចំពោះឯកឧត្តម **ម៉ានូអែល ម៉ារ៉េរ៉ូ គ្រុស** និងគណៈប្រតិភូដែលបានអញ្ជើញមកបំពេញទស្សនកិច្ចជាមិត្តភាព និងផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។ តាមរយៈដំណើរទស្សនកិច្ចរបស់ឯកឧត្តមនៅកម្ពុជានាពេលនេះ ពិតជាមានសារៈសំខាន់ជាខ្លាំងដល់ការពង្រឹងពង្រីកចំណងមិត្តភាព សហប្រតិបត្តិការល្អរវាងប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរឡើងនិងរឹងមាំថែមទៀត ដែលនឹងនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមក ទាំងក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត។

ជាមួយគ្នានេះ សម្តេចប្រធានព្រឹទ្ធសភា បានសម្តែងនូវការចូលរួមសោកស្តាយចំពោះរដ្ឋាភិបាល និងប្រជាជនគុយបា ដែលទទួលរងគ្រោះ និងគ្រោះមហន្តរាយខូចខាតដែលបង្កឡើងដោយព្យុះសង្ឃរា Hurricane Ian កាលពីពេលថ្មីៗកន្លងមកនេះ។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ានូអែល ម៉ារ៉េរ៉ូ គ្រុស** បានរំលឹកអំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ តាំងពីឆ្នាំ១៩៥៩មក ជាពិសេសទំនាក់ទំនងដ៏ល្អប្រពៃរវាងថ្នាក់ដឹកនាំគុយបា និងសម្តេចព្រះបរមរតនកោដ្ឋ។ ក្រៅពីនេះប្រទេសទាំងពីរក៏មានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងសភានៃប្រទេសទាំងពីរផងដែរ។ ក្នុងនោះដែរនាពេលថ្មីៗនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋគុយបា និងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូគុយបានៅព្រះរាជាណាចក្រកម្ពុជាក្នុង



រូបថតអនុស្សាវរីយ៍




សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម ម៉ានូអែល ម៉ារ៉េរ៉ូស គ្រុស អញ្ជើញធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារសំខាន់ចំនួន ២ គឺវិស័យអប់រំ និងវប្បធម៌រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋគុយបា

ឱកាសនេះ គឺជាសក្ខីភាពនៃការលើកកម្ពស់ទំនាក់ទំនងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត។

ឯកឧត្តមនាយករដ្ឋមន្ត្រី បានជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភាជ្រាបថា គោលបំណងនៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនាពេលនេះ គឺដើម្បីពង្រឹងពង្រីកនូវទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំថែមទៀត ជាពិសេសការផ្សារភ្ជាប់ទំនាក់ទំនងខាងសេដ្ឋកិច្ច និងពាណិជ្ជកម្ម។ ឯកឧត្តមនាយករដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណដល់ព្រះរាជាណាចក្រកម្ពុជាដែលបានផ្តល់ជំនួយជាអង្ករជូនចំពោះរដ្ឋាភិបាល និងប្រជាជនគុយបាផងដែរ។

សម្តេចប្រធានព្រឹទ្ធសភា បានរំលឹកអំពីទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ដែលត្រូវបានបង្កើតឡើងចាប់ពីឆ្នាំ ១៩៦០ ដោយព្រះករុណាព្រះបាទ **សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** និងឯកឧត្តម **ហ្វីដែលកាស្ត្រូ** ប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋគុយបា។ ប្រទេសទាំងពីរបានផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំទៅវិញទៅមក និងគាំទ្រគ្នាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។ សាធារណរដ្ឋគុយបាបានគាំទ្រខាងនយោបាយ វិស័យអប់រំ និងវិស័យសុខាភិបាលដល់ប្រទេសកម្ពុជានៅក្នុងកាលៈទេសៈលំបាកបំផុត ក្រោយពីរបបប្រល័យពូជសាសន៍ **ប៉ុល ពត** និងក្រោមការហ៊ុមព័ទ្ធសេដ្ឋកិច្ច និងនយោបាយពីខាងក្រៅ។ ប្រទេសកម្ពុជាក៏បានគាំទ្រប្រទេសគុយបាក្នុងការប្រឆាំងចំពោះការហ៊ុមព័ទ្ធសេដ្ឋកិច្ចប្រទេសគុយបាតាមរយៈការដាក់ទណ្ឌកម្មនានាដោយអយុត្តិធម៌ ដែលនេះសបញ្ជាក់អំពីការរំលោភសិទ្ធិរបស់ប្រជាជនគុយបា និងរំលោភលើច្បាប់អន្តរជាតិ។ ការជួយគាំទ្រគ្នាទៅវិញទៅមកនេះ មិនត្រឹមតែនាំមកនូវផលប្រយោជន៍ជូនប្រទេសទាំងពីរប៉ុណ្ណោះទេ ប៉ុន្តែបានរួមចំណែកក្នុងការថែរក្សាសន្តិភាពស្ថិរភាព សន្តិសុខ ក្នុងតំបន់ និងអន្តរជាតិផងដែរ ។

សម្តេចប្រធានព្រឹទ្ធសភា បានគាំទ្រឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរបន្តអនុវត្តន៍យន្តការដែលមានស្រាប់តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ និងអនុវត្តន៍ឱ្យបានពេញលេញនូវ

អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ សម្តេចយល់ថា ប្រទេសទាំងពីរគួរគប្បីខិតខំទាញយកផលប្រយោជន៍ពីសក្តានុពលនៃយន្តការ និងកិច្ចព្រមព្រៀងខាងលើឱ្យបានច្រើនជាអតិបរិមា ដើម្បីនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

សម្តេចប្រធានព្រឹទ្ធសភាបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័ននីតិបញ្ញត្តិរវាងប្រទេសទាំងពីរ តាមរយៈការផ្លាស់ប្តូរទស្សនកិច្ច និងជំនួបរវាងថ្នាក់ដឹកនាំ និងសមាជិកសភានៃសភាប្រទេសទាំងពីរ និងការគាំទ្រគ្នាទៅវិញទៅមកនៅក្នុងក្របខ័ណ្ឌអន្តរសភា រួមមាន៖ សន្និសីទតំបន់អាស៊ី-ប៉ាស៊ីហ្វិក (ICAP) និងសហភាពអន្តរសភា (IPU)។ តាមរយៈឯកឧត្តមនាយករដ្ឋមន្រ្តី សម្តេចមានបំណងបង្កើនកិច្ចសហប្រតិបត្តិការរវាងព្រឹទ្ធសភាកម្ពុជា ជាមួយនឹងរដ្ឋសភាអំណាចប្រជាជនគុយបា។

សូមបញ្ជាក់ថា កាលពីល្ងាចថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០២២ នេះ បន្ទាប់ពីមានជំនួបទ្វេភាគីរួចមក សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Manuel Marrero Cruz នាយករដ្ឋមន្រ្តី នៃសាធារណរដ្ឋគុយបា បានអញ្ជើញធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារសំខាន់ៗចំនួន០២ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋគុយបា ដែលឯកសារចំនួន០២ នោះ រួមមាន៖

១- កម្មវិធីសហប្រតិបត្តិការ និងផ្លាស់ប្តូរវប្បធម៌រវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជា និងក្រសួងវប្បធម៌នៃសាធារណរដ្ឋគុយបា សម្រាប់ឆ្នាំ ២០២២ ដល់ ២០២៧។

២- កិច្ចព្រមព្រៀង នៃកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំកាយ វប្បធម៌និងកីឡារវាងក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា និងវិទ្យាស្ថានជាតិ កីឡា អប់រំ កាយ និងកម្សាន្តនៃសាធារណរដ្ឋគុយបា៕




សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម ម៉ានូអែល ម៉ារេរ៉ូស គ្រុស អញ្ជើញធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារសំខាន់ចំនួន ២ គឺវិស័យអប់រំ និងវប្បធម៌រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋគុយបា

# រដ្ឋសភាបើកសម័យប្រជុំលើកទី ៨ នីតិកាលទី ៦

*អត្ថបទ ៖ សៅ សុវណ្ណ , រូបថត ៖ រដ្ឋសភា*



សម្តេចអគ្គពញាចក្រី ហេង សំរិន អញ្ជើញជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងសម័យប្រជុំរដ្ឋសភា

រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំលើកទី៨នីតិកាលទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា កាលពីថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០២២ ដោយមានវត្តមានសមាជិក សមាជិការដ្ឋសភា ពេលចាប់ផ្តើមសម័យប្រជុំចំនួន ៩៣រូប ។

របៀបវារៈសម័យប្រជុំរដ្ឋសភាលើកទី ៨ នីតិកាលទី ៦ មានចំនួន ៥ គឺ៖

១-ព្រះរាជសារព្រះករុណាព្រះបាទ សម្តេច**ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជូនសម័យប្រជុំរដ្ឋសភាលើកទី ៨ នីតិកាទី ៦ ។

២-របាយការណ៍សង្ខេបស្តីពី សកម្មភាពការងាររបស់រដ្ឋសភា ចន្លោះសម័យប្រជុំរដ្ឋសភាលើកទី ៧ និងលើកទី ៨ នីតិកាទី ៦ ។

៣-ការសម្រេចអំពីសុពលភាព នៃអាណត្តិរបស់បេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រនីតិកាលទី ៦ នៃរដ្ឋសភាចំនួន ២រូប៖គឺ ឯកឧត្តម **ហេង ប៊ុនថាន់** ជាតំណាងរាស្ត្រមណ្ឌលខេត្តរតនគិរី ជំនួសឯកឧត្តម **ប៊ូ ឡាំ** ដែលបានទទួលមរណភាព ។ ឯកឧត្តម **នុត ដា** ជាតំណាងរាស្ត្រមណ្ឌលរាជធានីភ្នំពេញ ជំនួសឯកឧត្តម **ជៀប ស៊ីវន** ដែលបានទទួលមរណភាព ។




៤-ការបោះឆ្នោតជ្រើសតាំង៖ ឯកឧត្តម **ចាន់ យឿន** ជាសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈនៃរដ្ឋសភា ។ លោកជំទាវ **ស៊ុន សារឿន** ជាសមាជិកគណៈកម្ម



ទិដ្ឋភាពរួមសម័យប្រជុំរដ្ឋសភា



សមាជិករដ្ឋសភា

ការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា ។

៥-ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីបួន ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន ។សេចក្តីព្រាងច្បាប់នេះមាន ២មាត្រា អង្គរដ្ឋសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ទាំងមូលមានចំនួន ៩៦ សម្លេង ។

មុននឹងចាប់ផ្តើមសម័យប្រជុំរដ្ឋសភា តាមរបៀបវារៈអង្គសភាបានអនុម័តយល់ព្រមលើ សមាសភាពលេខាធិការសម័យប្រជុំរដ្ឋសភា លើកទី ៨ នីតិកាទី ៦ ចំនួន ៣រូប ដែលមានរាយនាមដូចតទៅ៖១-ឯកឧត្តម **ពេជ្រ ជីវ័ន** អាយុ ៦៩ឆ្នាំ,២-ឯកឧត្តម **សៀង ស៊ុតថង** អាយុ ៧០ឆ្នាំ,និង ៣-ឯកឧត្តម **ស៊ូ តិរិទ្ធ** អាយុ ៧០ឆ្នាំ ៕



ឯកឧត្តម ឡេង ប៉េងឡុង អញ្ជើញឡើងរាយការណ៍
ពីវត្តមានសមាជិក-សមាជិការដ្ឋសភា

# ទំហំពាណិជ្ជកម្មកម្ពុជា-វៀតណាមរំពឹងថាកើនដល់ ១២ពាន់លានដុល្លារ នៅឆ្នាំ២០២២

## ✪ ភាគីទាំងពីរឯកភាពគ្នាបន្តការបោះបង្គោលព្រំដែន ដែលនៅសេសសល់ចំនួន ១៦ភាគរយ ទៀតឱ្យបាននាប់

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ AKP-ព្រឹទ្ធសភា-រដ្ឋសភា*



សម្តេចអគ្គមហាពញាចក្រី ហេង សំរិន អនុញ្ញាតឱ្យឯកឧត្តម ដុ វ៉ាន់ចៀន ចូលជួបពិភាក្សាការងារ



ប្រតិភូវៀតណាម



ថ្នាក់ដឹកនាំរដ្ឋសភា

ទំហំពាណិជ្ជកម្មប្រទេសកម្ពុជានិងវៀតណាមរំពឹងថា នៅឆ្នាំ២០២២ នេះនិងសម្រេចបាន ១២ពាន់លានដុល្លារ ។

ការរំពឹងបែបនេះក្នុងឱកាសដែល ឯកឧត្តម **ដុ វ៉ាន់ចៀន** ( H.E DO VAN CHiEN ) គណៈលេខាមជ្ឈិមបក្សនិងជាប្រធានគណៈកម្មាធិការមជ្ឈិមរណសិរ្សមាតុភូមិវៀតណាមព្រមទាំងគណៈប្រតិភូបានការអនុញ្ញាតពី សម្តេចអគ្គពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ នៅ



ទិដ្ឋភាពទូទៅនៃជំនួបពិភាក្សាការងារ

វិមានរដ្ឋសភា ។

ឯកឧត្តម **ដូ វ៉ាន់ចៀន** បានអបអរសាទរចំពោះជោគជ័យរបស់កម្ពុជា នៅក្នុងការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នាពេលកន្លងមកនេះ ។ ជាមួយគ្នានេះ ឯកឧត្តមបានវាយតម្លៃខ្ពស់ពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការដាក់ចេញវិធានការដ៏មានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យ ។

ទន្ទឹមនេះដែរ ឯកឧត្តម **ដូ វ៉ាន់ចៀន** បានវាយតម្លៃខ្ពស់ពីការរីកចម្រើននូវចំណងមិត្តភាព កិច្ចសហប្រតិបត្តិការជាបងប្អូននៃប្រទេសទាំងពីរ ដែលមានការរីកចម្រើនជាលំដាប់ ទោះបីនៅក្នុងកាលៈទេសៈដ៏លំបាកនៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ជាសកលនេះយ៉ាងណាក្តី ។ ឯកឧត្តមបានកត់សម្គាល់ថា ទំហំពាណិជ្ជកម្មប្រទេសកម្ពុជានិងវៀតណាម សម្រេចបាន ៩ពាន់លានដុល្លារនៅឆ្នាំ ២០២១ និងរំពឹងថា នៅឆ្នាំ២០២២ នេះ និងសម្រេចបាន ១២ពាន់លានដុល្លារ ។

ក្នុងកិច្ចពិភាក្សានោះដែរ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** បានចាត់ទុកវត្តមានរបស់គណៈប្រតិភូរណសិរ្សមាតុភូមិវៀតណាមនាពេលនេះ បង្ហាញពីការបន្តលើកកម្ពស់ទំនាក់ទំនងមិត្តភាពសាមគ្គីភាពជាប្រពៃណីនិងកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរ ដែលមានជាយូរលង់មកហើយ ពិសេសរវាងរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា និងរណសិរ្សមាតុភូមិវៀតណាម ឱ្យកាន់តែល្អប្រសើរថែមទៀត ។

សម្តេចប្រធានរដ្ឋសភា បានគូសបញ្ជាក់ថា ទំនាក់ទំនងមិត្តភាព សាមគ្គីភាពជាប្រពៃណី ភាពជាអ្នកជិតខាងល្អនិងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសកម្ពុជានិងវៀតណាម ត្រូវបានថ្នាក់ដឹកនាំនិងប្រជាជនជាច្រើនជំនាន់រួមគ្នាពូនជ្រុំ និងកសាងជាបន្តបន្ទាប់ ដើម្បីតម្កល់ទុកជាឧត្តមប្រយោជន៍សម្រាប់ប្រជាជាតិទាំងសងខាង ។ នៅក្នុងរយៈពេលជាង៥ទសវត្សរ៍មកនេះប្រទេសទាំងពីរសម្រេចបាននូវសមិទ្ធផលជាច្រើន ដែលកើតចេញពីចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងបក្សរដ្ឋ និងរដ្ឋាភិបាលប្រទេសទាំងពីរ កម្ពុជា-វៀតណាម ។

សម្តេចប្រធានរដ្ឋសភា បានវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការយ៉ាងប្រសើរលើគ្រប់វិស័យរវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរដើម្បីជាឧត្តមប្រយោជន៍ សម្រាប់ប្រជាជាតិទាំងសងខាងមានជាអាទិ៍ ការសម្រេចបានកំណើននៃពាណិជ្ជកម្មទ្វេភាគីគួរឱ្យកត់សម្គាល់ ហើយថ្មីៗនេះប្រទេសទាំងពីរបានសហការគ្នាយ៉ាងជោគជ័យក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដោយអាចបើកប្រទេសឡើងវិញ និងបានចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច និងទេសចរណ៍ឡើងវិញផងដែរ ។

ក្នុងឱកាសនោះ សម្តេចបានសម្តែងនូវការអបអរសាទរចំពោះ ការសម្រេចបាននូវអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកម្មវិធីសហប្រតិបត្តិការរវាងរណសិរ្សប្រទេសកម្ពុជា-វៀតណាម និងប្រទេសឡាវសម្រាប់ដំណាក់កាលឆ្នាំ២០២០-២០២៣។ សម្តេចមានសុទិដ្ឋិនិយមថា កម្ពុជា-វៀតណាម នឹងបន្តអនុវត្តអនុស្សរណៈនៃការយោគយល់នេះ ឱ្យក្លាយទៅជាសកម្មភាព និងសមិទ្ធផលជាក់ស្តែង ដើម្បីផលប្រយោជន៍សម្រាប់ប្រជាជាតិទាំងសងខាង ។

នៅថ្ងៃទី២៩ ខែកក្កដា ដដែលនេះដែរ ឯកឧត្តម **ដូ វ៉ាន់ចៀន** គណៈលេខាមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម និងប្រតិភូអមដំណើរបានការអនុញ្ញាតពី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារនៅវិមានសន្តិភាពផងដែរ ។

នៅក្នុងជំនួបនោះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានអបអរសាទរនិងស្វាគមន៍ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ ដែលចាត់ទុកថាជាឱកាសដ៏ថ្លៃថ្លាមួយក្នុងការរួមចំណែក ប្រារព្ធខួបទី៥៥នៃថ្ងៃបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ហើយការផ្លាស់ប្តូរ ទស្សនកិច្ចទៅវិញទៅមករវាង គណៈប្រតិភូគ្រប់ជាន់ថ្នាក់របស់ប្រទេសទាំងពីរកម្ពុជានិងវៀតណាម បានបង្ហាញពីទំនាក់ទំនងល្អប្រសើរនិងកិច្ចសហប្រតិបត្តិការស្អិតរមួតរវាងប្រទេសទាំងពីរជាបងប្អូនជាអ្នកជិតខាង ។

សម្តេចតេជោបានមានប្រសាសន៍សង្ឃឹមថា ទស្សនកិច្ច



សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម ដុ វ៉ាន់ចៀន



សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យឯកឧត្តម ដុ វ៉ាន់ចៀន ចូលជួបពិភាក្សាការងារ

នេះនឹងជួយពង្រឹងថែមទៀតនៅទំនាក់ទំនងល្អប្រសើររវាងប្រទេសទាំងពីរ បក្សទាំងពីរ និងរណសិរ្សប្រទេសទាំងពីរ ។

ជាការឆ្លើយតប ឯកឧត្តម Do Van Chien បានសំដែងសេចក្តីសប្បាយរីករាយ ដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជាក្នុងឱកាសនេះ ដែលជាឱកាសល្អក្នុងការរឹតបន្តឹងទំនាក់ទំនងរវាងប្រទេសទាំងពីររណសិរ្ស និងបក្សទាំងពីរ ហើយឯកឧត្តមក៏បាន ពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីថ្នាក់ដឹកនាំវៀតណាមជូនចំពោះសម្តេចតេជោនាយករដ្ឋមន្ត្រីផងដែរ ។ ជាមួយនេះដែរ ឯកឧត្តម Do Van Chien ក៏បានសម្តែងនូវការអបអរសាទរចំពោះជោគជ័យដ៏ត្រចះត្រចង់របស់គណបក្សប្រជាជនកម្ពុជាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នាពេលកន្លងមក ដែលបានបង្ហាញពីជំនឿទុកចិត្តដ៏ខ្ពស់របស់ប្រជាជននិងជូនពរឱ្យគណបក្សប្រជាជនកម្ពុជាទទួលបានជោគជ័យត្រចះត្រចង់ថែមទៀត ក្នុងការបោះឆ្នោតសកលនៅឆ្នាំ២០២៣ ខាងមុខនេះ ។ ឯកឧត្តមក៏បានមានប្រសាសន៍វាយតម្លៃខ្ពស់ចំពោះវិធានការដែលសម្តេចតេជោ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការ ទប់ស្កាត់ ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យ ដោយមានអត្រានាំមុខក្នុងការចាក់វ៉ាក់សាំងនៅក្នុងតំបន់និងពិភពលោក ហើយទទួលបានលទ្ធផលល្អប្រសើរក្នុងការបើកប្រទេស និងស្តារសេដ្ឋកិច្ចឡើងវិញ ។

ជាមួយគ្នានោះដែរ សម្តេចតេជោនាយករដ្ឋមន្ត្រី បានរម្លឹកប្រាប់ ឯកឧត្តម **ដុ វ៉ាន់ចៀន** ស្តីពីដំណើរការឆ្លងកាត់ដ៏វែង



រូបថតអនុស្សាវរីយ៍





សម្តេចវិបុលសេនាភក្តី សាយ ឈុំ អនុញ្ញាតឱ្យឯកឧត្តម ដុ វ៉ាន់ចៀន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ

ឆ្ងាយដែលបក្សរណសិរ្សទាំងពីរបានឆ្លងកាត់ជាមួយគ្នាទៅវិញទៅមកពិសេសសម្តេចបានរម្លឹកពីដំណើរតស៊ូរបស់សម្តេច និងការជួយឧបត្ថម្ភរបស់មិត្តវៀតណាមក្នុងការជួយរំដោះប្រទេសកម្ពុជា ហើយទប់ស្កាត់ការវិលត្រឡប់របស់របបខ្មែរក្រហមនិងការជួយជាបន្តបន្ទាប់ ។ នៅក្នុងឆ្នាំខាងមុខនេះ ឆ្នាំក្រោយនេះជាខួបទី ៤៥ ឆ្នាំនៃការបង្កើតកងទ័ពកម្ពុជា សម្តេចតេជោនាយករដ្ឋមន្ត្រី និងក្រសួងពាក់ព័ន្ធនិងរៀបចំឱ្យមានការធ្វើមាតុភូមិនិវត្តន៍អដ្ឋិធាតុយុទ្ធជនកម្ពុជាចំនួន ៤៩ ដែលនៅសេសសល់បានវិលត្រឡប់ មកកាន់មាតុភូមិកម្ពុជាវិញ ។

សម្តេចតេជោ ក៏បានសម្តែងនូវការពេញចិត្ត ចំពោះស្ថិរភាពនៃទំនាក់ទំនងប្រទេសទាំងពីរ ជាពិសេសការសម្រេចបាន នូវការបោះបង្គោលព្រំដែនបានចំនួន ៨៤ភាគរយ ហើយក៏បានឯកភាពគ្នាបន្តការបោះបង្គោលព្រំដែនដែលនូវសេសសល់ចំនួន ១៦ភាគរយ ទៀតឱ្យបានឆាប់រហ័ស ដើម្បីប្រែក្លាយប្រទេសទាំងពីរឱ្យមានសុខសន្តិភាពនិងព្រំដែនស្ថិរភាព បង្កលក្ខណៈងាយស្រួលដល់ប្រជាជននៃប្រទេសទាំងពីរក្នុងការទៅមករកគ្នា ។

សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានអបអរសាទរចំពោះវៀតណាមផងដែរ ដែលបានគ្រប់គ្រងល្អនូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមកដល់ពេលនេះចំនួនអ្នកឆ្លងក្នុងប្រទេសវៀតណាមបានថយចុះគួរឱ្យកត់សម្គាល់និងអបអរសាទរចំពោះភាគីវៀតណាមដែលបានរៀបចំចាត់តាំងកីឡាស៊ីហ្គេមបានល្អប្រសើរ ដែលផ្តល់ឱកាសឱ្យកម្ពុជាទទួលបានមេដាយច្រើននិងទទួលបានបទពិសោធន៍សម្រាប់ការរៀបចំកីឡាស៊ីហ្គេមនៅឆ្នាំ ២០២៣ ខាងមុខនេះ ។ សម្តេចតេជោបានសម្តែងសេចក្តីសង្ឃឹមថា ទស្សនកិច្ចរបស់គណៈប្រតិភូវៀតណាមនៅពេលនេះគឺចំពេលដ៏ល្អដែលអាចឱ្យបំពេញការងារប្រាស្រ័យទាក់ទងបានយ៉ាងទូលំទូលាយ ។

ដោយឡែក កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២២ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យឯកឧត្តម **ដុ វ៉ានចៀន** គណៈលេខាមជ្ឈឹមបក្សកុម្មុយនីស្តវៀតណាម និងជាប្រធានគណៈកម្មាធិការមជ្ឈឹមបក្សរណសិរ្សមាតុវៀតណាម ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារនៅវិមានរដ្ឋសភា ។

ក្នុងជំនួបពិភាក្សា ឯកឧត្តម **ដុ វ៉ាន់ចៀន** បានជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភាជ្រាបថា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៥៥ នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា-វៀតណាម ឯកឧត្តមបានដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជានាពេលនេះ ក្នុងគោលបំណងដើម្បីពង្រឹងពង្រីកទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងរណសិរ្សនៃប្រទេសទាំងពីរ ដែលមានតួនាទីសំខាន់សម្រាប់ឃោសនាអប់រំអំពីសមិទ្ធផលរួមនៃប្រទេសទាំងពីរ សម្រាប់ទុកឱ្យកូនចៅជំនាន់ក្រោយបានស្វែងយល់ដឹង និងពូនជ្រុំបន្ថែមទៀតនាពេលអនាគត ។



សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ និងឯកឧត្ដម ដ៉ុ វ៉ាន់ចៀន

ឯកឧត្ដម **ដ៉ុ វ៉ាន់ចៀន** បានសម្ដែងនូវសេចក្ដីរីករាយដោយមើលឃើញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែល្អប្រសើរ ។ ឯកឧត្ដមមានជំនឿជឿជាក់ថា ប្រទេសទាំងពីរខិតខំប្រឹងប្រែងកសាងខ្សែបន្ទាត់ព្រំដែនប្រកបដោយការអភិវឌ្ឍនិងមានកិច្ចសហប្រតិបត្តិការល្អប្រពៃ ។ ក្នុងសម័យកាលដែលមានសន្តិភាព ប្រទេសទាំងពីរនឹងបន្តពង្រឹងពង្រីកទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការល្អនេះឱ្យបានកាន់តែរឹងមាំបន្តបន្ទាប់ថែមទៀត ។ រណសិរ្សមាតុភូមិវៀតណាមនិងខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីបង្កើនកិច្ចសហការល្អជាមួយនឹងប្រជាជននិងថ្នាក់ដឹកនាំកម្ពុជា ។

សម្ដេចប្រធានព្រឹទ្ធសភា បានវាយតម្លៃខ្ពស់ចំពោះដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ នៅព្រះរាជាណាចក្រកម្ពុជា ស្របពេលដែលប្រទេសទាំងពីរ ប្រារព្ធខួបអនុស្សាវរីយ៍លើកទី៥៥នៃការបង្កើតទំនាក់ទំនងការទូត និងជាឆ្នាំមិត្តភាពកម្ពុជា-វៀតណាម ។ ប្រទេសទាំងពីរបានរៀបចំកម្មវិធីសកម្មភាពជាច្រើន ដើម្បីអបអរសាទរឆ្នាំជាប្រវត្តិសាស្ត្រនេះ រួមមានការផ្លាស់ប្ដូរដំណើរទស្សនកិច្ចរវាងថ្នាក់ដឹកនាំមន្ត្រីតាមក្រសួង ស្ថាប័ននានា ក៏ដូចជាមន្ត្រីនៅតាមមូលដ្ឋានផងដែរ ។ ក្នុងរយៈពេល ៥៥ឆ្នាំ កន្លងទៅនេះ ប្រជាជននៃប្រទេសទាំងពីរ បានឆ្លងកាត់នូវដំណាក់កាលជាប្រវត្តិសាស្ត្រជាច្រើន ដោយបានជួយគាំទ្រគ្នាទៅវិញទៅមក ដើម្បីបុព្វហេតុឯករាជ្យ អធិបតេយ្យភាព បូរណភាពនិងការអភិវឌ្ឍ ។ ប្រទេសទាំងពីរត្រូវតែខិតខំពង្រឹងពង្រីកទំនាក់ទំនងមិត្តភាពសាមគ្គីភាពនិងកិច្ចសហប្រតិបត្តិការនេះឱ្យកាន់តែរឹងមាំខ្លាំងក្លាថែមទៀត ដើម្បីទុកជាមរតកសម្រាប់កូនចៅទាំងជំនាន់នេះនិងជំនាន់ក្រោយទៀត ។

សម្ដេចប្រធានព្រឹទ្ធសភាបានវាយតម្លៃខ្ពស់និងមានសេចក្ដីពេញចិត្តជាខ្លាំងចំពោះចំណងមិត្តភាព សាមគ្គីភាពនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសនិងប្រជាជនទាំងពីរ ដែលបន្តរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែស៊ីជម្រៅមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងរឹងមាំយូរអង្វែង ។ ជាមួយគ្នានេះ សម្ដេចបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងរណសិរ្សនៃប្រទេសទាំងពីរ ដែលបានរួមចំណែកដ៏ខ្លាំងក្លាក្នុងការឃោសនាអប់រំអំពីសមិទ្ធផលជូនប្រជាជននៃប្រទេសទាំងពីរក៏ដូចជាការរួមចំណែកដ៏ខ្លាំងក្លាក្នុងការពង្រឹងពង្រីកទំនាក់ទំនង សាមគ្គីភាពនិងសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងគ្រប់ស្ថានភាពនិងគ្រប់កាលៈទេសៈ ។

សម្ដេចប្រធានព្រឹទ្ធសភាបានគូសបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជាមានទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការល្អជាមួយនិងរដ្ឋសភាវៀតណាម ទាំងក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងនៅលើឆាកអន្តរជាតិ ដូចជា នៅក្របខ័ណ្ឌ IPU , AIPA , APF , APPF និង CLV ជាដើម ។

ក្នុងនាមប្រជាជនកម្ពុជា សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការដឹងគុណចំពោះកងទ័ពប្រជាជន និងបក្សកុម្មុយនីស្តវៀតណាម ដែលតែងតែជួយគាំទ្រដល់បុព្វហេតុដ៏ត្រឹមត្រូវយុត្តិធម៌របស់ប្រជាជនកម្ពុជាក្នុងគ្រប់ដំណាក់កាលទាំងអស់ ។

តាមរយៈគណប្រតិភូ សម្ដេចប្រធានព្រឹទ្ធសភាបានផ្ដាំផ្ញើសួរសុខទុក្ខដោយសេចក្ដីនឹករលឹកនិងសេចក្ដីគោរពស្រឡាញ់ដ៏ស្មោះស្ម័គ្រជូនឯកឧត្ដមប្រធានរដ្ឋសភាវៀតណាមនិងថ្នាក់ដឹកនាំជាន់ខ្ពស់វៀតណាមទាំងអស់ ។

សម្ដេចប្រធានព្រឹទ្ធសភាគូសបញ្ជាក់ថា ប្រទេសកម្ពុជាចាត់ទុកវៀតណាមគឺជាមិត្តល្អ ជាបងប្អូនល្អ ជាអ្នកជិតខាងល្អនិងជាដៃគូល្អ តាមពាក្យស្លោក " ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណីកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង " ៕



រូបថតអនុស្សាវរីយ៍



# កម្ពុជា កំពុងព្យាយាមចូលរួមជាមួយអង្គការសហប្រជាជាតិ គាំទ្រសន្តិភាព និងសន្តិសុខអន្តរជាតិ លើកកម្ពស់លើគោលការណ៍ គុណតម្លៃជាមូលដ្ឋាននៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ

*អត្ថបទ ៖ យូ សំបូរ, រូបថត ៖ អន យួនសំអូន*



«ក្នុងនាមជាប្រទេសមួយ ដែលទទួលបានបទពិសោធន៍ក្នុងការរកបាននូវសន្តិភាពដោយលំបាកក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន កម្ពុជាបាននឹងកំពុងព្យាយាមចូលរួមប្រកបដោយការស្ថាបនា ជាមួយអង្គការសហប្រជាជាតិ គាំទ្រនូវសន្តិភាព និងសន្តិសុខអន្តរជាតិ ព្រមទាំងលើកកម្ពស់ការគោរពលើគោលការណ៍ និងគុណតម្លៃជាមូលដ្ឋាននៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងច្បាប់ អន្តរជាតិ។» នេះជាសេចក្តីថ្លែងការណ៍របស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណា



សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមសម័យប្រជុំលើកទី ៧៧ នៃកិច្ចពិភាក្សាទូទៅ
របស់មហាសន្និបាតអង្គការសហប្រជាជាតិ









ចក្រកម្ពុជា ថ្លែងក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៧៧ នៅទីក្រុងញូវយ៉ក ថ្ងៃទី២១-២៣ ខែកញ្ញា ឆ្នាំ២០២២ ក្រោមប្រធានបទ "ចំណុចរបត់ សំខាន់ នៃការផ្លាស់ប្តូរមិនអាចត្រឡប់ក្រោយបាន៖ ដំណោះស្រាយបរិវត្តកម្មចំពោះបញ្ហាប្រឈមប្រទាក់ក្រឡាគ្នា"។

សម្តេចតេជោបានគូសបញ្ជាក់ថា ភាពមិនប្រាកដប្រជាជាសកលកាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ តាមរយៈការកើនឡើងនូវភាពតានតឹងនៃជម្លោះប្រដាប់អាវុធ ការប្រណាំងប្រជែងសព្វាវុធ ការកើនឡើងនៃសម្ព័ន្ធភាពសន្តិសុខខ្នាតតូច សង្គ្រាមបច្ចេកវិទ្យា និងពាណិជ្ជកម្ម ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងការគំរាមកំហែងកាន់តែខ្លាំងឡើងចំពោះពហុភាគីនិយម ជាក់ស្តែងសង្គ្រាមនៅអ៊ុយក្រែន បានបង្កភាពស្មុគស្មាញមិនត្រឹមតែចំពោះទំនាក់ទំនងអន្តរជាតិនៅតំបន់អឺរ៉ុបប៉ុណ្ណោះទេ ប៉ុន្តែបានបន្ទុចបង្អាក់សកម្មភាពសេដ្ឋកិច្ចធ្វើឱ្យបញ្ហាសន្តិសុខស្បៀង និងថាមពលកាន់តែយ៉ាប់យ៉ឺន ការកើនឡើងនៃអរិភាពរវាងតួអង្គកាន់តែច្រើនឡើងៗ ដោយផ្ទាល់ ឬដោយប្រយោល និងគ្មានសញ្ញានៃការបញ្ចប់ រួមទាំងការគំរាមកំហែងនៃសង្គ្រាមនុយក្លេអ៊ែរ បានជះឥទ្ធិពលធ្ងន់ធ្ងរដល់ពិភពលោក ស្ថានការណ៍នៅឧបទ្វីបកូរ៉េនៅតែជាក្តីព្រួយបារម្ភ ដោយសារការត្រៀមសាកល្បងអាវុធនុយក្លេអ៊ែរលើកទី៧។ ក្នុងឆ្នាំនេះកូរ៉េខាងជើងបានបាញ់បង្ហោះកាំជ្រួចមីស៊ីលផ្លោងរាប់សិបគ្រាប់ឆ្លើយតបនឹងសមយុទ្ធយោធា។ ភាពតានតឹងរវាងសហរដ្ឋអាមេរិក និងចិន ជុំវិញបញ្ហាតៃវ៉ាន់ក៏បង្កការព្រួយបារម្ភផងដែរ។

សម្តេចតេជោបានបន្តថា ការជួបជុំគ្នាពេលនេះបានឆ្លុះ







សម្ដេចតេជោ ហ៊ុន សែន អញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋគុយបា

បញ្ជាំងពីភាពជោគជ័យគួរឱ្យកត់សម្គាល់ នៃកិច្ចខិតខំប្រឹងប្រែងរួមរបស់យើងក្នុងការយកឈ្នះនូវជំងឺរាតត្បាត ប៉ុន្តែការប្រយុទ្ធប្រឆាំងនឹងវិបត្តិសុខភាពសកលនេះនៅពុំទាន់បញ្ចប់នៅឡើយ។ ទម្រង់ថ្មីៗវីរុសបំប្លែងខ្លួននិងជំងឺឆ្លងផ្សេងៗកំពុងតែលេចឡើងជាបន្តបន្ទាប់ ។ តើនឹងមានអ្វីផ្សេងទៀត ដែលអាចនឹងកើតមានឡើងនាពេលអនាគត? ប្រព័ន្ធសុខាភិបាលសកលមួយដ៏រឹងមាំ ជាពិសេសអង្គការសុខភាពពិភពលោក (WHO) ដែលមានតួនាទីស្នូលក្នុងការសម្របសម្រួលអាចជួយកសាងប្រព័ន្ធសុខាភិបាលជាតិមួយកាន់តែមានភាពធន់ និងនិរន្តរភាព។ ការចែកចាយវ៉ាក់សាំង ឈរលើយន្តការពហុភាគី ប្រកបដោយការបើកចំហ និងតម្លាភាព ជំរុញគោលការណ៍ទទួលខុសត្រូវរួមពិតប្រាកដ គឺជាមធ្យោបាយតែមួយគត់សម្រាប់ទប់ស្កាត់ជំងឺរាតត្បាតផ្សេងៗនាអនាគត រួមទាំងការចែករំលែកបទពិសោធន៍ និងឧត្តមានុវត្តន៍ ព្រមទាំងការផ្ទេរបច្ចេកវិទ្យា ក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍វ៉ាក់សាំង។

ការគំរាមកំហែងចំពោះមនុស្សជាតិ គឺភាពងាយរងគ្រោះរបស់យើង នៃការប្រែប្រួលអាកាសធាតុ។ យើងចាំបាច់ត្រូវផ្លាស់ប្តូរដំណើរការដោះស្រាយបញ្ហាអាកាសធាតុនាពេលនេះ ដោយមិនអាចរង់ចាំថ្ងៃស្អែកបាននោះទេ។ អស់រយៈពេល៥០ឆ្នាំមកហើយចាប់តាំងពីរដ្ឋាភិបាលត្រូវបានទទួលការព្រមានពីការផ្លាស់ប្តូរទម្រង់ផលិតកម្ម និងការប្រើប្រាស់របស់យើង ដើម្បីចៀសវាងគ្រោះមហន្តរាយនេះ ។ ប៉ុន្តែជាអកុសលចាប់តាំងពីពេលនោះមកយើងឃើញតែការបាត់បង់ជីវចម្រុះកាន់តែច្រើន ការរេចរឹលដីកាន់តែច្រើន និងការខ្វះខាតទឹកសាបកាន់តែកើនឡើង ។ សកម្មភាពរួមរបស់យើងត្រូវតែផ្តោតលើកិច្ចខិតខំប្រឹងប្រែងជាសកលកបញ្ចៀសផលប៉ះពាល់ ដើម្បីលើកកម្ពស់ការអភិវឌ្ឍ ដែលមានភាពធន់នឹងអាកាសធាតុ។ ការប្តេជ្ញាចិត្តរបស់យើងទាញសីតុណ្ហភាពពិភពលោកឱ្យថយ








សម្ដេចតេជោ ហ៊ុន សែន អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ
នៅវិមានអនុស្សាវរីយ៍ ចូហ្សេម៉ាទី ( José Marti ) ប្រទេសគុយបា

១,៥អង្សាសេ ទាមទារការផ្ដល់ហិរញ្ញប្បទាន និងការផ្ទេរបច្ចេកវិទ្យា ដើម្បីសម្រួលដល់ការផ្លាស់ប្ដូរប្រកបដោយអត្ថន័យក្នុងកិច្ចខិតខំប្រឹងប្រែងបញ្ចៀស និងសម្របខ្លួន។ យើងត្រូវតែអនុវត្តនូវលទ្ធផលនៃកិច្ចប្រជុំនៅក្នុងទីក្រុង Glasgow ដែលបានអនុម័ត COP២៦ ដោយយកចិត្តទុកដាក់ជាបន្ទាន់ និងឈរលើគោលការណ៍រួម ប៉ុន្តែបែងចែកការទទួលខុសត្រូវ និងតាមសមត្ថភាពរៀងៗខ្លួន។

ការគំរាមកំហែងបែងចែកប៉ូលពាណិជ្ជកម្ម និងសេដ្ឋកិច្ច កើតចេញពីការប្រជែងគ្នារវាងសហរដ្ឋអាមេរិក និងចិន ប្រាកដណាស់នឹងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចសកល អាស្រ័យហេតុនេះការផ្លាស់ប្ដូរជាមូលដ្ឋានទៅមុខនៃដំណើរការសង្គម-សេដ្ឋកិច្ច និងនយោបាយ គឺត្រូវពង្រឹងប្រព័ន្ធពាណិជ្ជកម្មពហុភាគីផ្អែកលើវិធានច្បាប់ ដោយមានអង្គការពាណិជ្ជកម្មពិភពលោកជាអង្គការស្នូលអាចលើកកម្ពស់ពាណិជ្ជកម្មអន្តរជាតិ បើកចំហកាត់បន្ថយរបាំងពាណិជ្ជកម្ម និងធានាភាពធន់នៃខ្សែច្រវាក់តម្លៃតំបន់និងសកល។ យើងត្រូវយកចិត្តទុកដាក់កាន់តែខ្លាំងលើគោលនយោបាយឌីជីថលប្រកបដោយបរិយាប័ន្ន និងក្របខ័ណ្ឌបទប្បញ្ញត្តិអំណោយផល ដែលនាំទៅរកការវិនិយោគកាន់តែច្រើននៅក្នុងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ព្រោះវាមានសារៈសំខាន់សម្រាប់តភ្ជាប់



សម្ដេចតេជោ ហ៊ុន សែន ជួបពិភាក្សាទ្វេភាគីពង្រឹងចំណងមិត្តភាពកិច្ចសហប្រតិបត្តិការ កម្ពុជា - គុយបា



គម្លាតឌីជីថលដែលកំពុងកើនឡើង និងបង្កើតប្រភពនៃកំណើនថ្មី។ ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ជាផ្នែកមួយមិនអាចខ្វះបានក្នុងការគាំទ្រការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព តាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការ កសាងហេដ្ឋារចនាសម្ព័ន្ធបៃតង ជំរុញអន្តរកាលថាមពល និងការប្រើប្រាស់បច្ចេកវិទ្យាបៃតង។

ឆ្នាំនេះកម្ពុជាមានកិត្តិយសធ្វើជាប្រធានអាស៊ាន មកដល់បច្ចុប្បន្នអង្គការនេះមានអាយុ៥៥ឆ្នាំ ហើយយើងមានមោទនភាពអបអរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្ររបស់យើង និងសមិទ្ធផលដ៏គួរឱ្យកត់សម្គាល់ ដែលយើងសម្រេចបានជាបន្តបន្ទាប់។ ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ អាស៊ានអាចមានលទ្ធភាពធ្វើដំណើរឆ្លងកាត់សភាពការណ៍ភូមិសាស្ត្រនយោបាយ ដែលមានការផ្លាស់ប្តូរឥតឈប់ឈរក្លាយជាអង្គការតំបន់ដ៏លេចធ្លោ និងជោគជ័យបំផុត ខណៈដែលមានការបោះជំហានយ៉ាងខ្លាំង ជំរុញភាពជឿទុកចិត្តបាន និងភាពពាក់ព័ន្ធក្នុងកិច្ចការពិភពលោក។

ប្រធានបទរបស់យើង "អាស៊ានរួមគ្នាធ្វើ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា" បង្ហាញពីស្មារតីរឹងមាំនៃការរួបរួមគ្នាគ្របដណ្តប់លើបញ្ហាចម្រូងៗទាំងអស់ ។ ជាការពិតបញ្ហាប្រឈមទាំងនេះមានផលប៉ះពាល់យ៉ាងទូលំទូលាយលើដំណើរការកសាងសហគមន៍អាស៊ាន និងទំនាក់ទំនងខាងក្រៅរបស់យើង។ ប៉ុន្តែក្នុងនាមជាប្រធានអាស៊ាន កម្ពុជាបានប្តេជ្ញាចិត្តក្នុងការប្រេបាច់បញ្ចូលកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីដោះស្រាយនូវគោលដៅរួម នាំមកនូវផលប្រយោជន៍ដល់ប្រជាជនរបស់យើង ផ្អែកលើស្មារតីនៃមជ្ឈភាព ឯកភាព និងសាមគ្គីភាពអាស៊ាន។ ពិតណាស់ស្ថានភាពនៅក្នុងប្រទេសមីយ៉ាន់ម៉ា មានសភាពគួរឱ្យព្រួយបារម្ភ ដែលអាចបង្កជាផលប៉ះពាល់ដោយផ្ទាល់ទៅលើសន្តិសុខ និងស្ថិរភាពនៃតំបន់ទាំងមូល ប៉ុន្តែយើងត្រូវតែទទួលស្គាល់ថា វិបត្តិនេះគឺស្មុគស្មាញ ជាមួយនឹងមូលហេតុដែលចាក់ឫសយ៉ាងជ្រៅ។ ក្នុងនាមជាប្រធានអាស៊ាន កម្ពុជាប្តេជ្ញាយ៉ាងពេញទំហឹងក្នុងការជួយមីយ៉ាន់ម៉ាដោះស្រាយវិបត្តិ ហើយកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអស់ គឺសំដៅស្វែងរកការបញ្ចប់អំពើហិង្សា នាំមកនូវជំនួយមនុស្សធម៌ដល់ប្រជាជនខ្វះខាត និងស្វែងរកការកសាងទំនុកចិត្តក្នុងចំណោមគ្រប់ភាគីពាក់ព័ន្ធ សំដៅបើកឱ្យមានការសន្ទនានយោបាយរួមមួយដូចដែលបានកំណត់ដោយកិច្ចព្រមព្រៀងជាឯកច្ឆន្ទទាំង៥ចំណុចរបស់អាស៊ាន។



សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមក្នុងពិធីបុណ្យសព ឯកឧត្តម អាបេ ស៊ីនហ្សូ អតីតនាយករដ្ឋមន្ត្រីជប៉ុន



ជាងពីរឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងប្រកបដោយភាពបុរេសកម្ម ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ តាមរយៈការដាក់ចេញនូវវិធានការសុខាភិបាល អន្តរាគមន៍សង្គម និងសេដ្ឋកិច្ច និងវិធានការរដ្ឋបាលនានា។ រាជរដ្ឋាភិបាលបានកំណត់ការចាក់វ៉ាក់សាំងកូវីដ-១៩ ជាវិធានការយុទ្ធសាស្ត្រជាគន្លឹះ ជាលទ្ធផល កម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេស ដែលមានអត្រាគ្របដណ្តប់នៃចំនួនប្រជាជនទទួលបានវ៉ាក់សាំងជំងឺកូវីដ-១៩ ខ្ពស់ជាងគេក្នុងកម្រិតសកល ជាពិសេសការសម្រេចបាននូវ "ភាពសាំសហគមន៍" ដ៏រឹងមាំនិងអាចបើកដំណើរការប្រទេសឡើងវិញបានពេញលេញនៅចុងឆ្នាំ២០២១ ក៏ដូចជាការស្តារឡើងវិញ នូវសកម្មភាព សង្គម - សេដ្ឋកិច្ចទាំងអស់ក្នុងគន្លងប្រក្រតីភាពថ្មីផងដែរ។

ក្នុងឱកាសនោះ សម្តេចតេជោបានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ចំពោះប្រទេសជាមិត្តទាំងអស់ បានផ្តល់វ៉ាក់សាំងកូវីដ-១៩ ដល់កម្ពុជាតាមរយៈក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី។ សម្រាប់វិស័យសង្គម រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ដូចជាទីភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីដាក់ឱ្យអនុវត្ត និងពង្រីកកម្មវិធីសំខាន់ៗមួយចំនួន ដូចជា ១-កម្មវិធីសាច់ប្រាក់ពលកម្ម ក្នុងគោលបំណងកែលម្អហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងការផ្តល់ឱកាសការងារបន្ថែម និង ២- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ដើម្បីជួយសម្រាលការលំបាក និងរក្សាជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ។ ចំពោះវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជា



ពិធីបុណ្យសព ឯកឧត្តម អាបេ ស៊ីនហ្សូ អតីតនាយករដ្ឋមន្ត្រីជប៉ុន

បានខិតខំព្យាយាមឥតស្រាកស្រាន្ត ដើម្បីដោះស្រាយបញ្ហាជារចនាសម្ព័ន្ធរាំរ៉ៃ ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច។ ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជាបានដោះស្រាយបញ្ហាប្រឈមជាច្រើន ដែលអាជីវកម្មបានជួបប្រទះតាមរយៈការអនុវត្តច្បាប់ស្តីពីវិនិយោគថ្មី ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជននិងការអនុម័តលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដូចជា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-សាធារណរដ្ឋកូរ៉េ និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់។ ជារួមសេដ្ឋកិច្ចកម្ពុជាត្រូវ បានវាយតម្លៃថានឹងសម្រេចបានក្នុងអត្រាកំណើន ៥,៤%ក្នុងឆ្នាំ២០២២ គាំទ្រដោយការងើបឡើងវិញយ៉ាងខ្លាំងនៃវិស័យកម្មន្តសាល ទេសចរណ៍និងកសិកម្ម។ ចំពោះកិច្ចដំណើរការលទ្ធិប្រជាធិបតេយ្យវិញការបោះឆ្នោតឃុំ-សង្កាត់ ដែលបានរៀបចំឡើងកាលពីខែមិថុនាកន្លងទៅ ឆ្លុះបញ្ចាំងនូវកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរ។ ជាង៨០%នៃអ្នកចុះឈ្មោះបោះឆ្នោត បានទៅបោះឆ្នោតប្រកបដោយភាពសេរី យុត្តិធម៌ សន្តិភាព និងតម្លាភាព។ ការកោតសរសើរ និងគាំទ្រយ៉ាងពេញទំហឹងរបស់ប្រជាជនកម្ពុជា លើកិច្ចខិតខំ ប្រឹងប្រែងឥតស្រាកស្រាន្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរក្សាសន្តិភាព ស្ថិរភាព នយោបាយ កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ប្រកបដោយភាពជោគជ័យ បានជំរុញឱ្យមានការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តជូនគណបក្សកាន់អំណាចយ៉ាងលើសលប់។ ទាក់ទងនឹងបេសកកម្មរក្សាសន្តិភាព កម្ពុជាបានបន្តបញ្ជូនកងកម្លាំងរាប់ពាន់នាក់ ដើម្បីទៅបំពេញបេសកកម្មក្នុងបណ្តាប្រទេសដែលកំពុងជួបវិបត្តិ។ ជាង១៥%នៃកងកម្លាំងកម្ពុជាដែលចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហ ប្រជាជាតិគឺជា"ស្ត្រី"។ ពួកគាត់បានដើរតួជាគំរូ និងជំរុញទឹកចិត្តដល់ស្ត្រី និងយុវនារី ក្នុងសង្គមដែលគ្របដណ្តប់ដោយបុរស ដើម្បីទាមទារសិទ្ធិ និងចូលរួមចំណែកក្នុងកិច្ចដំណើរការរក្សាសន្តិភាព ។ ទាក់ទងនឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ។

អង្គជំនុំជម្រះកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសាលដីការតម្កល់ការផ្តន្ទាទោសអស់មួយជីវិតដល់អតីតប្រមុខរដ្ឋខ្មែរក្រហមពីបទប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ



សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមក្នុងពិធីបុណ្យសព ឯកឧត្តម អាបេ ស៊ីនហ្សូ អតីតនាយករដ្ឋមន្ត្រីជប៉ុន

លើអនុសញ្ញាទីក្រុងហ្សឺណែវ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ បានបង្ហាញពីកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងកម្ពុជា និង អង្គការសហប្រជាជាតិ តាមរយៈសាលាក្តីកូនកាត់នាំមកនូវ យុត្តិធម៌ដល់ប្រជាជនកម្ពុជា ដែលបានរងគ្រោះយ៉ាងធ្ងន់ធ្ងរពី ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជនជាតិឯង យើងអាចប្រកាស ប្រាប់ពិភពលោកអំពីការពិតដែលបានរកឃើញ និងយុត្តិធម៌ ត្រូវបានការពារ ហើយផ្សព្វផ្សាយដល់ពិភពលោកថា ឧក្រិដ្ឋកម្ម បែបនេះមិនគួរកើតឡើងម្តងទៀតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ឡើយ។ សម្តេចតេជោបានថ្លែងអំណរគុណចំពោះប្រទេស ផ្តល់ជំនួយទាំងឡាយ បានផ្តល់ថវិកាគាំទ្រ និងថ្លែងអរគុណ ចំពោះជនរួមជាតិកម្ពុជាទាំងអស់នូវការសហការពង្រឹងដំណើរ ការផ្សះផ្សាជាតិ។ ទោះបីជាមានបញ្ហាប្រឈមជាច្រើនអនេក បានជះឥទ្ធិពលអវិជ្ជមានដល់វឌ្ឍនភាពនយោបាយ សង្គម និង សេដ្ឋកិច្ចក្តីយើងទាំងអស់គ្នានៅតែបន្តប្តេជ្ញាចិត្តជានិច្ចសម្រេច ឱ្យបាននូវរបៀបវារៈឆ្នាំ២០៣០សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាព។

នៅថ្ងៃទី២៣ដល់ទី២៥ សម្តេចតេជោ **ហ៊ុន សែន** បាន អញ្ជើញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋគុយបា ជំនួបទ្វេភាគី ជាមួយឯកឧត្តមប្រធានាធិបតី **មីហ្គែល ឌីយ៉ាសកាណែល ប៊ឺមូដេស** ដើម្បីពង្រឹងចំណងមិត្តភាពរវាងកម្ពុជា និងគុយបា ពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗ។ សម្តេចតេជោ



**ហ៊ុន សែន** បានមានប្រសាសន៍ថា ក្នុងរយៈពេល ៦២ឆ្នាំ នៃ ទំនាក់ទំនងរវាង កម្ពុជា និងគុយបា សម្តេចបានរួមចំណែក ពង្រឹងពង្រីកទំនាក់ទំនងនេះអស់រយៈពេល៤៣ឆ្នាំ (១៩៧៩-២០២២) គឺស្មើង២/៣ នៃការធ្វើដំណើរទាំងមូល។ ទស្សនកិច្ច ចុងក្រោយរបស់សម្តេចតេជោបានធ្វើឡើងនៅឆ្នាំ២០០០។ ២២ឆ្នាំក្រោយ សម្តេចតេជោបានធ្វើទស្សនកិច្ចសាជាថ្មីម្តង ទៀតក្នុងគោលបំណងពង្រឹងចំណងមិត្តភាពដែលមានស្រាប់ ឱ្យកាន់តែរឹងមាំថែមទៀត។ សូមអរគុណប្រជាជនគុយបាដែល បានជួយដល់ប្រជាជនកម្ពុជាក្នុងពេលដែលយើងជួបការលំបាក បំផុត ក្រោយការដួលរលំរបបប្រល័យពូជសាសន៍ប៉ុល ពត។ ជួយគ្នាក្នុងគ្រាក្រស្គាល់មិត្តល្អក្នុងគ្រាលំបាក។

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំ

គណប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញចូលរួមបុណ្យសពថ្នាក់ជាតិរបស់ ឯកឧត្តម **អាបេ ស៊ិនហ្សូ** អតីតនាយករដ្ឋមន្ត្រីជប៉ុន ដែលពិធីបុណ្យសពថ្នាក់ជាតិនេះបានរៀបចំឡើងនៅសាល Nippon Budokan តាមបែបបទប្រពៃណី និងសាសនាជប៉ុន  និងបានផ្តល់មហាកិត្តិយសពីប្រេសិតរបស់ព្រះចៅអធិរាជ និងព្រះរាជអគ្គមហេសី និងអតីតព្រះចៅអធិរាជ និងព្រះរាជអគ្គមហេសី រួមនឹងការថ្វាយកម្រងផ្កាពីសមាជិកព្រះរាជវង្សានុវង្សជប៉ុន មានការចូលរួមពីថ្នាក់ដឹកនាំជាប្រមុខរដ្ឋ រដ្ឋាភិបាល អតីតមេដឹកនាំពិភពលោកប្រមាណ ៥០រូប និងភ្ញៀវកិត្តិយសអន្តរជាតិប្រមាណ ៧០០នាក់ និងភ្ញៀវជាតិសរុបទាំងអស់ប្រមាណ ៤ ៥០០នាក់ បានអញ្ជើញមកចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីបុណ្យសពថ្នាក់ជាតិដើម្បីលាគ្នាជាលើកចុងក្រោយ។ ចំពោះស្នាដៃនិងការចងចាំឯកឧត្តម **អាបេ** ជាអ្នកនយោបាយអភិរក្សនិយម ដែលត្រូវបានគេចងចាំចំពោះសមិទ្ធផល គោលនយោបាយជាច្រើនទាំងក្នុង និងក្រៅប្រទេស ទាំងការដឹកនាំពិភពលោក និងទំនាក់ទំនងដ៏កក់ក្តៅ ដែលឯកឧត្តមបានកសាងជាមួយមេដឹកនាំពិភពលោក កាលពីអតីតកាល និងបច្ចុប្បន្ន។ លើសពីនោះឯកឧត្តម **អាបេ** ក៏ត្រូវបានគេចងចាំថា ជាបុគ្គលដែលខ្វាយខ្វល់អំពីសុខុមាលភាពប្រជាជន-កម្មករ ស្ថិរភាពសង្គម និងសន្តិសុខជាតិរបស់ជប៉ុនជាដរាប បើទោះឯកឧត្តមពុំមែនជានាយករដ្ឋមន្ត្រី ក្នុងពេលដែលជីវិតរបស់ឯកឧត្តមត្រូវបានគេលួចធ្វើឃាតក៏ដោយ ឯកឧត្តមនៅតែជាកម្លាំងនយោបាយដ៏សំខាន់មួយរូបនៅក្នុងប្រទេសជប៉ុន។ ប្រជាជនជប៉ុនភាគច្រើនដែលមកចូលរួមកាន់ទុក្ខឯកឧត្តម អាបេ គឺជាក្រុមយុវជនវ័យក្មេង ដែលទទួលបានការងារធ្វើដំបូង ដោយសារគោលនយោបាយសេដ្ឋកិច្ច ដែលមានឈ្មោះថា អាបេណូមិក (Abenomics)។ នៅក្នុងអំឡុងពេលនៃការកាន់តំណែងក្នុងអាណត្តិទី២ ចាប់ពីចុងឆ្នាំ២០១២ ដល់ខែកញ្ញា ឆ្នាំ២០២០ ក្នុងពេលជំងឺកូវីដ-១៩ កំពុងរាតត្បាត ជប៉ុនបានបង្កើតការងារថ្មីប្រមាណ ៥លានកន្លែង។

សម្តេចតេជោបានជួបសម្តែងការគួរសមជាមួយឯកឧត្តម **ហ្វូមីអូ គីស៊ីដា** នាយករដ្ឋមន្ត្រីជប៉ុន និងភរិយារបស់ឯកឧត្តម **អាបេ** បាននាំនូវព្រះរាជបន្ទូលព្រះមហាក្សត្រ និងព្រះមហាក្សត្រីចូលរួមរំលែកមរណទុក្ខជាមួយរដ្ឋាភិបាល និងក្រុមគ្រួសាររបស់ឯកឧត្តម **អាបេ** ។ សម្តេចតេជោ នាយករដ្ឋមន្ត្រីបានសម្តែងការសោកស្តាយដោយក្រៀមក្រំជាទីបំផុត បានគូសបញ្ជាក់ថា មរណភាពរបស់ឯកឧត្តម **អាបេ** គឺជាការបាត់បង់មិត្តភក្តិដ៏ល្អមួយរូបរបស់សម្តេច ក៏ដូចជាប្រជាជនកម្ពុជាទាំងមូល។ ឯកឧត្តម **អាបេ** ជាមេដឹកនាំមួយរូប ដែលមានគុណបំណាច់យ៉ាងធំធេងសម្រាប់កម្ពុជា  លើសពីនោះ ឯកឧត្តម **អាបេ** គឺជាមិត្តភ័ក្រដ៏ល្អពិតប្រាកដ និងជាអ្នកគាំទ្រដ៏ស្មោះត្រង់របស់កម្ពុជា ដែលបានរួមចំណែកយ៉ាងជ្រាលជ្រៅក្នុងការលើកកម្ពស់ទំនាក់ទំនងទ្វេភាគី និងគាំទ្រដល់ការអភិវឌ្ឍលើគ្រប់វិស័យនៅកម្ពុជា។ ឯកឧត្តម **អាបេ** គឺជាមិត្តជាទីស្រលាញ់រាប់អានដ៏យូរម្នាក់ ដែលបានរួមចំណែកពូនជ្រុំភាពជាដៃគូ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ ដើម្បីជាផលប្រយោជន៍ទៅវិញទៅមកនៃប្រទេស និងប្រជាជនយើងទាំងពីរ។ មរណភាពរបស់ឯកឧត្តម **អាបេ ស៊ីនហ្សូ** មិនគ្រាន់តែជាការបាត់បង់នូវរដ្ឋបុរសស្នេហាជាតិម្នាក់របស់ជប៉ុន ដែលបានដឹកនាំឱ្យមានការរីកចំរើន និងលើកកម្ពស់តួនាទីរបស់ជប៉ុននៅលើឆាកអន្តរជាតិ និងតំបន់ប៉ុណ្ណោះទេ តែជាការបាត់បង់មិត្តភក្តិដ៏ល្អពិតប្រាកដមួយរូបរបស់ប្រជាជនកម្ពុជា និងរូបសម្តេចផ្ទាល់ ដែលបានរួមចំណែកក្នុងការលើកកម្ពស់ទំនាក់ទំនងទ្វេភាគីកម្ពុជា ជប៉ុន រហូតដល់ភាពជាដៃគូយុទ្ធសាស្ត្រកាលពីឆ្នាំ២០១៣ ក៏ដូចជាបានជំរុញការផ្តល់ជំនួយគាំទ្រដល់ការអភិវឌ្ឍនៅកម្ពុជាផងដែរ។ កាយវិការដ៏សប្បុរស និងមនោសញ្ចេតនាស្មោះស្ម័គ្ររបស់ឯកឧត្តម **អាបេ ស៊ីនហ្សូ** នឹងត្រូវបានចងចាំដិតដាមជាប់ជានិច្ចក្នុងទឹកចិត្តរបស់ប្រជាជនកម្ពុជា ក៏ដូចជារូបសម្តេចជារៀងរហូត។ ក្នុងកាលៈទេសៈដ៏សែនសោកសង្រេងនេះ សម្តេចបានបួងសួងឱ្យវិញ្ញាណក្ខន្ធរបស់ឯកឧត្តម **អាបេ ស៊ីនហ្សូ** បានទៅសោយសុខក្នុងសុគតិភព កុំបីឃ្លាងឃ្លាតឡើយ។

សូមបញ្ជាក់ថា ឯកឧត្តម **អាបេ ស៊ីនហ្សូ** អតីតនាយករដ្ឋមន្ត្រីជប៉ុន បានទទួលមរណភាពកាលពីវេលាម៉ោង១៥ រសៀលថ្ងៃទី៨ កក្កដា ឆ្នាំ២០២២ បន្ទាប់ពីខ្មាន់កាំភ្លើងវ័យជាង ៤១ឆ្នាំម្នាក់ បានបាញ់ប្រហារមកលើឯកឧត្តម **អាបេ ស៊ីនហ្សូ** ក្នុងឱកាសដែលរូបឯកឧត្តមអញ្ជើញថ្លែងក្នុងយុទ្ធនាការឃោសនារកសម្លេងឆ្នោតជ្រើសរើសព្រឹទ្ធសភាជប៉ុន នៅទីក្រុងណារា ភាគខាងលិចប្រទេសជប៉ុន កាលពីវេលាម៉ោង១១ និង៣០នាទី ថ្ងៃទី ៨ កក្កដា ឆ្នាំ២០២២៕

# លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ផ្ដើមធ្វើបុណ្យកឋិនទាន ដង្ហែចូលវត្តព្រះឥន្ទកោសីយ៍ឃុំស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប

អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ ទា ផូលីន



ទិដ្ឋភាពវត្តព្រះឥន្ទកោសីយ៍កំពុងជួសជុល



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ព្រមទាំងថ្នាក់ដឹកនាំនិងពុទ្ធបរិស័ទជួបជុំពិធីសូត្រមន្ត



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន មានប្រសាសន៍សំណេះសំណាល



ពុទ្ធបរិស័ទជិតឆ្ងាយអញ្ជើញចូលរួម

បុណ្យកឋិនជាពិធីបុណ្យមួយដ៏ធំ ពិសេសជាងបុណ្យផ្សេងៗទៀតៗ គឺចាប់ធ្វើបន្ទាប់ពីបុណ្យចេញវស្សា ។ ពុទ្ធបរិស័ទជាប្រជាពលរដ្ឋខ្មែរជារឿយៗ តែងតែនាំគ្នាប្រារព្ធធ្វើបុណ្យកឋិនជារៀងរាល់ឆ្នាំ គឺចាប់ផ្ដើមពីថ្ងៃ ១រោច ខែអស្សុជ ទៅទល់នឹងថ្ងៃ ១៥កើត ពេញបូណ៌មី ខែកត្ដិក (ចន្លោះពីខែតុលានិងខែវិច្ឆិកា) ដែលមានរយៈពេល ២៩ថ្ងៃ ហើយមួយឆ្នាំធ្វើបានតែម្ដងប៉ុណ្ណោះ និងទទួលបានអានិសង្សបានទាំងសង្ខាងអ្នកធ្វើនិងអ្នកទទួល ។

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រួមជាមួយ ឯកឧត្តម លោកជំទាវ លោកជំទាវ ឧកញ៉ា មន្ត្រីរាជការ និងពុទ្ធបរិស័ទជិតឆ្ងាយបានឯកភាពគ្នាផ្ដើមធ្វើបុណ្យកឋិនទាន ដើម្បីនាំយកបច្ច័យចំនួន ១២១លានរៀល និង ៦ ០០០ដុល្លារ ទៅជួសជុលដំបូលព្រះវិហារ នៅវត្តព្រះឥន្ទកោសីយ៍ ស្ថិតនៅក្នុងភូមិទ្រាំង ឃុំស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ដែលអង្គកឋិនទាននេះបានប្រព្រឹត្តទៅនៅព្រឹកថ្ងៃពុធ ២រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ ។

លោកជំទាវកិត្តិសង្គហបណ្ឌិតបានមានប្រសាសន៍ថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំប្រទេសជាតិឆ្ពោះទៅរកសុខសន្តិភាព និងការអភិវឌ្ឍគ្រប់វិស័យ រួមទាំងវិស័យពុទ្ធចក្រ និងអាណាចក្រ ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋគ្រប់រូបអាចជួបជុំគ្នាធ្វើបុណ្យតាមបែបព្រះពុទ្ធសាសនា ។

នៅក្នុងពិធីអង្គកឋិនទាននេះដែរ លោកជំទាវកិត្តិសង្គហបណ្ឌិត បានប្រសិទ្ធពរជ័យដល់ពុទ្ធបរិស័ទដែលបានចូលរួមបច្ច័យតាមសទ្ធាជ្រះថ្លាក្នុងអង្គកឋិនទាននេះ ដើម្បីចូលរួម



សម្តេចព្រះវនរ័តកិត្តិបណ្ឌិត ណយ ច្រឹក សម្តេចព្រះសង្ឃនាយករងទី២ នៃព្រះរាជាណាចក្រកម្ពុជា

កសាងសមិទ្ធផលនានានៅវត្តព្រះឥន្ទកោសីយ៍ដើម្បីតម្កល់មហាកុសលផលបុណ្យទៅអនាគតជាតិពិសេសសូមឱ្យវត្ថុស័ក្តិសិទ្ធិក្នុងលោកតាមជួយថែរក្សាប្រមុខដឹកនាំប្រទេសនិងប្រជាជនខ្មែរទូទាំងប្រទេសជួបតែសេចក្តីសុខ សុខសន្តិភាព និងការអភិវឌ្ឍជានិច្ចនិរន្តរ៍ ។

សម្តេចព្រះវនរ័តកិត្តិបណ្ឌិត **ណយ ច្រឹក** សម្តេចព្រះសង្ឃនាយករងទី ២ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តច័ន្ទបុរីវង្សស្ថិតនៅសង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ បានមានព្រះបន្ទូលឱ្យដឹងថា កឋិនទានគឺជាបុណ្យមួយ បើគ្មានការចាំព្រះវស្សានោះទេ វត្តនោះមិនអាចទទួលអង្គកឋិនទានបានឡើយ ក៏គ្មានសិទ្ធិទទួលក្រាលគ្រងកឋិនទានបានដែរ ពោលគឺយ៉ាងហោចណាស់នៅក្នុងវត្តនីមួយៗ ត្រូវមានភិក្ខុសង្ឃមួយអង្គបានគង់ចាំព្រះវស្សារយៈពេល ៣ខែ ទើបមានអង្គកឋិនហែចូលវត្តនោះបាន ។





ជារៀងរាល់ឆ្នាំការធ្វើបុណ្យតាមរដូវកាល កំណត់មានរយៈពេល ២៩ ថ្ងៃ គឺចាប់ពីថ្ងៃ ១រោច ខែអស្សុជ រហូតដល់ថ្ងៃ ១៥ កើតពេញបូណ៌មី ខែកត្តិក ។ ចំពោះការប្រារព្ធធ្វើបុណ្យកឋិនឡើង គឺដើម្បីទទួលបាននៅអានិសង្សខ្ពង់ខ្ពស់បំផុត ពោលគឺអ្នកដែលបានកសាងកឋិននេះឡើងទទួលបានអានិសង្ស៥យ៉ាង ហើយព្រះសង្ឃទទួលក្រាលគ្រងក៏ទទួលបានអានិសង្ស៥យ៉ាងផងដែរ ។





លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ព្រមទាំងថ្នាក់ដឹកនាំនិងពុទ្ធបរិស័ទជិតឆ្ងាយក្នុងពិធីដង្ហែអង្គកឋិន



គ្រែកឋិន និងលំដាប់បរិក្ខា

តាមទំនៀមទម្លាប់ព្រះពុទ្ធសាសនាបានសម្តែង ថាបុគ្គលដែលបានកសាងកឋិនទានត្រឹមត្រូវ គឺអាចបិទនូវអបាយភូមិ ៤ មានប្រេត នរក អសុរកាយ និងតិរច្ឆាន មានន័យថា អ្នកកសាងទានចៀសផុតពីការកើតជា ប្រេត អសុរកាយ ហើយរមែងកើតទៅជាមនុស្សលោកឬទេវតា តែបើកើតជាមនុស្សលោករមែងកើតជាត្រកូលអ្នកមាន បើរូបគឺមានរូបស្អាតត្រចះត្រចង់ពណ្ណរាយណ៍ មានពណ៌សម្បុរដូចជាមាស មានទ្រង់ទ្រាយល្អប្រពៃ មានបញ្ញាវៀងវៃ អង់អាចក្លាហាន ឈ្លាសឆ្លាសប៉ិនប្រសប់ និងដល់អស់ព្រះជន្មក៏ទៅកើតជាស្តេចចក្រពត្រាធាធិរាជសោយក្នុងទ្វីបទាំង៤ មានទ្វីបតូចៗ ២ ០០០ ជាបរិវារនេះ ដោយអានិសង្សកឋិនដែលពុទ្ធបរិស័ទបានធ្វើ។

ដោយឡែក ពុទ្ធបរិស័ទដែល លោក អ្នកបានធ្វើដល់ព្រះសង្ឃដែលបានអនុមោទនាក្រាលគ្រងកឋិនហ្នឹង ក៏ទទួលបាននូវអានិសង្ស៥ដែរ។ បុណ្យកឋិនក៏មានន័យដែរថា គឺបានជួយសង្គ្រោះដល់ព្រះសង្ឃសម្រាប់បុណ្យហ្នឹង ពីព្រោះអ្នកបួសបានអំណាចអានិសង្សកឋិនបានជា លោក អ្នកប្រាជ្ញាឱ្យភិក្ខុសង្ឃហ្នឹងត្រូវបវរណាចូលព្រះវស្សាដើម្បីធ្វើសីលសម្មាធិបញ្ញា និងបានម៉ឺងម៉ាត់ម៉ត់ចត់ ហើយព្រះសង្ឃលោកសង្គ្រោះ មិនតែប៉ុណ្ណោះកឋិនហ្នឹងកើតឡើងដោយព្រះអង្គអនុញ្ញាតដល់ភិក្ខុ ៣០អង្គ នៅដែនបាថាយៈជាអ្នកប្រព្រឹត្តនៅក្នុងព្រៃប្រតិបត្តិបិណ្ឌបាតប្រព្រឹត្តប្រើប្រាស់ សំពត់ បង្សុកូល ដែលរឿងកឋិននេះមានប្រវត្តិយូរលង់ណាស់មកហើយ ពោលគឺមុនសម័យកាលព្រះពុទ្ធមកម្ល៉េះ។

ការធ្វើបុណ្យកឋិនទានសម័យបច្ចុប្បន្នតែងតែទទួលបាននូវអត្ថប្រយោជន៍និងផលប្រយោជន៍ទាំងផ្នែកអាណាចក្រនិងពុទ្ធចក្រផងដែរ។ ចំពោះផ្នែកព្រះធម៌និងទទួលបានអានិសង្សដ៏ធំច្រើនជាងអ្នកដទៃដើម្បីសន្សំទុកនៅជាតិខាងមុខផ្នែកមនុស្សលោកគឺមានកិត្តិយសសេចក្តីថ្លៃថ្នូរកេរ្តិ៍ឈ្មោះ ព្រោះមានឈ្មោះថាជាអ្នកបានចូលរួមចំណែកក្នុងការកសាងអភិវឌ្ឍន៍សង្គមជាតិ៕

# ក្រសួងព័ត៌មានរាយការណ៍ពីដំណើរការវិវឌ្ឍនៃវិស័យព័ត៌មាន និងសោតទស្សន៍នៅកម្ពុជា ជូនគណៈកម្មការទី៥ នៃព្រឹទ្ធសភា

*អត្ថបទ៖ ឌី ណារិន, រូបថត៖ ខឹម សុវណ្ណារ៉ា*



កិច្ចពិភាក្សារវាងគណៈកម្មការទី៥ ព្រឹទ្ធសភា និងក្រសួងព័ត៌មាន



ឯកឧត្តម ខៀវ កាញារីទ្ធ



ឯកឧត្តម ឈិត គឹមយាត

ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រី ក្រសួងព័ត៌មាន បានដឹកនាំថ្នាក់ដឹកនាំជំនាញ ទទួលបន្ទុក អគ្គនាយកដ្ឋានទាំង ៥ App ក្រសួងព័ត៌មាន  វិទ្យុ FMជាតិ 96MHz ជួបពិភាក្សាការងារជាមួយគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា ដែលដឹកនាំដោយឯកឧត្តម **ឈិត គឹមយាត** ប្រធានស្តីទីគណៈកម្មការទី៥ នៃព្រឹទ្ធសភា កាលពីព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដើម្បី





ឆ្លើយនូវសំណួរមួយចំនួនទាក់ទងដំណើរការវិវឌ្ឍនៃវិស័យព័ត៌មាន និងសោតទស្សន៍នៅកម្ពុជា រួមជាមួយបញ្ហាប្រឈមនានា ដែលក្រសួងព័ត៌មានត្រូវធ្វើការដោះស្រាយ និងបំពេញឱ្យបានល្អ ។

ក្នុងឱកាសនោះ ឯកឧត្តម **ឈិត គឹមយាត** បានជម្រាបជូនអំពីគោលបំណងនៃកិច្ចពិភាក្សា គឺដើម្បីស្វែងយល់អំពីការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន និងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ខេត្ត ដូចជា វិទ្យុ ទូរទស្សន៍ កាសែត





ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងព័ត៌មាន ចូលរួមក្នុងពិធីពិភាក្សា

ទស្សនាវដ្តី ជាដើម។ ឯកឧត្តមបានបញ្ជាក់បន្ថែមថា កិច្ចពិភាក្សានាពេលនេះ គឺដើម្បីពិភាក្សាលើបញ្ហានានា និងជួយគ្នាទៅវិញទៅមកលើការកែសម្រួលច្បាប់ និងបញ្ហាមួយចំនួនដែលព្រឹទ្ធសភាបានចុះទៅមូលដ្ឋាន ដែលនេះគឺជាតួនាទីរបស់ព្រឹទ្ធសភា ហើយមិនមែនជាការវាយតម្លៃទៅលើសមិទ្ធផលជាច្រើនដែលក្រសួងសម្រេចបាននោះទេ ។

ឯកឧត្តមបានបញ្ជាក់បន្ថែមអំពីមុខងាររបស់ព្រឹទ្ធសភា គឺនីតិកម្ម ត្រួតពិនិត្យ និងតំណាង និងបានលើកឡើង អំពីកម្រង





▼ ឯកឧត្តម ខៀវ កាញារីទ្ធ និងថ្នាក់ដឹកនាំក្រសួងព័ត៌មាន ជួបពិភាក្សាជាមួយគណៈកម្មការទី៥ នៃព្រឹទ្ធសភា ▲



កម្ពុជា ទទក បន្ថែម ដែលក្រៅពី ទទក១ ផ្សាយព័ត៌មានទូទៅ គឺ ទទក២ ផ្សាយកម្មវិធីអប់រំ សម្រាប់ការបង្រៀនតាមប្រព័ន្ធអនឡាញ កាលពីកំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ រួមទាំងគម្រោង ទទក៣ មានកម្មវិធីផ្សព្វផ្សាយព័ត៌មានកំសាន្តសប្បាយ ។ ចំពោះ AKP មានផ្សាយជាភាសាអង់គ្លេស បារាំង និងអារ៉ាប់ ហើយការផ្សព្វផ្សាយរបស់វិទ្យុជាតិកម្ពុជា តាមរលកធាតុអាកាស AM និង FM ហើយសម្រាប់វិទ្យុជាតិ FM 96

▼



សំណួរមួយចំនួនដែលគណៈកម្មការទី៥ បានផ្ញើជូនក្រសួងព័ត៌មាន ដើម្បីពិនិត្យ និងរាយការណ៍។

ឯកឧត្តមរដ្ឋមន្ត្រី **ខៀវ កាញារីទ្ធ** មានប្រសាសន៍ជម្រាបជូនអំពីវឌ្ឍនភាពរបស់ក្រសួងព័ត៌មាន ទាក់ទងនឹងការអនុវត្តតួនាទីភារកិច្ច ដែលអនុវត្តស្របទៅតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ឯកឧត្តមក៏បានរំលេចអំពីការរៀបចំប៉ុស្ដិ៍ទូរទស្សន៍ជាតិ

គឺផ្សាយសម្រាប់ទេសចរណ៍ និងយុវជន ដែលមានជាភាសាខ្មែរ ភាសាចិន និងវៀតណាម។ ជាមួយនេះ ក៏មានកម្មវិធីវិទ្យុ FM តាមបណ្ដាខេត្ត ក្នុងនោះ វិទ្យុជាតិ ខេត្តរតនគីរី ក៏មានផ្សាយជាភាសា ព្រៅ ព្នង ទំពួន គ្រឹង និងចារាយផងដែរ ។

ជាមួយនេះដែរក្រសួង ក៏ត្រៀមរៀបចំបង្កើតស្ថានីយវិទ្យុ-នៅលើភ្នំបូកគោក ដែលមានកម្ពស់ខ្ពស់អាចផ្សាយបានឆ្ងាយពិសេសមានសារប្រយោជន៍ដល់បងប្អូនប្រជានេសាទ អ្នកធ្វើ



ទិដ្ឋភាពនៃកិច្ចពិភាក្សារវាងក្រសួងព័ត៌មាន និងគណៈកម្មការទី៥ នៃព្រឹទ្ធសភា

ដំណើរតាមសមុទ្រ និងកងទ័ពដែលប្រចាំការតាមបណ្តាកោះ អាចស្តាប់បានការផ្សាយព័ត៌មាន ដំណឹងទាន់ហេតុការណ៍ថ្មីៗ។

ទាក់ទងនឹងអ្នកសារព័ត៌មាន គឺក្រសួងមានអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ដើម្បីគ្រប់គ្រង ហើយដោះស្រាយវិវាទអ្នកសារព័ត៌មាន ក្រសួងមានមេធាវីប្រចាំក្រសួង និងមេធាវីស្ម័គ្ររបស់សម្តេចតេជោផងដែរ សម្រាប់ជួយសម្របសម្រួល និងដោះស្រាយក្នុងករណីដែលអ្នកសារព័ត៌មានអនុវត្តន៍ត្រឹមត្រូវតាមវិជ្ជាជីវៈ។ ឯកឧត្តមរដ្ឋមន្ត្រី ក៏បានបញ្ជាក់បន្ថែមថា តាម



ឯកឧត្តម ឈិត គីមយាត ជូនស៊ីញ៉េអនុស្សាវរីយ៍ដល់ ឯកឧត្តម ខៀវ កាញារីទ្ធ



ពិធីថតរូបអនុស្សាវរីយ៍រវាងប្រតិភូទាំងពីរ

រយៈរដ្ឋធម្មនុញ្ញកម្ពុជា ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ប៉ុន្តែករណីដែលប្រើប្រាស់សិទ្ធិនេះដោយបំពាននោះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ ក្រសួងកំពុងតែរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន និងសេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មច្បាប់របបសារព័ត៌មាន ដើម្បីពង្រឹងការគ្រប់គ្រងអ្នកសារព័ត៌មានឱ្យកាន់តែល្អប្រសើរ និងសិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋទូទៅផងដែរ ។ ឯកឧត្តមក៏បានបញ្ជាក់ជូនអំពីបញ្ហាប្រឈមដែលក្រសួងជួបប្រទះនោះ គឺបញ្ហាហិរញ្ញវត្ថុ និងធនធានមនុស្ស ដែលនៅមានកម្រិតនៅឡើយ និងពុំទាន់អាចឆ្លើយតបបាន ទាន់ពេលវេលា និងគ្រប់គ្រាន់លើកិច្ចការព័ត៌មាន និងផ្សព្វផ្សាយ។

ទាក់ទងទៅសំណួរពាក់ពន្ធ័នឹងការផ្លាស់ប្ដូរប្រពន្ធ័ការផ្សាយ ពីអាណាឡូក មកប្រពន្ធ័ឌីជីថល ឯកឧត្ដមរដ្ឋមន្ត្រីក្រសួងព័ត៌មាន បានបញ្ជាក់ពីសារសំខាន់ដែលត្រូវផ្លាស់ប្ដូរស្របតាមការវិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រពន្ធ័ផ្សព្វផ្សាយនៅកម្ពុជា និងពិភពលោក ហើយកន្លងមកនេះ ទូរទស្សន៍រដ្ឋ និងឯកជនក្នុងស្រុកមួយចំនួនបានប្ដូរមកប្រើប្រព័ន្ធឌីជីថលនេះជាបណ្ដើរៗរួចមកហើយ។

ឯកឧត្ដមប្រធានស្ដីទីគណៈកម្មការទី៥ នៃព្រឹទ្ធសភា បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរួមជាមួយនឹងសមិទ្ធភាពដែលក្រសួងព័ត៌មានសម្រេចបាន។ ឯកឧត្ដមក៏បានបញ្ជាក់បន្ថែមអំពីបញ្ហាមួយចំនួនដែលទទួលបានពីមូលដ្ឋាន និងមានសំណូមពរចំនួនបី គឺ ១. ស្នើពិនិត្យ និងរៀបចំបញ្ចប់សេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មានឱ្យបានឆាប់តាមដែលអាចធ្វើបាន ២. ស្នើកំណត់លក្ខខណ្ឌឱ្យបានច្បាស់បន្ថែមទៀតចំពោះ ការស្នើសុំ ប្រកបវិជ្ជាជីវៈអ្នកសារព័ត៌មាន និង ៣. បើកវគ្គបណ្ដុះបណ្ដាលអ្នកសារព័ត៌មានឱ្យបានច្រើនបន្ថែមទៀត។

ឯកឧត្ដម **ឈិត គឹមយាត** បានធ្វើការបូកសរុបកិច្ចពិភាក្សា និងបញ្ជាក់ថា គណៈកម្មការទី៥ នឹងរៀបចំរបាយការណ៍នៃកិច្ចពិភាក្សានាឱកាសនេះ គោរពជូនសម្ដេចប្រធានព្រឹទ្ធសភា និងគណៈកម្មការទាំងអស់បានជ្រាប ៕

# ពិធីចុះហត្ថលេខា កិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន
# រវាងទីភ្នាក់ងារសារព័ត៌មានកម្ពុជា និង ទីភ្នាក់ងារសារព័ត៌មានគុយបា

*អត្ថបទ ៖ យូ សំបូរ , រូបថត ៖ វ៉ាន់ ច័ន្ទភិរុណ*




ពិធីចុះហត្ថលេខាកិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារសារព័ត៌មានកម្ពុជា និងទីភ្នាក់ងារសារព័ត៌មានគុយបា

ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃពិធីចុះហត្ថលេខាលើអនុស្សរណៈថ្មីស្តីអំពីកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មាន រវាងទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP និងទីភ្នាក់ងារសារព័ត៌មានគុយបា Prensa Latina នាថ្ងៃអង្គារ១កើត ខែកត្តិក ឆ្នាំខាលចត្វាស័ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ នៅសាលព្រះវិហារ នៃក្រសួងព័ត៌មាន។ កិច្ចព្រមព្រៀងថ្មីនេះមានបំណងបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធឈរលើមូលដ្ឋាននៃផលប្រយោជន៍រួមទៅវិញទៅមក ដើម្បីលើកកម្ពស់ និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងវិស័យព័ត៌មាន ទម្រង់អត្ថបទ រូបថត និងសោតទស្សន៍ ព្រមទាំងចំណេះដឹងផ្នែកសារព័ត៌មាន និងការគ្រប់គ្រងព័ត៌មាន។

ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានរម្លឹកឡើងពីចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អ រវាងប្រទេសកម្ពុជា និងគុយបា ចាប់ពីពេលនោះមកយើងមានសាលាមួយនៅកម្ពុជា ដែលមានឈ្មោះថា សាលាគុយបា។ នៅឆ្នាំប្រទេសកម្ពុជា ត្រូវបានគេហ៊ុំព័ទ្ធសេដ្ឋកិច្ចដូចប្រទេសគុយបា ហើយកម្ពុជានាពេលនោះបានជួបនូវការលំបាកបំផុតមានភាពអត់ឃ្លាន នៅពេលនោះប្រទេសជាមិត្តចង់ផ្តល់ជាខ្មៅដៃសៀវភៅមកកម្ពុជាក៏គេជំទាស់ ព្រោះការសម្រេចរបស់អង្គការសហប្រជាជាតិ គឺផ្តល់តែជំនួយបន្ទាន់តែប៉ុណ្ណោះ។

ឯកឧត្តមរដ្ឋមន្ត្រី បានគូសបញ្ជាក់ថា កម្ពុជាយល់ច្បាស់ពីការលំបាកទាំងអស់នេះ ហើយគាំទ្រការតស៊ូប្រឹងប្រែងរបស់រដ្ឋាភិបាល និងប្រជាជនគុយបាបន្តទៅមុខទៀត តាមរយៈការផ្សាយព័ត៌មានពិតប្រាកដ ពីអ្វីដែលកើតមានឡើងនៅក្នុងប្រទេសគុយបា។

សូមបញ្ជាក់ថា នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៦០ ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋគុយបាបានបង្កើតទំនាក់ទំនងការទូតជាមួយគ្នា ហើយចាប់ពីពេលនោះមកមានដំណើរទស្សនកិច្ចទៅកាន់គុយបា របស់សម្តេចតេជោ **ហ៊ុន សែន** នាឆ្នាំ ១៩៩៩ ជាព្រឹត្តិការណ៍គួរឱ្យចងចាំរបស់សម្តេចតេជោ **ហ៊ុន សែន** ជាមួយឯកឧត្តម **ហ្វីដែល កាស្រ្តូ** និងគ្រឿងឥស្សរិយយសលំដាប់ខ្ពស់ "**ហូសេម៉ារទី**" ។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២២ ក្នុងឱកាសសម្តេចតេជោអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសគុយបា កម្ពុជានិងគុយបា បានប្តេជ្ញាលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិ




កម្ពុជា និងគុយបា ចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរ លើវិស័យព័ត៌មាន

ការ ខណៈអនុស្សរណៈចំនួន៣ ត្រូវបានចុះហត្ថលេខានៅប្រទេសគុយបា និងបានជួបសម្តែងការគួរសមជាមួយប្រធានសភា និងប្រធានាធិបតីរបស់គុយបា និងបានអញ្ជើញដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធវីរបុរសគុយបា ឯកឧត្តម Jose Marti នៅវិមាន Jose Marti Memorial ព្រមទាំងអញ្ជើញទស្សនកិច្ចស្សនកិច្ចនៅមជ្ឈមណ្ឌលវិស្វកម្មហ្សេន និងជីវបច្ចេកវិទ្យា ដែលបង្កើតឡើងដោយដោយឯកឧត្តម **ហ្វីដែល កាស្ត្រូ** អតីតប្រធានាធិបតីគុយបាផងដែរ។

សម្តេចតេជោ **ហ៊ុន សែន** និងលោកប្រធានាធិបតីគុយបា បានរម្លឹកឡើងវិញយ៉ាងច្រើននូវចំណងមិត្តភាព និងទំនាក់ទំនងរវាងកម្ពុជា និងគុយ ជាពិសេសការប្រកៀកស្មាគ្នាដើម្បីជម្នះការលំបាកទាំងឡាយកាលពីអតីតកាល។ បានរំលឹកពីទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ ក្រោយពេលបដិវត្តន៍នៃប្រទេសគុយបា ហើយទំនាក់ទំនងនេះបានចាប់ផ្តើមរវាងអតីតប្រធានាធិបតី **ហ្វីដែល កាស្ត្រូ** និងអតីតព្រះមហាក្សត្រ **សម្តេច ព្រះនរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ។ លោកប្រធានាធិបតីគុយបាបានគូសបញ្ជាក់ថា ប្រទេសកម្ពុជា និងគុយបា បានគាំទ្រការស្វែងរកសន្តិភាព ក៏ដូចជាយុត្តិធម៌នៅលើពិភពលោក ដែលជាមូលដ្ឋាន នៃទំនាក់ទំនងប្រទេសគុយបា និងកម្ពុជា និងបានទទួលស្គាល់និងសរសើរភាពក្លាហានរបស់គណបក្សប្រជាជនកម្ពុជា ក៏ដូចជារាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ប្រយុទ្ធដើម្បីការពារឯករាជ្យភាព និងអធិបតេយ្យភាពរបស់កម្ពុជា។ ដំណើរទស្សនកិច្ចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីនៅគុយបា ក្នុងពេលវេលាមួយដែលមានភាពស្មុគស្មាញពាក់ព័ន្ធសេដ្ឋកិច្ច តែដំណើរទស្សនកិច្ចនេះមានសញ្ញាវិជ្ជមានដ៏ល្អនៃមិត្តភាព និងសាមគ្គីភាព។ ទស្សនកិច្ចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ឆ្លុះបញ្ចាំងយ៉ាងសំខាន់ជាប្រវត្តិសាស្ត្រនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ និងជាសក្សីមួយដ៏សំខាន់ នៃការបន្តពង្រឹងទំនាក់ទំនងទ្វេភាគី ប្រទេសទាំងពីរនឹងមានកិច្ចព្រមព្រៀងមួយចំនួនទៅលើវិស័យសុខាភិបាលអប់រំ និងការផ្លាស់ប្តូរទស្សនកិច្ច ការបណ្តុះបណ្តាលបទពិសោធន៍របស់អ្នកការទូតជាដើម ព្រមទាំងវិស័យផ្សេងៗទៀត ដែលយើងអាចពង្រីកបាន។ គុយបាពិតជារីករាយក្រៃលែងចំពោះទស្សនកិច្ចរបស់សម្តេចតេជោ នៅគុយបា នាពេលនេះ ព្រោះបានជួយជំរុញទំនាក់ទំនងរវាងប្រទេស និងប្រទេស ក៏ដូចជាប្រជាជន និងប្រជាជននៃប្រទេសទាំងពីរឱ្យកាន់តែប្រសើរឡើង។

សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា កម្ពុជា និងគុយបា នឹងចងចាំនូវការងារដែលបានធ្វើជាមួយគ្នាជាយូរមក ជាពិសេសការជួយគ្នាក្នុងឆ្នាំ១៩៧៩ កាលពី៤៣ឆ្នាំមុន។ ពេលនោះសម្តេចបានអញ្ជើញបំពេញទស្សនកិច្ចនៅគុយបា ដែលកាលនោះសម្តេចនៅជារដ្ឋមន្ត្រីការបរទេស ដើម្បីរៀបចំដំណើរទស្សនកិច្ចរបស់ប្រមុខរដ្ឋកម្ពុជា ចូលរួមកិច្ចប្រជុំចលនា

មិនចូលបក្សសម្ព័ន្ធ។ ប្រសិនបើគ្មានការជួយពីឯកឧត្តម **ហ្វីដែល កាស្ត្រូ** ទេនោះ កៅអីកម្ពុជាក្នុងចលនាមិនចូលបក្សសម្ព័ន្ធនេះ គឺដូចនឹងស្ថានភាពនៅអង្គការសហប្រជាជាតិ តែដោយសារមានការជួយរបស់ឯកឧត្តម **ហ្វីដែល កាស្ត្រូ** ទើបកៅអីកម្ពុជាក្នុងអង្គការចលនាមិនចូលបក្សសម្ព័ន្ធត្រូវទុកទំនេរ។ ទំនាក់ទំនងរវាងសម្តេច និងឯកឧត្តម **ហ្វីដែល កាស្ត្រូ** ហាក់បីដូចជាឪពុក និងកូន។ ជាពិសេសទំនាក់ទំនងរវាងសម្តេច និងឯកឧត្តម **ហ្វីដែល កាស្ត្រូ** ដែលធ្លាប់បានចរចា និងពិភាក្សាគ្នាជាច្រើន។ ប្រជាពលរដ្ឋកម្ពុជា មិនភ្លេចនោះឡើយ នូវអ្វីដែលប្រទេសគុយបាបានជួយដល់ប្រទេសកម្ពុជា ក្នុងគ្រាដ៏លំបាកក្រោយរំដោះចេញពីរបបប្រល័យពូជសាសន៍ប៉ុលពត។ នៅពេលនោះប្រទេសគុយបាបានជួយកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងក្រុមចក្រពត្តិនិយម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ នៅក្នុងឆ្នាំ១៩៧៩ ប្រទេសគុយបា បានជួយកម្ពុជាយ៉ាងច្រើន ពេលនោះកម្ពុជាមានស្តុរគុយបា មជ្ឈមណ្ឌលកុមារកំព្រាគុយបា ហើយក៏មានកប៉ាល់ចម្លងរបស់គុយបាផងដែរ។ ជំនួយគុយបានៅពេលនោះ គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់កម្ពុជា ជាពិសេសពលរដ្ឋកម្ពុជា ដែលទើបងើបពីសេចក្តីស្លាប់ នៃរបបខ្មែរក្រហម ហើយត្រូវការចាំបាច់ការរស់រៀនមានជីវិត ដូច្នេះជំនួយពីប្រទេសគុយបាគឺចាំបាច់បំផុត។ អ្វីដែលកាន់តែពិសេសទៀតនោះ ប្រទេសគុយបានជួយបណ្តុះបណ្តាលធនធានមនុស្ស គឺជារឿងសំខាន់ ក្នុងការអភិវឌ្ឍប្រទេសកម្ពុជានាពេលនោះ។ ពាក់ព័ន្ធកិច្ចការអាស៊ានវិញ សម្តេចតេជោ **ហ៊ុន សែន** បានលើកឡើងថា ប្រទេសគុយបា មានមិត្តភក្តិមួយចំនួនជាសមាជិកអាស៊ាន ដូចជា កម្ពុជា ឡាវ និងវៀតណាមផងដែរ ដូច្នេះគុយបាអាចធ្វើការជាមួយអាស៊ាន ទៅតាមវិស័យ ទៅតាមផ្នែក នៃកិច្ចសហប្រតិបត្តិការនេះ។ ប្រទេសគុយបា ធ្លាប់ចូលជាភាគីក្នុងសន្ធិសញ្ញាកិច្ចសហប្រតិបត្តិការអាស៊ីអាគ្នេយ៍រួចហើយ ដូច្នេះអ្វីដែលគុយបាចាប់អារម្មណ៍នេះ នឹងធ្វើឱ្យអាស៊ានកាន់តែមានតម្លៃ។ លោកប្រធានាធិបតីគុយបា បានចាត់ទុកសម្តេចតេជោជាមិត្តភក្តិដ៏ជិតស្និទ្ធ ហើយអរគុណសម្រាប់ពាក្យពេចន៍ទាំងឡាយដែលសម្តេចបានលើកឡើង គឺបានឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រ នៃភាពស្និទ្ធស្នាលរវាងប្រទេសទាំងពីរ ហើយក៏ឆ្លុះបញ្ចាំងអំពីដំណើរទស្សនកិច្ចរបស់សម្តេចកាលពីពេលមុន។ លោកប្រធានាធិបតី ក៏បានលើកឡើងពីការដាក់ទណ្ឌកម្មរបស់អាមេរិកលើប្រទេសគុយបា ដែលនាំឱ្យប្រទេស និងប្រជាជនទាំងមូលបានជួបការលំបាក តែគុយបាបានតស៊ូប្រឆាំងរាល់ការលំបាករួមទាំងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ផងដែរ។ ការយកឈ្នះលើជំងឺកូវីដ-១៩ ដោយសារការពឹងផ្អែកទៅលើសមត្ថភាពវេជ្ជសាស្ត្រ ក៏ដូចជាបទពិសោធន៍របស់ប្រជាពលរដ្ឋគុយបា ជាពិសេសការផលិតវ៉ាក់សាំងរបស់គុយបា ដែលមានវ៉ាក់សាំងរហូតដល់ទៅ៥ប្រភេទ។ វ៉ាក់សាំងនេះ មិនត្រឹមតែចាក់ពលរដ្ឋគុយបានោះទេ តែបាននាំចេញទៅក្រៅប្រទេសផងដែរ។ លោកប្រធានាធិបតី ក៏បានគូសបង្ហាញពីការប្តេជ្ញាចិត្តក្នុងការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗជាមួយកម្ពុជា ដោយបន្តធ្វើយ៉ាងណាជំរុញផលប្រយោជន៍រួមលើឆាកអន្តរជាតិផងដែរ៕



រូបថតអនុស្សាវរីយ៍

# ឯកឧត្តម រដ្ឋមន្ត្រី ខៀវ កាញារីទ្ធ ប្រគល់រថយន្តចំនួន ០៣គ្រឿង ដល់អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP និងអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

អត្ថបទ៖ យូ សំបូរ , រូបថត៖ អ៊ុង ហុងលៀង


ឯកឧត្តម ខៀវ កាញារីទ្ធ មានប្រសាសន៍ សំណេះសំណាលជាមួយថ្នាក់ដឹកនាំក្រសួងព័ត៌មាន

ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានប្រគល់ និងបែងចែករថយន្តចំនួន០៣គ្រឿង ដល់អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជាAKPចំនួន០២គ្រឿង គឺរថយន្ត ISUZU ០១គ្រឿងពាក់ស្លាកលេខរដ្ឋ11 2-0809 និងរថយន្ត NISSAN ០១គ្រឿងពាក់ស្លាកលេខរដ្ឋ112-0909 និងប្រគល់ជូនអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងព័ត៌មានចំនួន០១គ្រឿង ម៉ាក SIENNA ពាក់ស្លាកលេខរដ្ឋ11 2-5696 នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ដើម្បីសម្រួលការងារបន្ថែមឱ្យបានកាន់ល្អដល់ក្រុមការងារចុះធ្វើបទយកការណ៍ និងចុះយកព័ត៌មានទៅតាមបណ្ដាខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងឱកាសនោះដែរ ឯកឧត្តម **លី អ៊ាន់ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុ និងលោកជំទាវ


ឯកឧត្តម ខៀវ កាញារីទ្ធ ប្រគល់រថយន្តចំនួន០៣គ្រឿង ដល់ថ្នាក់ដឹកនាំក្រសួងព័ត៌មាន





ឯកឧត្តម ខៀវ កាញារីទ្ធប្រគល់រថយន្តជូនឯកឧត្តម លី វ៉ាន់ហុង និងលោកជំទាវ សុខមុំ និមល



ឯកឧត្តម អ៊ុង ហុងលៀង ទីប្រឹក្សានិងជាតំណាងក្រសួងព័ត៌មានទទួលរថយន្តពីមន្ត្រីគយនៅខេត្តបាត់ដំបង

**សុខមុំ និមល** អគ្គនាយិកា ទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP បានសំដែងនូវការអរគុណយ៉ាងជ្រាលជ្រៅដល់ឯកឧត្តមរដ្ឋមន្ត្រី **ខៀវ កាញារីទ្ធ** ដែលបានផ្តល់រថយន្តទាំងនេះទុកសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅក្នុងអង្គភាពចុះបំពេញបេសកកម្មនៅ តាមបណ្តាខេត្ត ក្រុង និងក្នុងរាជធានីភ្នំពេញបានយ៉ាងងាយស្រួល ពិសេសចុះយកព័ត៌មានមកផ្សព្វផ្សាយបានឆាប់រហ័ស។ ឯកឧត្តមរដ្ឋមន្ត្រីបានជម្រុញលើកទឹកចិត្តឱ្យថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់បន្តស្មារតីសាមគ្គីភាព និងសហការគ្នាបំពេញកិច្ចការប្រកបដោយប្រសិទ្ធភាព និងលទ្ធផលល្អ។ រថយន្តទាំង០៣គ្រឿងដែលប្រគល់ជូនដល់អគ្គនាយកដ្ឋានទាំងពីរនាពេលនោះ ឯកឧត្តមរដ្ឋមន្ត្រីបានគូសបញ្ជាក់ថា ទោះបីមិនមែនជារថយន្តថ្មីក៏ដោយ តែនៅប្រើប្រាស់ធ្វើដំណើរបាន




រថយន្តចំនួន០៣គ្រឿងជាអំណោយ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជូនក្រសួងព័ត៌មាន



ឯកឧត្តម ខៀវ កាញារីទ្ធ អញ្ជើញពិនិត្យរថយន្ត

ហើយត្រូវរួមគ្នាថែរក្សា ដើម្បីប្រើប្រាស់បានយូរអង្វែង។

សូមបញ្ជាក់ថា រថយន្តចំនួន ០៣គ្រឿង ខាងលើជាអំណោយដ៏ថ្លៃថ្លា របស់ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាជូនដល់ក្រសួងព័ត៌មាន ដើម្បីសម្រួលការងារដល់ក្រុមការងារ នៃក្រសួងព័ត៌មាន។ រថយន្តទាំង០៣គ្រឿងនេះបានផ្តល់ជូនដោយមន្ត្រីគយ ការិយាល័យស្រាវជ្រាវ និងបង្ក្រាប អំពើរត់ពន្ធ តំបន់៤ ចំនួន០១គ្រឿង ម៉ាក NISSAN NAVARA នៅខេត្តបាត់ដំបង,០១គ្រឿង ម៉ាក ISUZU ប្រគល់នៅខេត្តពោធិ៍សាត់ និង០១គ្រឿងទៀត ម៉ាក SIENNA នៅភ្នំពេញ ជូនឯកឧត្តម **អ៊ុង ហុងលៀង** ទីប្រឹក្សាក្រសួងព័ត៌មាន និងជាតំណាងឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន។



ជាមួយគ្នានេះដែរ ឯកឧត្តមរដ្ឋមន្ត្រី **ខៀវ កាញារីទ្ធ** ក៏បានពិនិត្យ ទទួលយករថយន្ត ០១គ្រឿង ម៉ាក ហុងឃី (HON GQI) HS5 របស់ក្រុមហ៊ុន MING YANG GUOJI ដែលបានប្រគល់ជូន ដល់ក្រុមការងារ ក្នុងកម្មវិធីប្រឡងសំនៀងជនពិការកម្ពុជា ពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** លើកទី២ ហើយរថយន្ត HON GQI ក្រុមការងារនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន បានយកមករក្សាទុកសម្រាប់ចុះបំពេញការងារតាមបណ្តាខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា នៅពេលមានកម្មវិធីប្រឡងសំនៀងជនពិការចាប់ផ្តើមដំណើរការនាពេលខាងមុខ។

សូមបញ្ជាក់ផងដែរថា ក្រុមហ៊ុន MING YANG GUOJI បានជូនរថយន្តចំនួន០១គ្រឿង ដល់ក្រសួងព័ត៌មាន ដែលពិធី ប្រគល់និងទទួលបានធ្វើឡើងកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ នៅទីតាំងក្រុមហ៊ុន MING YANG GUOJI ស្ថិតក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ក្រោមអធិបតីភាពឯកឧត្តម **គឹម គុណាវឌ្ឍ** រដ្ឋលេខាធិការក្រសួងព័ត៌មាន តំណាងឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន។

ក្នុងឱកាសនោះលោក Zhu Shuai អគ្គនាយកក្រុមហ៊ុន MING YANG GUOJI បានបញ្ជាក់ថា ការមកដល់របស់ក្រុមហ៊ុននៅប្រទេសកម្ពុជា យើងនឹងខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីបន្តថែរក្សា និងអភិវឌ្ឍមិត្តភាពដ៏ជ្រាលជ្រៅរវាងកម្ពុជាចិន ឱ្យបានល្អប្រសើរក្នុងអំឡុងពេលដែលសហគ្រាសមានការរីកចម្រើនដោយមិនភ្លេចឡើយអំពីការចូលរួមឧបត្ថម្ភក្នុងកម្មវិធីប្រឡងសំនៀងជនពិការកម្ពុជា ពានរង្វាន់ សម្តេចតេជោ **ហ៊ុន សែន** លើកទី២។ លោកអគ្គនាយកបានបន្តថា ក្រុមហ៊ុន MING YANG GUOJI គ្រប់បានបង្ហាញវត្តមាននៅកម្ពុជា រយៈពេលជាង៤ឆ្នាំមកហើយ ដោយដើរតួជាតំណាងចែកចាយក្នុងការលក់ និងផ្តល់នូវសេវាកម្មលក់រថយន្តម៉ាក HON GQI




*ឯកឧត្តម កឹម គុណាវឌ្ឍ ទទួលរថយន្ត ០១គ្រឿងពីក្រុមហ៊ុន MING YANG GUOJI*

ដែលជាម៉ាករថយន្តដ៏ល្បីល្បាញរបស់ចិន បានទទួលស្គាល់ក្នុងកម្រិតខ្ពស់នៅទីផ្សារកម្ពុជា។ ទាំងនេះក៏ជានិមិត្តសញ្ញា នៃទំនាក់ទំនងមិត្តភាពដ៏ជ្រាលជ្រៅរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ចាប់តាំងពីទសវត្សរ៍ឆ្នាំ៦០ ដែលកាលនោះក្រោមការដឹកនាំរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានយាងបំពេញព្រះរាជទស្សនកិច្ចនៅរោងចក្រផលិតរថយន្តម៉ាក HON GQI នាប្រទេសចិន៕




*លោក អគ្គនាយក MING YANG GUOJI មានប្រសាសន៍*



# គម្រោងសាងសង់ប្រព័ន្ធស្រោចស្រព និងការពារទឹកជំនន់ស្ទឹងព្រែកត្នោត បានសម្រេចការសាងសង់ប្រមាណ ៧០ភាគរយ

អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ ក្រសួងធនធានទឹក



ឯកឧត្តម លឹម គានហោ ពិនិត្យមើលផែនទីបំព្រួញនៃភូមិសាស្ត្រស្ដីពីគម្រោងសាងសង់ប្រព័ន្ធស្រោចស្រព និងស្ថានភាពទឹកស្ទឹងព្រែកត្នោតខេត្តកណ្ដាលជាមួយមន្ត្រីជំនាញ

ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ក្នុងឱកាសអញ្ជើញចុះពិនិត្យលទ្ធភាពក្នុងការរំដោះទឹកជំនន់ពីស្ទឹងព្រែកត្នោតខេត្តកណ្ដាល ដើម្បីបង្ហូរទម្លាក់ចូលទៅក្នុងទន្លេតាមរយៈប្រឡាយ ៩៤ និង ៩៦ ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២២ ដោយឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា៖ ស្ថានភាពទឹកតាមខ្នងទំនប់ សណ្ដាស្ទឹងព្រែកត្នោតបច្ចុប្បន្ននៅពុំទាន់មានអ្វីជាការព្រួយបារម្ភខ្លាំងក្លានៅឡើយទេ ។ ទន្ទឹមនេះឯកឧត្តមរដ្ឋមន្ត្រី បានណែនាំបន្ថែមដល់ប្រធានមុខ



ស្ថានភាពទឹកនៅទ្វារទឹកទំនប់អាង ៧មករា





ស្ថានភាពទឹកនៅសណ្ដស្ទឹងព្រែកត្នោត

ព្រួញទាំងអស់ត្រូវបង្កើនការយកចិត្តទុកដាក់ដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

តាមការបញ្ជាក់ពីមន្ត្រីជំនាញក្រសួង នៅល្ងាចថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ បានឱ្យដឹងថាចំពោះស្ថានភាពទឹក គឺគ្រាន់តែលិចតាមតំបន់នៅក្រៅសណ្ដស្ទឹងព្រែកត្នោត ក្នុងនោះមានតាមលំនៅឋានរបស់ប្រជាពលរដ្ឋលិចតិចតួចប៉ុណ្ណោះ ដែលជាសញ្ញាណមិនទាន់មាននៃការគំរាមកំហែងធ្ងន់ធ្ងរដល់លំនៅឋានរបស់ប្រជាពលរដ្ឋនោះឡើយ ។ ដោយឡែកកម្ពស់ទឹកនៅអាងទំនប់ ៧មករា មានកម្ពស់ ៥,១៩ម៉ែត្រ ហើយកម្ពស់ទឹកនេះមិនទាន់មានបញ្ហាអ្វីដែលព្រួយបារម្ភអ្វីនោះទេ។រីឯស្ថានភាពដែលឃើញមានលិចនៅលើដងស្ទឹងព្រែកត្នោតនៅពេលនេះ គឺមិនទាន់មានហៀរចេញធំដុំអ្វីនោះឡើយ ហើយអាចមានទឹកលិចតិចតួចនៅតាមតំបន់ដែលទាបឬហៅថាក្រៅសណ្ដ ។

ដោយឡែក កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយមបានឱ្យដឹងដែរថា ស្ថានភាពកម្ពស់ទឹកស្ទឹងព្រែកត្នោត បណ្ដាលមកពីជំនន់ទឹកភ្លៀង។ នៅសំណង់ទ្វារទឹកទំនប់អាង៧មករា មានកម្ពស់ទឹកខាងមុខទ្វារ៤,៨០ម៉ែត្រ(កម្ពស់ទឹកប្រុងប្រយ័ត្ន ៥,៣០ម៉ែត្រ) ។ (កម្ពស់ទឹកហូរលើទំនប់បង្ហៀរ ០,០០ម៉ែត្រ) (ស្មើទំនប់បង្ហៀរ) ។កម្ពស់ទឹកខាងក្រោយទ្វារទំនប់៥,៤០ម៉ែត្រ, កម្ពស់ទឹកប្រុងប្រយ័ត្ន ៧,០០ម៉ែត្រ ។ ទន្ទឹមនេះ កម្ពស់ទឹក



ស្ទឹងព្រែកត្នោតបានបន្តស្រកចុះ ០,៣០ម៉ែត្រ ធៀបនឹងព្រឹកម្សិលមិញ។ ការលើកឡើងឱ្យដឹងបែបនេះ ខណៈឯកឧត្តមរដ្ឋមន្ត្រីបានអញ្ជើញចុះត្រួតពិនិត្យស្ថានភាពទឹកស្ទឹងព្រែកត្នោត នៅភូមិសាស្ត្រភាគខាងលិចរាជធានីភ្នំពេញនិងខេត្តកណ្ដាល អមដំណើរដោយថ្នាក់ដឹកនាំក្រសួង រួមមាន ឯកឧត្តម **ជួន ប៊ិតថុន** អនុរដ្ឋលេខាធិការឯកឧត្តម **ម៉ៅ ហាក់** ជាប្រធានមុខព្រួញរាជធានីភ្នំពេញ លោក **ថាំ វីរយុទ្ធដា** ប្រធានមុខព្រួញខេត្តកណ្ដាល លោក **ហៀង ម៉េង** ប្រធានមុខព្រួញខេត្តកំពង់ស្ពឺព្រមទាំងមន្ត្រីបច្ចេកទេស ដោយឯកឧត្តមរដ្ឋមន្ត្រី **លឹម គានហោ** បានអះអាងថា បេសកកម្មនេះធ្វើឡើងក្នុងគោលបំណងសំខាន់ៗ ចំនួន ៣ រួមមាន៖





ឯកឧត្តម លឹម គានហោ ចង្អុលបង្ហាញលើផែនទីបំព្រួញលើភូមិសាស្ត្រក្នុងការត្រៀមជួយអន្តរាគមន៍រំដោះទឹកស្ទឹងព្រែកត្នោត

*__ទី១៖__ ចុះពិនិត្យវឌ្ឍនភាពការងារអនុវត្តគម្រោងសាងសង់ប្រព័ន្ធស្រោចស្រព និងការពារទឹកជំនន់ព្រែកត្នោត ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ដែលទទួលជំនួយហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិន បានសម្រេចការសាងសង់ប្រមាណ**៧០ភាគរយ** ដោយបានចូលរួមចំណែកជួយសម្រួលលំហូរទឹកបានយ៉ាងច្រើន បើប្រៀបធៀបស្ថានភាពកម្ពស់ទឹកស្ទឹងដូចគ្នាកាលពីឆ្នាំមុន ។

*__ទី២៖__ ពិនិត្យស្ថានភាពទឹកតាមខ្នងទំនប់សណ្តស្ទឹងព្រែកត្នោត ដែលបច្ចុប្បន្នមិនទាន់មានសភាពធ្ងន់ធ្ងរនៅឡើយ បើទោះជាយ៉ាងនេះក្តី ក្រុមមន្ត្រីបច្ចេកទេសក្រសួងនិងគ្រឿងចក្របានប្រចាំការត្រៀមតាំងពីខែសីហា ឆ្នាំ២០២២ មកម្ល៉េះ ។

*__ទី៣៖__ ជាសំណូមពររបស់លោកដល់ប្រជាពលរដ្ឋ ដែលមានលំនៅឋាននៅតាមបណ្តោយស្ទឹងក្នុងភូមិសាស្ត្រខាងលិចរាជធានីភ្នំពេញ និងខេត្តកណ្តាល មេត្តារក្សានូវទំហំ ឬច្រកមុខទឹកចាស់ ដើម្បីធានាដល់ការដោះទឹកឱ្យមានប្រសិទ្ធភាពទាន់ពេលវេលា បើពុំនោះទេរាជធានីភ្នំពេញ និងទទួលរងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ។

គួរជម្រាបថា ស្ថានភាពកម្ពស់ទឹកស្ទឹងព្រែកត្នោត នៅសំណង់ទ្វារទឹកទំនប់អាង ៧មករា នាព្រឹកថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២នេះ កម្ពស់ទឹកខាងមុខទ្វារ៤,៨០ម៉ែត្រ ( កម្ពស់ទឹកប្រុងប្រយ័ត្ន៥,៣០ម៉ែត្រ ) កម្ពស់ទឹកហូរលើទំនប់បង្ហៀរ ០,០០ម៉ែត្រ(ស្មើកម្ពស់ទំនប់បង្ហៀរ),កម្ពស់ទឹកខាងក្រោយទ្វារទំនប់ ៥,៤០ម៉ែត្រ ( កម្ពស់ទឹកប្រុងប្រយ័ត្ន៧,០០ម៉ែត្រ ) ។ ស្ថានភាពព្រឹកនេះកម្ពស់ទឹកស្ទឹងព្រែកត្នោតបានបន្តស្រកចុះ ០,៣០ម៉ែត្រ ធៀបនឹងព្រឹកម្សិលមិញ ។

គួររំលឹកផងដែរថា ស្ថានភាពជំនន់ទឹកស្ទឹងព្រែកត្នោត កាលពីឆ្នាំ២០២០ កម្ពស់ទ្វារទឹកទំនប់៧មករា មានកម្រិតកម្ពស់ទ្វារទឹកខាងមុខ៦,៥៤ម៉ែត្រ,កម្ពស់ទឹកហូរលើទ្វារទឹកមានកម្ពស់១,៧៤ម៉ែត្រ ហើយកម្ពស់ទ្វារទឹកក្រោយ៩,៤៥ម៉ែត្រ ។ ដោយឡែកស្ថានភាពទឹកជំនន់ស្ទឹងព្រែកត្នោតកាលពីឆ្នាំ២០២១ កន្លងមក ទឹកបានចាប់ផ្តើមធ្វើការគំរាមកំហែងខ្លាំងនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ បន្ទាប់មកនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ ទឹកជំនន់ឡើងដល់កម្រិតកំពូល ដែលមានកម្ពស់អតិបរិមា ៦,៥៨ម៉ែត្រ ( កម្ពស់ហានិភ័យ៥,១០ម៉ែត្រ ) ។ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ ទឹកចាប់ផ្តើមស្រកចុះ លុះដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០២១ វេលាម៉ោង ១៤:00នាទីរសៀល កម្ពស់ទឹកស្ទឹងព្រែកត្នោត មានត្រឹម៥,០៨ម៉ែត្រ បានឆ្លងផុតហានិភ័យជាស្ថាពរ ។





ឯកឧត្តម លឹម គានហោ ពិនិត្យស្ថានភាពទឹកតាមសណ្តស្ទឹងព្រែកត្នោត



# ឯកឧត្តម ឧត្តមសេនីយ៍ ឯក ហ៊ុន ម៉ាណែត ជួបសម្តែងការគួរសមជាមួយ ប្រធានាធិបតីទីម័រខាងកើត

អត្ថបទ ៖ សាត សុផល, រូបថត ៖ សហការី



ជំនួបពិភាក្សារវាងឯកឧត្តម ហ៊ុន ម៉ាណែត និងឯកឧត្តមប្រធានាធិបតី ទីម័រខាងកើត



ឯកឧត្តមប្រធានាធិបតី ទីម័រខាងកើត

ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក បានអញ្ជើញជួបសម្តែងការគួរសមជាមួយឯកឧត្តម Jose Ramos Horta ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត កាលពីល្ងាចថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ក្នុងឱកាសដែល ឯកឧត្តម ប្រធានាធិបតី កំពុងបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។





ឯកឧត្តម ហ៊ុន ម៉ាណែត និងឯកឧត្តមប្រធានាធិបតី ទីម័រខាងកើត ប្តូរវត្ថុអនុស្សាវរីយ៍

ក្នុងជំនួបនេះ ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** សម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរបំពេញទស្សនកិច្ចផ្លូវរដ្ឋជាលើកទី២ របស់ ឯកឧត្តម ប្រធានាធិបតី Jose Ramos Horta មកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញអំពីចំណងមិត្តភាពដ៏ជិតស្និទ្ធ និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អរវាងប្រទេស រដ្ឋាភិបាល និងប្រជាជនទាំងពីរ កម្ពុជា-ទីម័រខាងកើត។



ក្នុងឱកាសនោះផងដែរ ឯកឧត្តម ឧត្តមសេនីយ៍ឯក ក៏បានចូលរួមអបអរសាទរចំពោះ ឯកឧត្តម Jose Ramos Horta ដែលទទួលបានជោគជ័យដ៏ត្រចះត្រចង់ក្នុងការបោះឆ្នោតប្រធា-នាធិបតីនៅប្រទេសទីម័រខាងកើត កាលពីខែមេសា ឆ្នាំ២០២២ កន្លងទៅ ដែលជាការចូលកាន់តំណែងប្រមុខរដ្ឋលើកទីពីររបស់ ឯកឧត្តម Jose Ramos Horta។

ឯកឧត្តម ប្រធានាធិបតីទីម័រខាងកើត បានសម្តែងនូវការពេញចិត្តចំពោះឱកាសដ៏មានអត្ថន័យសម្រាប់ជំនួបសំណេះសំណាលជាមួយ ឯកឧត្តម **ហ៊ុន ម៉ាណែត** និងបានរំលឹកអំពីភាពជាអ្នកដឹកនាំរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នៅក្នុងកិច្ចខិតខំប្រឹងប្រែងចូលរួមដោះស្រាយ





កិច្ចពិភាក្សាទំនាក់ទំនងមិត្តភាពរវាង កម្ពុជា-ទីម័រខាងកើត

បញ្ហាតំបន់ និងអន្តរជាតិ ជាពិសេសមនោសញ្ចេតនាស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្រ ដែលសម្តេចតេជោ មានចំពោះប្រទេស និងប្រជាជនទីម័រខាងកើត។

ជាមួយគ្នានេះ ឯកឧត្តម ប្រធានាធិបតី បានកត់សម្គាល់អំពីស្ថានភាពនៃការអភិវឌ្ឍរីកចម្រើនដ៏ឆាប់រហ័សរបស់ប្រទេសកម្ពុជា នៅក្រោយការបញ្ចប់ទាំងស្រុងនៃជម្លោះរ៉ាំរ៉ៃរាប់ទសវត្សរ៍ ដោយឯកឧត្តមបានវាយតម្លៃថា ជាការអភិវឌ្ឍដែលមានលក្ខណៈជាក់ស្តែង និងប្រាកដនិយម។

ក្រៅពីនេះ ឯកឧត្តមប្រធានាធិបតី និងលោកឧត្តមសេនីយ៍ ក៏បានផ្លាស់ប្តូរយោបល់គ្នាផងដែរអំពីទំនាក់ទំនងប្រកបដោយសក្តានុពលរវាងប្រទេសទាំងពីរ ជាពិសេសអំពីទស្សនវិស័យនៃកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗមួយចំនួនជាអាទិ៍ វិស័យវិនិយោគ ពាណិជ្ជកម្មនាំចេញ-នាំចូល កសិកម្ម អប់រំ ថាមពល និងការបើកជើងហោះហើរត្រង់ជាដើម។




ការថតរូបអនុស្សាវរីយ៍រវាងប្រតិភូកម្ពុជា និងទីម័រខាងកើត

# ឯកឧត្តម ថោង ខុន ទទួលគ្រឿងឥស្សរិយយស «ខ្សែកមាស» ពីក្រុមប្រឹក្សាអូឡាំពិកអាស៊ី (OCA)

*អត្ថបទ៖ សាត សុផល , រូបថត៖ ខឹម សុវណ្ណារ៉ា*



ក្រុមប្រឹក្សាអូឡាំពិកអាស៊ី (OCA) បានប្រគល់គ្រឿងឥស្សរិយយសថ្នាក់ខ្ពស់បំផុត «ខ្សែកមាស» ដល់ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិ CAMSOC ដែលនេះជាកិត្តិយសសម្រាប់ឯកឧត្តមចំពោះការលះបង់សម្រាប់ចលនាអូឡាំពិក និងការជំរុញឱ្យកីឡារីកចម្រើនរហូតទទួលរៀបចំព្រឹត្តិការណ៍អន្តរជាតិធំៗ កីឡាស៊ីហ្គេម-អាស៊ានប៉ារ៉ាហ្គេមឆ្នាំ២០២៣ និងការប្រកួតកីឡាអូឡាំពិកយុវជនអាស៊ីឆ្នាំ២០២៩ នៅកម្ពុជា។

ការប្រគល់គ្រឿងឥស្សរិយយសដល់ឯកឧត្តម **ថោង ខុន** ដោយឯកឧត្តម Raja Randhir Singh ប្រធានស្តីទីក្រុមប្រឹក្សាអូឡាំពិកអាស៊ី(OCA) នៅសណ្ឋាគារសុខារ៉េស៊ីដង់ ក្នុងពិធីបើកមហាសន្និបាតក្រុមប្រឹក្សាអូឡាំពិកអាស៊ីនាថ្ងៃទី០៤ខែតុលា



ឯកឧត្តម ថោង ខុន ទទួលខ្សែកមាសពីក្រុមប្រឹក្សាអូឡាំពិកអាស៊ី OCA








ឆ្នាំ២០២២ ក្រោមអធិបតីភាពរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ មហាសន្និបាតនេះដែរ ក៏មានការអញ្ជើញចូលរួមពីឥស្សរជន និងថ្នាក់ដឹកនាំចលនាកីឡាអូឡាំពិកអាស៊ី និងអន្តរជាតិប្រមាណ ៤០០នាក់ មកពី ៥៥ប្រទេស ជុំវិញពិភពលោកចូលរួម និងប្រតិភូមកពីបណ្តាប្រទេសក្រុមប្រឹក្សាអូឡាំពិកអាស៊ី ចំនួន ៤៥ប្រទេស។

បន្ទាប់ពីទទួលបានមេដាយ ឯកឧត្តមរដ្ឋមន្ត្រី បានមានប្រសាសន៍ថា ជាមេដាយដែលបានផ្តល់កិត្តិយសយ៉ាងក្រៃលែងដល់កម្ពុជា ផ្តល់កិត្តិយសដល់កីឡាករ កីឡាការិនី គ្រូបង្វឹក សហព័ន្ធកីឡាជាតិ និងក្រសួងអប់រំ យុវជន និងកីឡាផងដែរ។ ព្រមជាមួយនោះ ក៏ជាកិត្តិយសរាល់ការចូលរួមពីចលនាអូឡាំពិកទាំងអស់ ដែលបានគាំទ្រចលនាអូឡាំពិកនៅកម្ពុជា។

ក្នុងឱកាសនោះដែរ ឯកឧត្តម **វ៉ាត់ ចំរើន** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា (NOCC) ក៏បានអបអរសាទរទៅដល់ឯកឧត្តម **ថោង ខុន** ដែលទទួលបាននៅគ្រឿងឥស្សរិយយសនេះ នៅក្នុងការលះបង់ទាំងកម្លាំងកាយចិត្តក្នុងការចូលរួមគ្រប់ចលនាអូឡាំពិក ក៏ដូចជាសកម្មភាពកីឡាកន្លងមក៕

# ឯកអគ្គរដ្ឋទូតជប៉ុន៖ ទឹកផឹកសុវត្ថិភាពធានាបាននូវគុណភាពជីវិត

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ រដ្ឋាករទឹកក្រុងភ្នំពេញ*



ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ លើកឡើងថាទឹកផឹកសុវត្ថិភាពធានាបាននូវគុណភាពជីវិត





ឯកឧត្តម ឡុង ណារ៉ូ បង្ហាញពីខ្សែសង្វាក់ផលិតកម្មក្នុងរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតភូមិព្រែក រាជធានីភ្នំពេញ

ឯកឧត្តម **មិកាមិ ម៉ាសាហ៊ីរ៉ូ** ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា បានលើកឡើងថា ទឹកផឹកសុវត្ថិភាពធានាបាននូវគុណភាពជីវិត។ ឯកឧត្តមមានប្រសាសន៍បែបនេះ ក្នុងឱកាសអញ្ជើញទៅធ្វើទស្សនកិច្ច នៅរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតភូមិព្រែក នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០២២។

ឯកឧត្តម ឯកអគ្គរដ្ឋទូតជប៉ុនសង្ឃឹមថា រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតភូមិព្រែកនេះ នឹងធានាបាននូវគុណភាពជីវិតរបស់ប្រជាជនកម្ពុជា និងជួយពង្រឹងចំណងមិត្តភាពរវាងជប៉ុន និងកម្ពុជា ផងដែរ។ សមិទ្ធផលនេះ ត្រូវបានមជ្ឈដ្ឋានជុំវិញពិភពលោក មានការភ្ញាក់ផ្អើលងឿងឆ្ងល់ និងកោតស្ញប់ស្ញែង ហើយគេសំដៅថាជា " ភាពអស្ចារ្យនៃទីក្រុងភ្នំពេញ "។

គួរឱ្យដឹងផងដែរថា កន្លែងដែលទឹកផឹកសុវត្ថិភាពទទួលបានដោយគ្រាន់តែបើកក្បាលរ៉ូប៊ីណេនៅអាស៊ីអាគ្នេយ៍នោះ គឺមានតែនៅ សិង្ហបុរី និងរាជធានីភ្នំពេញរបស់កម្ពុជាប៉ុណ្ណោះ។



រូបថតអនុស្សាវរីយ៍
ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ និងឯកឧត្តម ឡុង ណារ៉ូ

ការទទួលបានទឹកផឹកសុវត្ថិភាពនេះ គឺដោយមានកិច្ចសហប្រតិបត្តិការ រវាងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានចាប់ផ្តើមតាំងពីទសវត្សរ៍ទី៩០ មកម្ល៉េះ ហើយក៏បានសម្រេចនូវសមត្ថភាពផ្គត់ផ្គង់ទឹកខ្ពស់ ស្តង់ដារគុណភាពទឹកខ្ពស់ និងការគ្របដណ្តប់យ៉ាងទូលំទូលាយនៃប្រព័ន្ធផ្គត់ផ្គង់ទឹកក្នុងរយៈពេល ២០ឆ្នាំកន្លងមកនេះ។

ដោយឡែក ដើម្បីផ្លាស់ប្តូរចំណេះដឹង និងបង្កើតបណ្តាញទំនាក់ទំនងជាមួយអ្នកជំនាញទឹកស្អាតនៅក្នុងប្រទេសកម្ពុជា អាស៊ីអាគ្នេយ៍ និងទូទាំងពិភពលោក កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ឡុង ណារ៉ូ** អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ព្រមទាំងថ្នាក់ដឹកនាំ បានប្រារព្ធពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា តាមរយៈប្រព័ន្ធអនឡាញ ជាមួយសមាគមទឹកស្អាតអន្តរជាតិ (IWA) ស្តីពីកិច្ចសហការក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស។

ពិធីចុះអនុស្សរណៈខាងលើនេះ មានគោលដៅរួមសំខាន់ៗ ចំនួនបី គឺ ទី១-សហការ និងសម្របសម្រួលព្រឹត្តិការណ៍ក្នុងស្រុក តំបន់ និងអន្តរជាតិ ដែលអាចផ្តល់ឱកាសក្នុងការផ្លាស់ប្តូរចំណេះដឹង និងបង្កើតបណ្តាញទំនាក់ទំនងជាមួយអ្នកជំនាញទឹកស្អាតនៅក្នុងប្រទេសកម្ពុជា អាស៊ីអាគ្នេយ៍ និងទូទាំងពិភពលោក។ ទី-២ លើកកម្ពស់ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ជំនាញតាមរយៈការសម្របសម្រួលផ្សារភ្ជាប់ទំនាក់ទំនង និងការចែករំលែកចំណេះដឹងជាមួយបណ្តាញទំនាក់ទំនងអ្នកជំនាញទឹកស្អាតរបស់ភាគីទាំងសងខាងឱ្យកាន់តែទូលំទូលាយ និងទី៣- បង្កើនឥទ្ធិពលសមាគមទឹកស្អាតនៅកម្ពុជា និងការលើកកម្ពស់កិត្តិសព្ទរបស់ រ.ទ.ស.ភ នៅលើពិភពលោក។៕




សកម្មភាពឯកឧត្តម ឡុង ណារ៉ូ ព្រមទាំងថ្នាក់ដឹកនាំអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាតាមរយៈប្រព័ន្ធអនឡាញរវាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងសមាគមទឹកស្អាតអន្តរជាតិ IWA ផ្សាយចេញពីអង្គភាពរដ្ឋាករទឹក

# ធនាគារពិភពលោកព្យាករកំណើនសេដ្ឋកិច្ចកម្ពុជា មាន ៤,៨% ក្នុងឆ្នាំ២០២២

*អត្ថបទ ៖ សាត សុផល , រូបថត ៖ ឯកសារ*




ផ្សារធំថ្មីដែលបម្រើអាជីវកម្មដឹមមាញឹក



សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងឱកាសបញ្ជាគ្រឿងយន្តច្រូតកាត់ផលស្រូវ





សកម្មភាពលើកដាក់ទំនិញនៅផែកុងតឺន័រខេត្តព្រះសីហនុ

យោងតាមរបាយការណ៍របស់ធនាគារពិភពលោក ចេញផ្សាយកាលពីថ្ងៃទី២៧ ខែកញ្ញា បានព្យាករណ៍ជាថ្មីម្តងទៀតថា នៅឆ្នាំ២០២២ កំណើនសេដ្ឋកិច្ចកម្ពុជា នឹងកើនដល់ ៤,៨ ភាគរយ និងឆ្នាំ២០២៣មានកំណើន ៥,២ ភាគរយ។ កាលពីខែមិថុនា ឆ្នាំ២០២២ កន្លងទៅ ធនាគារពិភពលោក បានព្យាករសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំនេះ មានកំណើនត្រឹម ៤,៥ ភាគរយ ប៉ុន្តែនៅពេលនេះ បានដំឡើងអត្រាកំណើននេះ រហូតដល់ ៤,៨%។

ដោយឡែក នាពេលថ្មីៗនេះ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក៏បានចេញការព្យាករនូវកំណើនសេដ្ឋកិច្ចកម្ពុជា នៅក្នុង







អ្នកឧកញ៉ា ម៉ុង រិទ្ធី ពិនិត្យមើលសកម្មភាពកម្មករចៀរជ័រកៅស៊ូ



ប្រជាពលរដ្ឋដាំដំណាំបន្លែគ្រប់ប្រភេទ បន្ទាប់ពីដំណាំស្រូវ



ឆ្នាំ២០២២ មានកំណើន ៥,៣% ប៉ុន្តែបានបន្ទាបការព្យាករ អត្រាកំណើន នៅឆ្នាំ២០២៣ ពី ៦,៥% មកនៅត្រឹម ៦,២% ដោយសារការចុះខ្សោយ នៃកំណើនសេដ្ឋកិច្ចពិភពលោក។

ចំពោះរាជរដ្ឋាភិបាលកម្ពុជាវិញ សម្រាប់ឆ្នាំ២០២២ បានព្យាករណ៍ថា កំណើនសេដ្ឋកិច្ច នឹងអាចសម្រេចបានក្នុងរង្វង់ ៥,៤% ដោយផ្អែកលើកំណើននៃតម្រូវការក្រៅប្រទេស និងការកើនឡើងវិញនៃការវិនិយោគទាំងក្នុងប្រទេស និងក្រៅប្រទេស។

អ្នកសេដ្ឋកិច្ចកម្ពុជា បានទទួលយកចំពោះការព្យាកររបស់ធនាគារពិភពលោកនេះ ដោយសារពិនិត្យលើលទ្ធភាពកម្រិតនៃការនាំចេញរបស់កម្ពុជា មានកំណើនខ្ពស់ ជាពិសេសការនាំចេញទៅប្រទេសសហរដ្ឋអាមេរិក និងទៅអឺរ៉ុប ដូចជា សម្លៀកបំពាក់ សម្ភារធ្វើដំណើរ និងកង់ជាដើម មានសន្ទុះកើនឡើងច្រើនរហូតដល់ជាង ២០ភាគរយ។ ដោយឡែកវិស័យសារពើពន្ធក៏ប្រមូលចំណូលបានលើសផែនការកំណត់ នៅឆ្នាំ ២០២២នេះ។ ចំណែកដំណើរការអាជីវកម្ម និងសកម្មភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋខ្មែរ មានស្ថានភាពល្អប្រសើរច្រើន។ ជាក់ស្តែងដូចជា កំណើនក្នុងវិស័យទេសចរណ៍ មានពលរដ្ឋធ្វើដំណើរកម្សាន្តច្រើន រួមទាំងការហូរចូលនូវវត្តមានទេសចរអន្តរជាតិ ដែលបង្ហាញពីចរន្តសេដ្ឋកិច្ចតាមរយៈការចាយវាយរបស់ភ្ញៀវទេសចរ។

ចំពោះវិស័យសំណង់បច្ចុប្បន្ន ក៏មានការរីកដុះដាលគួរកត់សម្គាល់ ដោយមានការសាងសង់ជាបន្តបន្ទាប់។ ទន្ទឹមនេះ វិស័យអចលទ្រព្យ ក៏មានចរន្តទិញលក់ ដោយរក្សាបានលំនឹងសេដ្ឋកិច្ចសង្គម។

រីឯវិស័យឧស្សាហកម្មនៅកម្ពុជា ក៏ដំណើរការល្អ ដោយមានការផលិតសម្ភារប្រើប្រាស់ផ្សេងៗ និងផ្នែកសហគ្រាសធនតូច និងមធ្យម បានរួមចំណែកសំខាន់ក្នុងការផលិត ម្ហូបអាហារ នំចំណី ជាដើម។ ចំណែកឧស្សាហកម្មរ៉ែមាស ជាប្រភពនៃចំណូលសួយសារពិសេស ដែលអាចរកប្រាក់ចំណូលចាក់ចូលក្នុងសេដ្ឋកិច្ចជាតិផងដែរ៕





# សមាគម TYDA ចុះពិនិត្យព្យាបាលជំងឺទូទៅ និងជំងឺមាត់ធ្មេញ ជូនប្រជាជនក្នុងតំបន់ទួលសំបូរ សង្កាត់ព្រៃវែង ខណ្ឌដង្កោរ

*អត្ថបទ ៖ សាត សុផល , រូបថត៖ ក្រុមការងារ TYDA*



លោកជំទាវ ពេជ ចន្ទមុន្នី ចែកអំណោយដល់កុមារ

លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី** អនុប្រធានក្រុមប្រឹក្សាភិបាល សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជន សម្តេចតេជោ (TYDA) បានដឹកនាំក្រុមការងារនិងកម្លាំងស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺទូទៅ និងជំងឺមាត់ធ្មេញជូនដល់ប្រជាជនក្នុងសហគមន៍ក្រីក្រនៅក្នុងតំបន់ទួលសំបូរ សង្កាត់ព្រៃវែង ខណ្ឌដង្កោរ ក្នុងបរិវេណសាលាបឋមសិក្សាទួលសំបូរ ដោយមានការចូលរួម













លោកជំទាវ ពេជ ចន្ទមុន្នី និងក្រុមគ្រូពេទ្យTYDA ចុះជួយពិនិត្យសុខភាពជូនប្រជាពលរដ្ឋ





ពីថ្នាក់ដឹកនាំក្រុមការងារ កម្លាំងស្ម័គ្រចិត្តនៃសមាគម TYDA អាជ្ញាធរមូលដ្ឋាន យុវជន និងផ្នែកដែលពាក់ព័ន្ធផ្សេងទៀត កាលពីចុងសប្តាហ៍ទី៣ ខែតុលា ។

លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី** បានមានប្រសាសន៍ថា សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត តែងតែយកចិត្តទុកដាក់គិតគូរអំពីសុខភាពរបស់បងប្អូនប្រជាពលរដ្ឋតាមរយៈការបង្កិតសេវាព្យាបាលប្រជាពលរដ្ឋដោយឥតគិតថ្លៃ។ ជាក់ស្តែង សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) បានចុះព្យាបាលបងប្អូនប្រជាពលរដ្ឋនៅតាមបណ្តាខេត្តសហគមន៍ អង្គការ មជ្ឈមណ្ឌលកុមារកំព្រា និងសាលារៀនជាដើម ។

លោកជំទាវ បានបញ្ជាក់ថា  នេះជាសកម្មភាពថ្មីក្នុងការចុះពិនិត្យព្យាបាលដល់ប្រជាជនក្នុងសហគមន៍ក្រីក្រជាយរាជធានីភ្នំពេញ ដែលពីមុនមកសកម្មភាពនេះ ជាសកម្មភាពចុះអប់រំសុខភាពតាមខ្ទងផ្ទះដល់សហគមន៍ ហើយនេះជាលើកទី២ហើយ ដែលចុះព្យាបាលដល់សហគមន៍ក្រីក្រដើម្បី





លោកជំទាវ ពេជ ចន្ទមុន្នី សំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ



បង្ខិតការផ្តល់សេវាសុខភាពជូនដល់ប្រជាជនដែលនៅក្នុងតំបន់សហគមន៍ក្រីក្រ។

សូមបញ្ជាក់ផងដែរថា សមាគម TYDA ធ្លាប់បានចុះទៅអប់រំសុខភាព និងចុះចែកអំណោយជូនដល់សហគមន៍ដែលទទួលរងគ្រោះដោយទឹកជំនន់ព្រែកត្នោត និងបានចុះអប់រំសុខភាពមាត់ធ្មេញដល់សិស្សានុសិស្សនៅក្នុងសាលាបឋមសិក្សាទួលសំបូរនេះផងដែរ ៕



# ឯកឧត្តម ណុប ចាន់ណារិទ្ធ៖ ភាពរឹងមាំនៃការខារីកចម្រើន មិនអាចឃ្លាតចេញពីការធ្វើអធិការកិច្ចនោះបានឡើយ

*អត្ថបទ ៖ សៅ សុវណ្ណ , រូបថត ៖ វ៉ាន់ ច័ន្ទភិរុណ*



ឯកឧត្តម ណុប ចាន់ណារិទ្ធ អញ្ជើញឡើងមានមតិក្នុងសន្និសីទសារព័ត៌មាន



ឯកឧត្តម ណុប ចាន់ណារិទ្ធ



ឯកឧត្តម ផៃ ស៊ីផាន

ឯកឧត្តម **ណុប ចាន់ណារិទ្ធ** អ្នកនាំពាក្យក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជារដ្ឋលេខាធិការទទួលបន្ទុកការងារជួយលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព ព្រឹទ្ធសភា និងអធិការកិច្ចបានមានប្រសាសន៍ថា គ្រប់ស្ថាប័ន បើទោះជាអង្គភាពនោះមិនមែនរដ្ឋក៏ដោយ ការដាក់ចេញនូវផែនការងាររួចហើយចាំបាច់ណាស់ត្រូវតែមានការតាមដានត្រួតពិនិត្យ ( ធ្វើអធិការកិច្ច ) នូវរាល់សកម្មភាពដែលបានអនុវត្តន៍ ដើម្បីចាត់វិធានការបង្ការទប់ស្កាត់នូវរាល់សកម្មភាពអសកម្មនានា ឬត្រូវដោះស្រាយបត់បែនឱ្យ

ទាន់តម្រូវការជាក់ស្តែងទើបមានភាពរឹងមាំ និងមានការរីកចម្រើន។

ការលើកឡើងរបស់ឯកឧត្តម **ណុប ចាន់ណារិទ្ធ** បែបនេះនៅក្នុងឱកាសដែលឯកឧត្តមដឹកនាំប្រតិភូក្រសួងចូលរួមធ្វើសន្និសីទសារព័ត៌មានស្តីពីវឌ្ឍនភាព ៥ឆ្នាំ ដែលរៀបចំឡើងដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីខែកញ្ញា ឆ្នាំ ២០២២ កន្លងទៅ។

ឯកឧត្តម **ណុប ចាន់ណារិទ្ធ** បានបន្តទៀតថា បច្ចុប្បន្ននេះ កម្ពុជា បានដាក់ ចេញ នូវគោលនយោបាយរដ្ឋាភិបាលឌីជីថល ក្នុងនោះ " **ភាពជាអ្នកដឹកនាំ និងបរិវត្តកម្ម នៃវិស័យអធិការកិច្ច ក្នុងយុគសម័យ ឌីជីថល** " ក៏ជាតម្រូវ ការចាំបាច់ឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់ និងស្ថាប័នទាំងថ្នាក់ជាតិ ក្រោមជាតិ និងស្ថាប័នដែលមិនមែនរដ្ឋ ត្រូវតែរៀបចំអភិវឌ្ឍន៍ខ្លួនទាំងធនធាន បញ្ញា និងរបៀបរបបការងារទៅតាមបរិបទថ្មី នៃជំនាន់ឌីជីថល៤.0 ផងដែរ។

ឯកឧត្តមបានគូសបញ្ជាក់ច្បាស់ថា ដើម្បីអភិវឌ្ឍន៍ភាពជាថ្នាក់ដឹកនាំ ចាំបាច់ណាស់យើងត្រូវបង្កើនប្រសិទ្ធភាព ក៏ដូចជាប្រសិទ្ធផលនៃការរៀនសូត្រ ហើយក៏បានផ្លាស់ប្តូរជាវិជ្ជមាននូវទម្លាប់ ផ្នត់គំនិត នៃការងារស្របនឹងបច្ចុប្បន្នភាព និងទៅអនាគត។

ឯកឧត្តមរដ្ឋលេខាធិការឱ្យដឹងថា ឆ្លងតាមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅភារកិច្ចឆ្នាំ២០២២ កន្លងទៅ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រោមការដឹកនាំរបស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** បានដាក់ចេញជាយន្តការយុទ្ធសាស្ត្រជាច្រើនដើម្បីបម្រើឱ្យវិស័យអធិការកិច្ច និងការដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហារ ពិសេសការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ។ ក្នុងនោះ ក្រសួងក៏បានរៀបចំប្រព័ន្ធគ្រប់គ្រង និងប្រព័ន្ធព័ត៌មានវិទ្យា ដូចជា មានរៀបចំឱ្យមានបណ្ណាល័យអេឡិចត្រូនិច និងការទទួលពាក្យបណ្តឹងតាមអនឡាញដើម្បីជួយសម្រួលដល់គ្រប់ភាគីពាក់ព័ន្ធដែលចង់ដឹងពីការសរសេរពាក្យបណ្តឹង និងដាក់ពាក្យបណ្តឹងមកកាន់ក្រសួង កាន់តែលឿនប្រកបដោយប្រសិទ្ធភាព៕




រូបថតអនុស្សាវរីយ៍

# កីឡាវ៉ូវីណាមកម្ពុជា ប្តេជ្ញាឆ្ពោះដណ្តើមមេដាយមាស ៩គ្រឿង ក្នុងឋានៈជាម្ចាស់ផ្ទះស៊ីហ្គេម ២០២៣

*អត្ថបទ ៖ ហេង ណាលីន , រូបថត ៖ ខឹម សុវណ្ណារ៉ា*




កីឡាករ កីឡាការិនីវូវីណាមកម្ពុជាថតរូបជុំគ្នា ក្រោយពិធីបំពាក់មេដាយស៊ីហ្គេមលើកទី៣១នៅប្រទេសវៀតណាម

បន្ទាប់ពីឈរនៅចំណាត់ថ្នាក់លេខ១ ក្នុងចំណោម ១៥ ប្រភេទកីឡាដែលដណ្តើមបានមេដាយពីការប្រកួតកីឡាស៊ីហ្គេមលើកទី៣១ នៅទីក្រុងហាណូយ ប្រទេសវៀតណាមកាលពីខែឧសភា ឆ្នាំ២០២២ ប្រភេទកីឡាវ៉ូវីណាមកម្ពុជាកាន់តែសម្រួចគោលដៅបន្ថែមដើម្បីត្រៀមលក្ខណៈទាំងផ្នែកការរៀបចំ និងគុណភាពបច្ចេកទេសរបស់កីឡាករ កីឡាការិនី ជម្រើសជាតិឱ្យកាន់តែមុតស្រួចក្នុងដំណើរឆ្ពោះទៅធ្វើម្ចាស់ផ្ទះបន្តវេន ស៊ីហ្គេមលើកទី៣២ ឆ្នាំ២០២៣ ដែលជាកំណត់ត្រាប្រវត្តិសាស្ត្រដំបូងរបស់កម្ពុជា ក្រោយរង់ចាំអស់រយៈពេល៦៤ឆ្នាំ ។

ឯកឧត្តម **អ៊ូ រតនា** ប្រធានសហព័ន្ធកីឡាវ៉ូវីណាមកម្ពុជា បានផ្តល់បទសម្ភាសន៍ដោយឡែកមួយ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP ថា នៅក្នុងផែនការយុទ្ធសាស្ត្រត្រៀមឆ្ពោះទៅធ្វើម្ចាស់ផ្ទះស៊ីហ្គេម ឆ្នាំ២០២៣ សហព័ន្ធកំពុងត្រៀមរៀបចំចំនួន ៣៣វិញ្ញាសា ខណៈសន្ទស្សន៍មេដាយមាស ដែលដាក់ចេញដោយគណៈកម្មាធិការជាតិ CAMSOC មានរហូតដល់ ៩គ្រឿង ។ ឯកឧត្តមបន្តថា សន្ទស្សន៍មេដាយមាស ៩គ្រឿង របស់ប្រភេទកីឡាដ៏មានសក្តានុពលរបស់កម្ពុជាមួយនេះ គឺស្ថិតនៅក្នុង



ឯកឧត្តម អ៊ូ រតនា ប្រធានសហព័ន្ធកីឡាវ៉ូវីណាមកម្ពុជា ផ្តល់កិច្ចសម្ភាសន៍




សកម្មភាពប្រកួតស៊ីហ្គេម លើកទី៣១របស់ក្រុមជម្រើសជាតិវូវីណាមកម្ពុជា





ការហ្វឹកហាត់បំប៉នបច្ចេកទេសរបស់ក្រុមជម្រើសជាតិវូវីណាមកម្ពុជា ត្រៀមទៅស៊ីហ្គេម លើកទី៣២ ឆ្នាំ២០២៣

ចំណាត់ថ្នាក់លេខ២បន្ទាប់ពីប្រភេទកីឡាតេក្វាន់ដូ អាយ.ធី.អេហ្វ (ITF) ដែលត្រូវបានដាក់គោលដៅស ន្ទ ស្សន៍មេដាយមាស រហូតដល់ ១៥គ្រឿង។

ក្នុង ៣៣វិញ្ញាសានេះ គឺមានផ្នែកប្រយុទ្ធ ៩ប្រភេទទម្ងន់ និង សម្តែង មេគុ នការពារខ្លួន ចំនួន២៤ ។ ឯកឧត្តមប្រធានសហព័ន្ធរូបនេះបញ្ជាក់ថា ការដាក់វិញ្ញាសាសម្តែងមេគុនដល់ ២៤នេះ គឺដោយសារវូវីណាមកម្ពុជាមានសក្តានុពលខ្លាំង ដែលអាចឈានដល់កម្រិតមេដាយមាសចំនួន ៩គ្រឿង។ឯកឧត្តមបានបន្តទៀតថា វូវីណាមកម្ពុជា ត្រូវបានដាក់សន្ទស្សន៍មេដាយមាសឈរនៅចំណាត់ថ្នាក់លេខ២ បន្ទាប់ពីប្រភេទកីឡាតេក្វាន់ដូ ITF នៃគោលដៅមេដាយមាស ១៥គ្រឿង ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ ក្នុងចង្កោមប្រភេទកីឡា យុទ្ធគុនចម្រុះដូចជា វូវីណាម តេក្វាន់ដូ ITFគុនល្បុក្កតោ ជាដើម ។

ឯកឧត្តម **អ៊ូ រតនា** ចាត់ទុកថា ការដណ្តើមមេដាយមាស ៩គ្រឿងនៃការធ្វើម្ចាស់ផ្ទះ ស៊ីហ្គេម ឆ្នាំ២០២៣នេះ គឺជាការ









សកម្មភាពប្រកួតស៊ីហ្គេមលើកទី៣១ របស់ក្រុមជម្រើសជាតិវ៉ូវីណាមកម្ពុជា

លំបាក ប៉ុន្តែទោះយ៉ាងណា ថ្នាក់ដឹកនាំ គ្រូបង្វឹកផូបនិងកីឡាករ កីឡាការិនីទាំងអស់កំពុងតែពុះពារក្នុងការហ្វឹកហាត់យ៉ាងខ្លាំងក្លា ទាំងពេលព្រឹក និងពេលល្ងាច ដើម្បីដើរលើមាគ៌ាឆ្ពោះទៅរកភាពជោគជ័យជូនជាតិ ក្នុងឋានៈជាម្ចាស់ផ្ទះព្រឹត្តិការណ៍កីឡាដ៏ធំប្រចាំតំបន់រៀងរាល់ឆ្នាំម្តង ជាលើកដំបូងនេះ ។

សូមជម្រាបថា វ៉ូវីណាមកម្ពុជា បានឈ្នះមេដាយមាស៣ ប្រាក់២ និងសំរឹទ្ធ៩ សរុប ១៤គ្រឿង ឈរនៅចំណាត់ថ្នាក់លេខ ១ នៃ ១៥ប្រភេទកីឡា ដែលឈ្នះមេដាយស៊ីហ្គេម ២០២២ នៅវៀតណាម នៅក្នុងចំណោម ៣៣ប្រភេទកីឡារបស់កម្ពុជា ដែលចាត់បញ្ជូនចូលរួមប្រកួត ស៊ីហ្គេម វៀតណាម ។

នៅក្នុងការប្តេជ្ញាចិត្តដ៏ខ្ពង់ខ្ពស់ ក្នុងការឈានទៅសម្រេចជោគជ័យជូនជាតិ ឯកឧត្តម **អ៊ូ រតនា** ក៏បានបង្ហាញឆន្ទៈដ៏មោះមុតបន្ថែមទៀត នៅក្នុងមហាសន្និបាតបូកសរុបលទ្ធផលការងារ និងលើកទិសដៅបន្ត ឆ្នាំ២០២២-២០២៣ ដោយបានជំរុញដល់មន្ត្រីសហព័ន្ធ គ្រូបង្វឹក កីឡាករ កីឡាការិនីជម្រើសជាតិទាំងអស់រួមគ្នា ដើម្បីការពារមេដាយមាស ៣គ្រឿងក្នុងស៊ីហ្គេមលើកទី៣១ និងបង្កើនមេដាយមាសឱ្យបាន ៦គ្រឿងបន្ថែម ដើម្បីដើរតម្រង់ទិសទៅសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ ឆ្នាំ២០២៣ (CAMSOC) ។

ឯកឧត្តម **អ៊ូ រតនា** គូសបញ្ជាក់ថា ចំពោះការសម្រេចគោលដៅទាំងនេះ គឺអាស្រ័យដោយការខិតរួមគ្នារបស់ថ្នាក់ដឹកនាំសហព័ន្ធ និងការខិតខំហ្វឹកហាត់ទ្វេដងរបស់កីឡាករ កីឡាការិនីជម្រើសជាតិដែលជាអ្នកអនុវត្តន៍ផ្ទាល់ក្នុងការសម្រួចទៅរកជោគជ័យ។ ឯកឧត្តមបានក្រើនរម្លឹកដល់ក្រុមជម្រើសជាតិត្រៀមស៊ីហ្គេម ឆ្នាំ២០២៣ ទាំងអស់គ្នាដើម្បីឈានឆ្ពោះទៅដណ្តើមមេដាយមាសឱ្យបានទាំង ៩វិញ្ញាសានេះ គឺមានប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសជាង ១៦លាននាក់នៅរង់ចាំផ្តល់កម្លាំងចិត្ត ការគាំទ្រយើងទាំងអស់គ្នាដើម្បីមោទកភាពជាតិក្នុងនាមជាម្ចាស់ផ្ទះព្រឹត្តិការណ៍ដ៏ធំជាប្រវត្តិសាស្ត្រដំបូងនេះ។ «កាលពីស៊ីហ្គេម ឆ្នាំ២០២២ នៅវៀតណាម ប្រភេទកីឡា វ៉ូវីណាមកម្ពុជា ដណ្តើមបានមេដាយមាស ៣គ្រឿង ពេលនោះយើងបានហ្វឹកហាត់ ១០០ភាគរយ។ ដូច្នេះដំណើរឆ្ពោះទៅធ្វើម្ចាស់ផ្ទះ ស៊ីហ្គេម ២០២៣ យើងត្រូវហ្វឹកហាត់ទ្វេដង ដើម្បីការពារមេដាយមាស ៣គ្រឿងហើយៗត្រូវបង្កើនការស្វែងរកមេដាយមាស ៦គ្រឿងបន្ថែម ដើម្បីឱ្យសម្រេចបានមេដាយ ៩គ្រឿង តាមសន្ទស្សន៍មេដាយរបស់គណៈកម្មាធិការជាតិ CAMSOC ក៏ដូចជារាជរដ្ឋាភិបាល »។ ឯកឧត្តមប្រធានសហព័ន្ធបានលើកឡើងដែរថា៖ «នេះជាការលំបាក ប៉ុន្តែខ្ញុំជឿជាក់ថា ក្រុមជម្រើសជាតិកម្ពុជានឹងអាចធ្វើបាន ដើម្បីឱ្យការព្យាយាមពុះពាររបស់ប្រភេទកីឡាវ៉ូវីណាមកម្ពុជា សម្រេចជោគជ័យជាប្រវត្តិសាស្ត្រជូនជាតិ» ។

ជាមួយគ្នានោះ ឯកឧត្តម **យ៉ា ថៃសាន** អគ្គលេខាធិការសហព័ន្ធកីឡាវ៉ូវីណាមកម្ពុជា បានលើកបង្ហាញពីសមិទ្ធផលដែលសម្រេចបាននាពេលកន្លងមក ក៏ដូចជាគោលដៅបន្តដែរ ជាពិសេសគឺសហព័ន្ធមានសាមគ្គីភាពផ្ទៃក្នុងល្អ ទាំងថ្នាក់ដឹកនាំ ប្រធានកិត្តិយស អនុប្រធានកិត្តិយស សមាជិកប្រតិបត្តិ ទីប្រឹក្សាជាន់ខ្ពស់ តែងមានទឹកចិត្ត ជួយឧបត្ថម្ភទាំងថវិកា និងស្មារតីធ្វើឱ្យសហព័ន្ធមានដំណើរការល្អ។ បន្ថែមពីលើនេះ សហព័ន្ធ




ពិធីចំពាក់មេដាយជូនដល់ម្ចាស់មេដាយវិញ្ញាសា
ក្រុមប្រភេទកីឡាវ៉ូវីណាមកម្ពុជា




ម្ចាស់មេដាយវិញ្ញាសាក្រុមសម្តែងការពារខ្លួនស្រី១ ប្រុស៣(មានអាវុធ)

ជ្រើសរើសបានអាជ្ញាកណ្តាលដែលមានគុណវុឌ្ឍិខ្ពស់ក្នុងការចូលរួមដឹកនាំ ការប្រកួតលក្ខណៈជាតិនិងអន្តរជាតិ។ជាមួយគ្នានោះ ឯកឧត្តមអគ្គលេខាធិការ ក៏បានលើកបង្ហាញចំណុចខ្សោយផងដែរ ដូចជានៅខ្វះមន្ត្រី ដែលមានចំណេះដឹងលើផ្នែកព័ត៌មានវិទ្យាផ្នែកភាសាបរទេសមន្ត្រីបច្ចេកទេសរៀបចំនិងដឹកនាំការប្រកួតមានបរិមាណនៅមានកម្រិត ខ្វះឧបករណ៍ សម្ភារស្តង់ដារ ហ្វឹកហាត់ ខ្វះឧបករណ៍អេឡិចត្រូនិកផ្តល់ពិន្ទុជាដើម ។

ឯកឧត្តម **យ៉ា ថៃសាន** សង្កត់ធ្ងន់ថា ចំពោះការងារត្រូវធ្វើបន្ទាប់គឺត្រៀមលក្ខណៈចូលរួមការប្រកួតកីឡា វ៉ូវីណាមជើងឯកទ្វីបអាស៊ី លើកទី៥ ចុងឆ្នាំ២០២២ នៅប្រទេសមីយ៉ាន់ម៉ា។ ទន្ទឹមនេះ ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលចៅក្រមអាជ្ញាកណ្តាលកម្រិតអន្តរជាតិ នាខែសីហា ឆ្នាំ២០២២។ ត្រៀមរៀបចំការប្រកួតជ្រើសរើសជើងឯកថ្នាក់ជាតិ ឆ្នាំ២០២២ នាខែសីហា ឆ្នាំ២០២២។ ត្រៀមរៀបចំការប្រកួតកីឡាជាតិ លើកទី៣ នាខែវិច្ឆិកា ឆ្នាំ២០២២។ ត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាវ៉ូវីណាមជើងឯកអាស៊ីអាគ្នេយ៍លើកទី៦ នាខែមីនា ឆ្នាំ២០២៣ ក្រោមការអនុញ្ញាត ជាគោលការណ៍ ពីគណៈកម្មាធិការជាតិ CAMSOC កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។ ឯកឧត្តមបានបន្ថែមថា ទាំងនេះ គឺជាការត្រៀមពង្រឹងគុណភាពទាំងការរៀបចំនិងការចូលរួមប្រកួតសំខាន់ៗ ដើម្បីត្រៀមលក្ខណៈឱ្យគ្រប់ជ្រុងជ្រោយលើមាគ៌ាឆ្ពោះទៅរកភាពជោគជ័យ នាស៊ីហ្គេម ឆ្នាំ២០២៣ ។

ជាមួយគ្នានេះដែរ កីឡាករ កីឡាការិនីជ័យលាភីមេដាយមាសស៊ីហ្គេម ២០២២ នៅវៀតណាមក៏បានបង្ហាញការតាំងចិត្តខ្ពស់ ដោយពង្រឹងបន្ថែមលើការហាត់ហ្វឹកហ្វឺន និងតែងទទួលបានការលើកទឹកចិត្តពីថ្នាក់ដឹកនាំសហព័ន្ធ ដើម្បីសម្រេចគោលដៅឆ្ពោះទៅប្រកួតប្រជែងមេដាយ ជូនជាតិ ក្នុងពេលកម្ពុជាធ្វើម្ចាស់ផ្ទះ ស៊ីហ្គេម នាខែឧសភា ឆ្នាំ២០២៣ ។

កីឡាករ វ៉ូវីណាម ជម្រើសជាតិកម្ពុជា **អេ វីរៈខាំឈីតតួថង** ដែលជាម្ចាស់មេដាយមាសទី៧ លើវិញ្ញាសាប្រយុទ្ធបុរសទម្ងន់ ៦៥គីឡូក្រាម បាននិយាយថា «សម្រាប់មេដាយមាសមួយនេះ មានអត្ថន័យខ្លាំងមែនទែន ចូលក្នុងបេះដូងរបស់ខ្ញុំតែម្តង ដោយសារមេដាយនេះ មិនមែនសម្រាប់ខ្ញុំទេគឺសម្រាប់ប្រជាជនទាំងអស់គ្នា បងប្អូនទាំងអស់គ្នា។ ប៉ាម៉ាក់ខ្ញុំ គាត់លើកទឹកចិត្តខ្ញុំ គាត់ជំរុញខ្ញុំរហូតដល់វគ្គផ្តាច់ព្រ័ត្រ។ សម្រាប់ស៊ីហ្គេម ឆ្នាំ២០២៣ ខ្ញុំនឹងប្តេជ្ញាចិត្តថា ធ្វើឱ្យអស់សមត្ថភាពដូចលើកនេះអ៊ីចឹង ឬក៏លើសហ្នឹងទៀត។ សំខាន់គឺខ្ញុំតាំងចិត្តខ្លួនឯងថានឹងខំប្រឹងឱ្យអស់ពីលទ្ធភាព ដើម្បីខ្លួនខ្ញុំផង ដើម្បីប្រទេសជាតិផង»។ នេះជាការបង្ហាញខ្លួនលើកដំបូងរបស់ **អេ វីរៈខាំឈីតតួថង** នៅស៊ីហ្គេម ហើយក៏ជាការឈ្នះមេដាយមាសដំបូងក្នុងស៊ីហ្គេម សម្រាប់កូនប្រុសអតីតស្តេចប្រដាល់គុនខ្មែរ **អេ តួថង** ។ ចំណែកឯ កីឡាការិនីដំឆ្នើម **ប៉ាល់ ឆរស្មី** ដែលជាម្ចាស់ជ័យលាភីមេដាយមាសជាច្រើនពីការប្រកួតអន្តរជាតិជាច្រើនបានបង្ហាញនូវក្តីរីករាយ និងប្តេជ្ញាបន្តដណ្តើមមេដាយជូនជាតិ ក្នុងឋានៈម្ចាស់ផ្ទះស៊ីហ្គេម លើកទី៣២ ឆ្នាំ២០២៣ ដែល **ប៉ាល់ ឆរស្មី** ចាត់ទុកថា ការចូលរួមប្រកួតនៅក្នុងព្រឹត្តិការណ៍អន្តរជាតិនៅផ្ទះខ្លួនឯង គឺជាកិត្តិយសសម្រាប់ខ្លួនឯង ជាតិនិងប្រជាពលរដ្ឋខ្មែរទាំងអស់ ព្រោះនេះជាប្រវត្តិសាស្ត្រដ៏ធំសម្រាប់ជាតិ។ កីឡាការិនី **ឆរស្មី** បានបញ្ជាក់ថា នៅពេលបញ្ចប់ស៊ីហ្គេម ២០២៣ នាងខ្ញុំនឹងសម្រាកពីជីវិតជាកីឡាការិនីហើយ ដោយ




ឯកឧត្តម វ៉ាត់ ចំរើន នាយបេសកកម្មស៊ីហ្គេមរបស់កម្ពុជា អញ្ជើញផ្តល់កិត្តិយសបំពាក់មេដាយជូនជ័យលាភីវូវីណាម ក្នុងស៊ីហ្គេមលើកទី៣១ ឆ្នាំ២០២២

សារ មានអាយុច្រើនហើយ។ «នាងខ្ញុំចង់ចូលរួមដណ្តើមមេដាយជូនជាតិ ក្នុងការប្រកួតស៊ីហ្គេម ឆ្នាំ២០២៣ ជាលើកចុងក្រោយរបស់នាងខ្ញុំ។ កាលពីមុន ខ្ញុំមិនធ្លាប់ដឹងថាអ្វីជាជម្រើសជាតិ អ្វីជាបទពិសោធន៍ក្នុងការប្រកួតអ្វីនោះទេ នៅពេលដែលនាងខ្ញុំចូលរួមហ្វឹកហាត់ និងប្រកួតអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ទើបខ្ញុំទទួលបានអារម្មណ៍ពិសេស ក្នុងពេលដែលដណ្តើមបានមេដាយជូនជាតិ វាជាពេលវេលាដ៏អស្ចារ្យ ក្នុងជីវិតរបស់នាងខ្ញុំ ក៏ដូចជាប្រទេសជាតិ។ កីឡាតំណាងឱ្យសន្តិភាព មិត្តភាព និងសាមគ្គីភាព។ ប្រសិនបើប្រទេសយើង គ្មានសន្តិភាព ប្រទេសយើងក៏មិនអាចទទួលរៀបចំធ្វើម្ចាស់ផ្ទះ ការប្រកួតកីឡាស៊ីហ្គេម ឬមានកីឡាណាបានដែរ» ។

កីឡាការិនីដ៏ឆ្នើម **ប៉ាល់ ឆរស្មី** បានចូលហ្វឹកហាត់កីឡាយូដូ ក្នុងការចាប់ផ្តើមដំបូង កាលពីឆ្នាំ១៩៩៦ ហើយនៅឆ្នាំ១៩៩៧ បានចូលហ្វឹកហាត់កីឡាតេក្វាន់ដូ ITF រហូតដល់ឆ្នាំ២០០៨ (ជម្រើសជាតិ)ហើយសម្រាក ៣ឆ្នាំដោយសារបញ្ហាសុខភាព រហូតដល់ឆ្នាំ២០១១ ទើបចូលហ្វឹកហាត់កីឡាវ៉ូវីណាម ក្នុងនាមជាកីឡាការិនីជម្រើសជាតិដល់ពេលបច្ចុប្បន្ននេះ។ ជាលទ្ធផលក្នុងការប្រកួតអន្តរជាតិកន្លងមក **ប៉ាល់ ឆរស្មី** ដណ្តើមបានមេដាយសរុប២២គ្រឿងក្នុងនោះស៊ីហ្គេមមេដាយមាស៣ សំរឹទ្ធ១។ ជើងឯកអាស៊ីអាគ្នេយ៍ មេដាយមាស ៥គ្រឿង (២០១១-២០១៩)។ មេដាយមាសជើងឯកអាស៊ី២០១៨ នៅឥណ្ឌូណេស៊ី ។ ជើងឯកពិភពលោក (២០១១-២០១៩ មេដាយប្រាក់១ និងមេដាយមាស២ និងអាស៊ានប៊ិចហ្គេម មេដាយមាស២០១៦ នៅវៀតណាម ៕




ឯកឧត្តម អ៊ូ រតនា និងប្រតិភូ កីឡាវូវីណាមកម្ពុជា បង្ហាញភាពរីករាយដណ្តើមមេដាយជូនជាតិ ក្រោយពិធីបំពាក់មេដាយស៊ីហ្គេមលើកទី៣១ នៅប្រទេសវៀតណាម

# សភាពាណិជ្ជកម្មខេត្តព្រះសីហនុផ្សព្វផ្សាយពីកាតព្វកិច្ច គណនេយ្យ សវនកម្មនិងបទបញ្ញត្តិពាក់ព័ន្ធ

*អត្ថបទនិងរូបថត៖ ឡាយ សារ៉ុម*




*លោកឧកញ៉ា វណ្ណា សុខហេង*

សភាពាណិជ្ជកម្ម ខេត្តព្រះសីហនុ បានបើកសិក្ខាសាលាផ្សព្វផ្សាយអំពីកាតព្វកិច្ចគណនេយ្យ សវនកម្មនិងបទបញ្ញត្តិពាក់ព័ន្ធសម្រាប់សហគ្រាសនៅក្នុងក្រុងព្រះសីហនុ ដោយមានម្ចាស់ក្រុមហ៊ុន ម្ចាស់សហគ្រាស ពាណិជ្ជករ អាជីវករ ចូលរួមជាច្រើននៅក្នុងក្រុងនៃខេត្តព្រះសីហនុ ដើម្បីសិក្សាស្វែងយល់អំពីច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធដែលបានបង្ហាញជូនដោយក្រុមមន្ត្រីជំនាញបច្ចេកទេសជាន់ខ្ពស់នៃនិយ័តករគណនេយ្យ និងសវនកម្ម នាព្រឹកថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ។

មានប្រសាសន៍នៅក្នុងកិច្ចប្រជុំ លោកឧកញ៉ា **វណ្ណា សុខហេង** ប្រធានសភាពាណិជ្ជកម្ម ខេត្តព្រះសីហនុ បានលើកឡើងថា ការបើកសិក្ខាសាលាផ្សព្វផ្សាយអំពីកាតព្វកិច្ចគណនេយ្យ និងសវនកម្មនិងបញ្ញត្តិពាក់ព័ន្ធសម្រាប់សហគ្រាសនាខេត្តព្រះសីហនុនាពេលនេះ គឺមានសារៈសំខាន់ ដើម្បីសិក្សាស្វែងយល់អំពីច្បាប់ស្ដីពីគណនេយ្យ និងសវនកម្មនិងបទបញ្ញត្តិពាក់ព័ន្ធ ដែលបង្ហាញជូនដោយក្រុមមន្ត្រីជំនាញបច្ចេកទេសជាន់ខ្ពស់នៃនិយ័តករគណនេយ្យ និងសវនកម្ម។

សភាពាណិជ្ជកម្មខេត្តព្រះសីហនុ គឺជាផ្នែកមួយដ៏សំខាន់នៃសភាពាណិជ្ជកម្មកម្ពុជាតំណាងឱ្យវិស័យឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ក៏ដូចជានៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកំណត់យ៉ាង




ច្បាស់ថាវិស័យឯកជន គឺជាក្បាលម៉ាស៊ីន នៃកំណើនសេដ្ឋកិច្ច។ ក្នុងន័យនេះសភាពាណិជ្ជកម្មខេត្តព្រះសីហនុ គឺជាតំណាងវិស័យឯកជនក្នុងខេត្តព្រះសីហនុ ដែលមានតួនាទីជាគន្លឹះដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម នៅក្នុងខេត្ត និងចូលរួមធ្វើឱ្យសម្រេចបាននូវគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើអាជីវកម្ម មូលដ្ឋានផលិតកម្ម ពាណិជ្ជកម្ម និងសេវាកម្មតាមរយៈដំណើរការអាជីវកម្មផ្សេងៗប្រកបដោយទំនួលខុសត្រូវ និង



*ម្ចាស់ក្រុមហ៊ុន សហគ្រាស ពាណិជ្ជករ អាជីវករ អញ្ជើញចូលរួម*




ឯកឧត្តម ប៊ូ ថារិន

ហិរញ្ញវត្ថុនៅតាមសហគ្រាសនានា អំពីច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទបញ្ញត្តិពាក់ព័ន្ធ ជាពិសេសកាតព្វកិច្ចជាសារវន្តចំនួន៣ ក្នុងនោះរួមមាន៖ ១-ការកាន់បញ្ជីគណនេយ្យ ២-ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារជាធរមាន និង៣-ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យសវនកម្មឯករាជ្យ តាមលក្ខខណ្ឌកំណត់តាមច្បាប់។ ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤



ម្ចាស់ក្រុមហ៊ុន សហគ្រាស ពាណិជ្ជករ អាជីវករ អញ្ជើញចូលរួម

តម្លាភាព។

ក្នុងឆ្នាំ២០២២ នេះសភាពាណិជ្ជកម្មខេត្តព្រះសីហនុ បានសហការជាមួយនឹងស្ថាប័នថ្នាក់ជាតិផ្សេងៗ បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីច្បាប់និយ័តកម្ម បទដ្ឋានគតិយុត្តិសំខាន់ៗមួយចំនួនដល់សមាជិក សមាជិកា ពាណិជ្ជករ អាជីវករ សេវាករ ក្នុងគោលដៅជាក់លាក់ ដើម្បីជួយដល់វិស័យឯកជននៅក្នុងខេត្តព្រះសីហនុ ដំណើរការមុខរបររបស់ខ្លួនឱ្យបានត្រឹមត្រូវ ចៀសផុតពីហានិភ័យផ្លូវច្បាប់មួយចំនួនដែលអាចកើតមានឡើងជាយថាហេតុ។

ឯកឧត្តម **ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យ និងសវនកម្មបានលើកឡើងថា សិក្ខាសាលានេះ ក្រុមការងារនិយ័តករគណនេយ្យ និងសវនកម្ម និងសភាពាណិជ្ជកម្មសាខាខេត្តព្រះសីហនុ បានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមទៀត ដល់នាយកក្រុមហ៊ុន សហគ្រាស និងអ្នកដែលមានការទទួលខុសត្រូវ លើកិច្ចការគណនេយ្យ និង

គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចបាន និងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពរួមទាំងកិច្ចអភិវឌ្ឍន៍ សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។



ម្ចាស់ក្រុមហ៊ុន សហគ្រាស ពាណិជ្ជករ អាជីវករ អញ្ជើញចូលរួម

# ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## បាននិងកំពុងជំរុញការអនុវត្តគម្រោងសាងសង់ ស្ថិតនៅរាជធានីភ្នំពេញ និងខេត្តកណ្តាល

*អត្ថបទ និងរូបថត ៖ វ៉ាន់ ច័ន្ទភិរុណា*



ឯកឧត្តម ថេង ច័ន្ទសង្វារ រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ថ្លែងក្នុងសន្និសីទសារព័ត៌មានស្តីពី « សមិទ្ធផលសម្រេចបានរយៈពេល ៥ឆ្នាំកន្លងមក » នៅទីស្តីការគណៈរដ្ឋមន្ត្រី



ឯកឧត្តម ថេង ច័ន្ទសង្វារ រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឯកឧត្តម **ថេង ច័ន្ទសង្វារ** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានមានប្រសាសន៍ថា មកដល់បច្ចុប្បន្នក្រសួងកំពុងរៀបចំគោលនយោបាយបន្ថែមទៀត នៅឆ្នាំ២០១៧ ស្តីពីការលើកទឹកចិត្ត និងរៀបចំកម្មវិធីជាតិ ដើម្បីអនុវត្តលំនៅឋាន ក្នុងការធានាឱ្យប្រជាពលរដ្ឋនៅទូទាំងប្រទេស មានលំនៅឋានសមរម្យ អាចរស់នៅប្រកបដោយសុខុមាលភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ជាពិសេសប្រជាពលរដ្ឋដែល មានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមងាយរងគ្រោះ ថ្លែងក្នុងសន្និសីទសារព័ត៌មានស្តីពី «សមិទ្ធផលសម្រេចបានរយៈពេល៥ឆ្នាំកន្លងមក របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់» កាលពីព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

ឯកឧត្តម រដ្ឋលេខាធិការ បានបន្តទៀតថា ការលើកទឹកចិត្តនិងរៀបចំកម្មវិធីជាតិ ដើម្បីអនុវត្តលំនៅឋាន រាជរដ្ឋាភិបាល បានសម្រេចឱ្យក្រសួងសហការជាមួយវិស័យឯកជន ហើយក្រសួងបាននិងកំពុងជំរុញការអនុវត្តន៍គម្រោងសាងសង់លំនៅឋានតម្លៃសមរ០ម្យបានចំនួន ៤គម្រោង នៅរាជធានីភ្នំពេញនិងខេត្តកណ្តាល ។

ជាមួយគ្នានេះផងដែរ ការអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សិទ្ធិទទួលបាន លំនៅឋានតម្លៃសមរម្យរបស់ប្រជាពលរដ្ឋ ក្រសួងបាននិងកំពុងជំរុញការអនុវត្តន៍គម្រោងសាងសង់ចំនួន ៤គម្រោង ស្ថិតនៅរាជធានីភ្នំពេញ និងខេត្តកណ្តាល មានចំនួន ៨,៣៣១ខ្នង និងចំណែកឯកជនចំនួន ២,៩៦០ខ្នង ដែលរួមមាន ទី១.ក្រុមហ៊ុន World Bridge Home Co.,Ltd អភិវឌ្ឍគម្រោង "លំនៅឋានទីក្រុងរណបសិរីមង្គល" ចំនួន ២,៤៥៧ខ្នង លើផ្ទៃដីទំហំ ២៤ហិកតា ស្ថិតនៅភូមិកោះគរ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល។ ក្រុមហ៊ុននេះ បានបញ្ចប់គម្រោងដំណាក់កាលទី ១ និង បានប្រគល់លំនៅឋានចំនួន ៦៨០ខ្នង ជូនប្រជាពលរដ្ឋនៅថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០២០ ហើយការសាង សង់ដំណាក់កាលទី ២ សម្រេចបាន ៩៥ភាគរយ។ ២.ក្រុមហ៊ុន B & BM Development Co.,Ltd អភិវឌ្ឍគម្រោង "បុរីសែនមនោរម្យព្រែកតាទែន" ចំនួន ៥,៣៤០ខ្នង លើផ្ទៃដីទំហំ ៨០ហិកតា ស្ថិតនៅភូមិ ស្លែងដីដុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល សម្រេចបាន ៩៣ភាគរយ។ ៣.ក្រុមហ៊ុន ARAKAWA Co.,Ltd អភិវឌ្ឍគម្រោង "លំនៅឋានអារ៉ាខាវ៉ា" ចំនួន ២,៩៦០។ ចំណែកឯកជនលើផ្ទៃដីទំហំ ១៣,៦៨០ម៉ែត្រក្រឡា ស្ថិតនៅភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ក្នុងនោះដំណាក់កាលទី ១ សម្រេចបាន ១០០ភាគរយ និងដំណាក់កាលទី ២ សម្រេចបាន ៧៧ភាគរយ និងទី៤ ក្រុមហ៊ុន ប៊ីអជីភី ប្រផឹធីឌីវេឡុបម៉ិន ឯ.ក អភិវឌ្ឍ "បុរីប្រេ្គនផាក" ចំនួន ៥៣៤ខ្នង លើផ្ទៃដីទំហំ ៥,១៦ ហិកតា ស្ថិតនៅភូមិទួលកី សង្កាត់ភ្លើងឆេះរទេះ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ក្នុងនោះ ដំណាក់កាលទី ១ សម្រេចបាន ១០០ភាគរយ និងដំណាក់កាលទី ២ សម្រេចបាន ១៣ភាគរយ ផងដែរ៕



ថ្នាក់ដឹកនាំក្រសួង អញ្ជើញចូលរួម



# ប្រទះឃើញបំណែកចម្លាក់ក្បាលនាគមួយផ្ទាំងមានរចនាប័ទ្មបាយ័ន ងើបចេញតាមឫសដើមស្រឡៅដែលបានរលំ

*អត្ថបទនិងរូបថត៖ លោក បូ សារី កែសម្រួលដោយ លីវ សុខុន*



ផ្ទាំងចម្លាក់ក្បាលនាគដែលប្រទះឃើញកប់ដី ក្រោមឫសឈើ



ថ្មីៗនេះ មានការប្រទះឃើញដោយចៃដន្យនូវបំណែកចម្លាក់ក្បាលនាគចំនួន១ ធ្វើពីថ្មភក់ស្ថិតក្នុងរចនាប័ទ្មបាយ័ន ក្រោយពេលដើមស្រឡៅធំមួយដើមបានដួលរលំបណ្ដាលឱ្យបំណែកក្បាលនាគដែលកប់ក្នុងដីជាយូរឆ្នាំមកហើយនោះត្រូវបានផុសឡើងតាមឫសឈើ នោះដែលស្ថិតនៅក្នុងបរិវេណវត្តទេពប្រណម្យ អតីតរាជធានីអង្គរធំ ។

លោក **ឈួក សុម៉ាឡា** ប្រធានក្រុមចុះបញ្ជីវត្ថុសិល្បៈ នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិ



លោក ឈូក សុម៉ាឡា ពិនិត្យមើលផ្ទាំងចម្លាក់ដែលជាប់នៅឫសឈើ



ចម្លាក់ក្បាលនាគដែលជាប់នៅក្រោមឫសឈើ



អ្នកជំនាញរៀបចំគាស់យកផ្ទាំងចម្លាក់ក្រោមឫសឈើ

អប្សរាបានឱ្យដឹងថា បំណែកក្បាលនាគនេះបានកប់ក្នុងដីជម្រៅប្រមាណកន្លះម៉ែត្រ ហើយជាក់ស្តែងដើមស្រឡៅ ដែលដុះពីលើមិនមានឫសកែវធំៗទេ ទើបពេលភ្លៀងជោគជាំទន់ដី ធ្វើឱ្យដួលរលំ និងផុសក្បាលនាគនេះមក ដោយមានឫសឈើដុះចាក់ស្រេះមកជាមួយតែម្តង។ លោក **សុម៉ាឡា** បន្តថា បំណែកក្បាលនាគនេះ មានត្រឹមតែកនាគមកក្បាលខាងលើ ដែលមានបណ្តោយ ១,២ម៉ែត្រ ទទឹង ១ម៉ែត្រ និងកម្រាស់ ០,៣ម៉ែត្រ បំណែកសត្វ



ចម្លាក់ក្បាលនាគដែលជាប់នៅក្រោមឬសឈើ

គ្រុឌជិះលើក្បាលនាគ ស្ថានភាពមុខនាគខាងមុខមានការខូចខាតច្រើនដោយអន្លើរ ដោយបាក់បែកមុខនាគ និងជុំវិញសងខាង ។រីឯសត្វគ្រុឌវិញ ត្រូវបានបាក់ច្រមុះ និងដៃផ្នែកនៅខាងលើ រួមទាំងផ្នែកខ្លះនៃក្បាល ។

លោក **ឈូក សុម៉ាឡា** សន្និដ្ឋានថា បំណែកក្បាលនាគនេះអាចយកចេញពីប្រាសាទបាយ័ន តែមិនដឹងថាយកមកទីតាំងនេះក្នុងគោលបំណងអ្វី និងពីពេលណានោះទេ។លោកបន្ថែមទៀតថា រូបចម្លាក់បែបនេះច្រើនឃើញនៅរចនាប័ទ្មបាយ័នក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ ទ្រង់បានយកនាគនិងគ្រុឌដែលជាសត្រូវនឹងគ្នាមកបញ្ចូលក្នុងសិល្បៈតែមួយដែលព្រះអង្គចង់បង្ហាញពីទស្សនៈបង្រួបបង្រួមសាសនារវាងព្រហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ទើបព្រះអង្គឱ្យស្ថាបត្យករបញ្ចូលនាគ និងគ្រុឌនៅជាមួយគ្នា ហើយដាក់បង្ហាញលើសំណង់នានារបស់ទ្រង់ ។ ដើម្បីរក្សាសុវត្ថិភាពនូវបំណែកក្បាលនាគនេះ ទើបអាជ្ញាធរជាតិអប្សរា សហការជាមួយនគរបាលការពារបេតិកភណ្ឌ ព្រមទាំងភ្នាក់ងារទេសចរណ៍ ធ្វើកំណត់ហេតុប្រគល់ទទួលបំណែកចម្លាក់ខាងលើយកទៅរក្សាទុកនៅសារមន្ទីរ ព្រះនរោត្តម







អ្នកជំនាញនិងសមត្ថកិច្ចចុះយកផ្ទាំងចម្លាក់ក្បាលនាគទៅរក្សាទុក្ខ

សីហនុ-អង្គរ ដើម្បីចុះបញ្ជីទុកជាឯកសារ ដោយបានលាងសម្អាតរក្សាទុកទៅតាមបច្ចេកទេស និងស្វែងរកទិន្នន័យផ្សេងទៀតផងទាក់ទងនឹងបំណែកក្បាលនាគនេះ ងាយស្រួលយកទៅដាក់នៅទីតាំងដើមវិញ បើមានការជួសជុលនៅទីតាំងដែលបានបាត់បង់នោះ ៕

# គិតចាប់ពីខែកញ្ញា ឆ្នាំ២០២១ ដល់ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ រថយន្តគ្មានពន្ធចំនួន ១៥ ៩៥០គ្រឿង ត្រូវបានម្ចាស់យកមកបង់ពន្ធ

*អត្ថបទ ៖ យូ សំបូរ , រូបថត៖ អ៊ុង ហុងលៀង*



ឯកឧត្តមបណ្ឌិត គុណ ញឹម អញ្ជើញបើកសន្និសីទសារព័ត៌មាន

«គិតចាប់ពីខែកញ្ញា ឆ្នាំ២០២១ រហូតដល់ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ មានរថយន្តគ្មានពន្ធចំនួន ១៥ ៩៥០គ្រឿងត្រូវបានម្ចាស់យកមកបង់ពន្ធ-អាករ និងកក់ប្រាក់ ដែលមានទឹកប្រាក់សរុបចំនួន៩៨.១៥លានដុល្លារអាមេរិក »។ ទន្ទឹមនេះក៏នៅមានរថយន្តចង្កូតស្តាំ ដែលម្ចាស់បានស្នើសុំចុះបញ្ជីរួច ប៉ុន្តែមិនទាន់បានមកបំពេញកាតព្វកិច្ចពន្ធនិងអាករចំនួន ៣ ៨៣៨គ្រឿង



ឯកឧត្តមបណ្ឌិត គុណ ញឹម



មន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធ និងអ្នកសារព័ត៌មានអញ្ជើញចូលរួម



ឯកឧត្តមបណ្ឌិត គុណ ញឹម មានប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន

ដែលម្ចាស់ត្រូវចូលមកបង់ពន្ធនិងអាករត្រឹមថ្ងៃទី៨ ខែតុលា ឆ្នាំ២០២២ ។ នេះជាសេចក្តីប្រកាសព័ត៌មានស្តីពីវឌ្ឍនភាព នៃការអនុវត្តការប្រមូលពន្ធ លើរថយន្តគ្មានពន្ធមានស្រាប់ ក្នុងប្រទេស នាព្រឹកថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៥ខែតុលា ឆ្នាំ២០២២អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) បានរៀបចំសន្និសីទសារព័ត៌មានស្តីពីវឌ្ឍនភាព នៃការអនុវត្តការប្រមូលពន្ធ លើរថយន្តគ្មានពន្ធមានស្រាប់ក្នុងប្រទេសលើកទី៧ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូ អមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីគយនិងរដ្ឋាករ ពាក់ព័ន្ធនិងអ្នកសារព័ត៌មានចំនួន ២៨រូប មកពីអង្គភាពសារព័ត៌មាន ១២ អង្គភាព ។

សន្និសីទសារព័ត៌មាននេះ មានគោលបំណង ដើម្បីជូនដំណឹងដល់សាធារណជន អំពីវឌ្ឍនភាព នៃការអនុវត្តការប្រមូលពន្ធ និងអាករនាំចូលលើរថយន្តគ្មានពន្ធ មានស្រាប់ក្នុងប្រទេស ស្របតាមខ្លឹមសារសេចក្តីជូនដំណឹង លេខ៤៨២ សជណ. ហធ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងការសម្រេចដ៏ខ្ពង់ខ្ពស់ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រ



មន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធ និងអ្នកសារព័ត៌មានអញ្ជើញចូលរួម



ឯកឧត្តមបណ្ឌិត គុណ ញឹម មានប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន

កម្ពុជា ថ្លែងក្នុងពិធីសំណេះសំណាលជាមួយគណៈប្រតិភូកីឡាអាស៊ានប៉ារ៉ាហ្គេម (ASEAN Para Games) នាព្រឹកថ្ងៃទី៦ ខែកកដា ឆ្នាំ២០២២ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលអនុញ្ញាតជាគោលការណ៍ឱ្យម្ចាស់រថយន្តចង្កូតស្តាំដែលនៅសេសសល់ចូលមកបំពេញកាតព្វកិច្ចពន្ធ និងអាករដោយមិនតម្រូវឱ្យកែចង្កូត។ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានគូសបញ្ជាក់ថា ក្នុងរយៈពេល៩ខែ ឆ្នាំ២០២២ អគ្គនាយកដ្ឋានគយបានបង្ក្រាបរថយន្តគេចពន្ធបានចំនួន ៥១០គ្រឿង ក្នុងនោះរថយន្តចង្កូតឆ្វេងចំនួន ៤៨២គ្រឿង និងរថយន្តចង្កូតស្តាំចំនួន២៨គ្រឿង។ ការបង្ក្រាបរថយន្តល្មើសច្បាប់នេះ គឺគយធ្វើសកម្មភាពដូចភ្លៀងរលឹម ដោយមិនអាចបន្ធូរបន្ថយដៃបានទេ ពិសេសនោះការបង្ក្រាបរថយន្តចង្កូតស្តាំ ដែលមានព្រំដែនវែងអន្លាយ និងអាចនាំឱ្យជនខិតខូចលួចនាំយករថយន្តទាំងនោះចូលមកក្នុងប្រទេសកម្ពុជាបាន។ តាមព្រំដែនក្រុមការងារគយបានបន្តដាក់កម្លាំងបន្ថែម ហើយក៏មានបណ្តាញផងដែរ ដើម្បីចាប់ជនល្មើសដែលលួចនាំរថយន្ត ចង្កូតស្តាំមកលក់នៅក្នុងប្រទេសកម្ពុជា។ ក្នុងរយៈពេល៩ខែកន្លងមកនេះ គឺគ្មានការលួចនាំយករថយន្តចង្កូតស្តាំមកទេ ខណៈដែលការចាប់បានតែពីរ ឬបីគ្រឿងប៉ុណ្ណោះ ដោយសារម្ចាស់មិនទៅចុះបញ្ជី ដើម្បីបានក្រដាសមួយសន្លឹកដាក់ជាប់រថយន្ត បង្ហាញមន្ត្រីគយ យកទៅបង់ពន្ធនៅពេលក្រោយ។ សម្រាប់យុទ្ធនាការរយៈពេល៩០ថ្ងៃ ជាលទ្ធផលគឺតត្រឹមថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ រថយន្តចង្កូតស្តាំគ្រប់ប្រភេទត្រូវបានម្ចាស់មកបង់ពន្ធអាករ និងចុះបញ្ជីសរុបចំនួន ៩ ៨១៤គ្រឿង និងទទួលបានថវិកា ២០លានដុល្លារ។ សម្រាប់រថយន្តចង្កូតស្តាំគ្រប់ប្រភេទម្ចាស់បានមកបង់ពន្ធអាករនិងចុះបញ្ជីសរុបចំនួន ៩ ៨១៤គ្រឿង ក្នុងនោះជាង៩០ភាគរយនៃរថយន្តចង្កូតស្តាំដែលម្ចាស់យកមកបង់ពន្ធនិងចុះបញ្ជី គឺជាប្រភេទរថយន្តដឹក និងប្រភេទរថយន្តបែន ដូចជារថយន្តដឹកដីដឹកខ្សាច់ និងដឹកថ្មជាដើម ។រថយន្តប្រភេទទាំងអស់នេះ គឺជារថយន្តប្រភេទដឹកដែលមានអត្រាពន្ធទាប ជាប្រភេទរថយន្តចាស់ៗ ដែលគិតជាទឹកប្រាក់ប្រមាណជិត២០លានដុល្លារ។ ឯកឧត្តមបណ្ឌិតបានបន្តថា ចំណូលទាំងនេះក៏ជាផ្នែកមួយចូលរួមនៅក្នុងផែនការ នៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលផងដែរ។ពាក់ព័ន្ធនឹងលទ្ធផលក៏ដូចជាវឌ្ឍនភាពដំណើរការប្រមូលពន្ធលើរថយន្តគ្មានពន្ធមានស្រាប់ក្នុងប្រទេស និងការងារប្រមូលពន្ធនិងអាករមួយចំនួនទៀត ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូបានលើកឡើងអំពីស្ថានភាពរដូវកាល និងបញ្ហាហិរញ្ញវត្ថុ ដែលអាចជាកត្តាប្រឈមរារាំងម្ចាស់រថយន្តដែលនៅសល់ចំនួន ៣ ៨៣៨គ្រឿង ទៀត ភាគច្រើនលើសលប់ជាប្រភេទរថយន្តដឹកចាស់ៗ មិនអាចមកបំពេញកាតព្វកិច្ចពន្ធនិងអាករឱ្យបាន ទាន់ពេលវេលាកំណត់ខាងលើ។ ដើម្បីសម្រួលដល់ការលំបាករបស់ម្ចាស់រថយន្តចង្កូតស្តាំចុះបញ្ជីរួចនៅសេសសល់ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នឹងលើកសំណើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបន្តគោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពីសម្តេចតេជោ នាយករដ្ឋមន្ត្រីអំពីលទ្ធភាពនៃការពន្យារពេលបន្ថែមទៀតជូនម្ចាស់រថយន្តដែលបានចុះបញ្ជីរួចទាំង ៣ ៨៣៨គ្រឿង អាចមកបំពេញកាតព្វកិច្ចពន្ធនិងអាករឱ្យបានគ្រប់ៗគ្នា៕

# គណៈប្រតិភូជាតិ និងអន្តរជាតិ អញ្ជើញទស្សនាប្រាសាទកោះកេរ និងរូបតំណាងព្រះស្កន្ទកុមារ

*អត្ថបទៈ ឡាយ សារ៉ុម , រូបថតៈ មន្ទីរព័ត៌មានខេត្តព្រះវិហារ*




*គណៈប្រតិភូអាស៊ាន-អឺរ៉ុប និងអ្នកជំនាញអង្គការក្រៅរដ្ឋាភិបាលមកទស្សនកិច្ចតំបន់ប្រាសាទកោះកេរ*

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានរៀបចំកម្មវិធីដំណើរទស្សនកិច្ចជូនគណៈប្រតិភូអាស៊ានប្រមាណជាង១00នាក់ដៃគូសន្ទនាតំណាងអន្តររដ្ឋាភិបាលមកពី អាមេរិក នីហ្សេរីយ៉ា អឺរ៉ុប និងអ្នកជំនាញមកពីអង្គការក្រៅរដ្ឋាភិបាល អង្គការយូណេស្កូភ្នំពេញ UNIDROIT,WCO,Antiquity Coalition,Blue Shield,Heritage of Peace និង ALPH ដែលបានអញ្ជើញមកចូលរួមកម្មវិធី សន្និសីទអន្តរជាតិស្តីពីការការពារ និងទប់ស្កាត់ការជួញដូរសម្បត្តិវប្បធម៌ខុសច្បាប់ ទៅទស្សនាអតីតរាជធានីបុរាណតំបន់ប្រាសាទកោះកេរ ក្នុងគោលបំណងឱ្យតំណាងអន្តររដ្ឋាភិបាល មន្ត្រីជំនាញ សិក្ខាកាម និងអ្នកចូលរួមទាំងអស់បានដឹងស្គាល់ពីប្រវត្តិសាស្ត្រដ៏យូរលង់ នៃប្រាង្គប្រាសាទខ្មែរ យល់ពីព្រលឹងនៃប្រាសាទ និងភាពអស្ចារ្យប្លែកគ្នានៃប្រាសាទនីមួយៗ ជាពិសេស គឺបានឃើញពីសម្បត្តិវប្បធម៌ ដែលបានទទួលរងការបំផ្លិចបំផ្លាញនាសម័យសង្គ្រាម និងវត្ថុបុរាណជាច្រើនទៀត ត្រូវបានលួចយកទៅលក់នៅទីផ្សារងងឹត។

«អតីតរាជធានីបុរីលិង្គ ឬឆោគគ្យ៉រ» ព្រះបាទ **ជ័យវរ្ម័ន**





*គណៈប្រតិភូអញ្ជើញទស្សនកិច្ចប្រាសាទកោះកេរ*



ព្រះស្កន្ទ គង់លើក្ងោក

ទី៤បានចាប់ផ្ដើមកសាងរាជធានីកោះកេរនាឆ្នាំ៩២១នៃគ្រឹស្ដសករាជ ហើយបានគ្រងរាជ្យជាផ្លូវការពីឆ្នាំ៩២៨ដល់ឆ្នាំ៩៤១ នៃគ្រឹស្ដសរាជ បន្ទាប់មកព្រះរាជបុត្រព្រះបាទ **ហរ្សវរ្ម័ន** ទី២ បានឡើងគ្រងរាជបន្តបានរយៈពេលខ្លីរហូតដល់ឆ្នាំ៩៤៤ នៃគ្រឹស្ដសករាជ។ ដែលរាជធានីរបស់ព្រះអង្គឈ្មោះ «លិង្គបុរ (បុរីលិង្គ) ជាភាសាសំស្រ្កឹត និងឆោគគ៌្យរ ជាភាសាខ្មែរ» ដែលឈ្មោះបច្ចុប្បន្នគឺប្រាសាទកោះកេរ។ កាលពីពេលកន្លងទៅថ្មីៗនេះតាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយសហរដ្ឋអាមេរិក កម្ពុជាទទួលបានរូបបដិមាដ៏មានតម្លៃគឺព្រះគណេស (Ganesha) និង **ព្រះស្កន្ទ** គង់លើក្ងោក (Skanda on a peacock) ដែលចម្លាក់ទាំងពីរនេះ មាននៅប្រាសាទកោះកេរ ជារាជធានីនៃ



ការធ្វើបទបង្ហាញអំពីប្រាសាទកោះកេរ





គណៈប្រតិភូអាស៊ាន-អឺរ៉ុប និងអ្នកជំនាញអង្គការក្រៅរដ្ឋាភិបាលមកទស្សនកិច្ចតំបន់ប្រាសាទកោះកេរ



តំបន់ប្រាសាទកោះកេរ នៅខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា

អាណាចក្រខ្មែរបុរាណពីឆ្នាំ៩២៨ដល់ ៩៤៤នៃគ្រឹស្តសករាជ បានបាត់បង់ដោយការលួចជីកគាស់កកាយ និងនាំចេញទៅជួញដូរ ដោយខុសច្បាប់ជាមួយសម្បត្តិវប្បធម៌ជាច្រើនផ្សេងទៀត ក្នុងអំឡុងពេលសម័យសង្គ្រាម។

មន្ត្រីក្រសួងវប្បធម៌បានលើកឡើងថា តាមរយៈសន្និសីទនេះ គឺជាឧទាហរណ៍មួយ នៃកិច្ចសហប្រតិបត្តិការពហុភាគីសម្រាប់ការអំពាវនាវរួមគ្នា ដើម្បីសកម្មភាពប្រយុទ្ធប្រឆាំងនឹងការជួញដូរខុសច្បាប់ និងការពារសម្បត្តិវប្បធម៌ដែលជាមរតកសម្រាប់មនុស្សជំនាន់ក្រោយ។ យើងត្រូវពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីផលប៉ះពាល់នៃការចរាចរ និងការជួញដូរខុសច្បាប់ ដើម្បីអាចធានាថា ប្រជាពលរដ្ឋនៃប្រទេសនីមួយៗ បានដឹងច្បាស់ពីសារសំខាន់នៃបេតិកភណ្ឌសម្រាប់សង្គមរបស់ខ្លួន និងការទទួលខុសត្រូវរបស់ពួកគេក្នុងកិច្ចការពារសម្បត្តិវប្បធម៌។ យើងសង្ឃឹមនិងជឿជាក់ថា ប្រជាជាតិអាស៊ីអាគ្នេយ៍ អឺរ៉ុប ដៃគូសន្ទនា មន្ត្រីជំនាញ និងអង្គការអន្តររដ្ឋាភិបាលនឹងមិនព្រងើយកន្តើយរួមសហការគ្នាក្នុងការបង្កើតយន្តការរួមទប់ស្កាត់ការចរាចរជួញដូរសម្បត្តិវប្បធម៌ខុសច្បាប់ និងចាត់វិធានការផ្លូវច្បាប់ទាមទារឬស្នើសុំមកវិញឱ្យបាននូវសម្បត្តិវប្បធម៌នានាទៅកាន់ប្រទេសដើមវិញដោយសន្តិវិធី៕



រូបថតអនុស្សាវរីយ៍ គណៈប្រតិភូអាស៊ាន-អឺរ៉ុប និងអ្នកជំនាញអង្គការក្រៅរដ្ឋាភិបាលនៅប្រាសាទកោះកេរ

**គណបក្សប្រជាជនកម្ពុជា**

គណៈកម្មាធិការគណបក្សមូលដ្ឋាន
អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

**ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ**
**អព្យាក្រឹត និង វឌ្ឍនភាពសង្គម**

# សារលិខិតអបអរសាទរ

## សូមគោរពជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !

តាងនាមថ្នាក់ដឹកនាំ សមាជិក សមាជិកា គណៈកម្មាធិការគណបក្សមូលដ្ឋានអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃគណៈកម្មាធិការគណបក្សក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខ្ញុំសូមអនុញ្ញាតគោរពសម្តែងនូវអំណរសាទរយ៉ាងស្មោះអស់ពីដួងចិត្តចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសដែលតុលាការប្រទេសបារាំង សភាទី ១៧ នៃតុលាការយុត្តិធម៌ទីក្រុងប៉ារីស បានបញ្ជាក់ក្នុងសំអាងហេតុនៃសាលក្រម នាថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០២២ ផ្តល់យុត្តិធម៌ និងភាពស្អាតស្អំជូន **សម្តេចតេជោ** និងរកឃើញការពិតថា សម រង្ស៊ី បានប្រព្រឹត្តអំពើបរិហារកេរ្តិ៍ ចំពោះ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

សាលក្រមរបស់តុលាការបារាំងនេះ បានបង្ហាញនូវភាពជោគជ័យរបស់ **សម្តេចតេជោ** ដែលទទួលបានការសម្រេចមួយសមស្របតាមបំណងប្រាថ្នារបស់ **សម្តេចតេជោ** ដែលចង់បាននូវយុត្តិធម៌ និងភាពស្អាតស្អំ និងទាត់ចោលការថ្លែងមួលបង្កាច់របស់ជនជាប់ចោទ សម រង្ស៊ី ។ ចំពោះបុគ្គល សម រង្ស៊ី វិញ ត្រូវរងភាពបរាជ័យយ៉ាងធ្ងន់ធ្ងរ ដោយតុលាការបានបញ្ជាក់ថា ពាក្យពេចន៍របស់ខ្លួន គឺជាការចោទប្រកាន់ដោយគ្មានភ័ស្តុតាង និងជាការបរិហារកេរ្តិ៍ ហើយត្រូវបង់ខាតចំពោះរាល់ការចំណាយទាំងអស់ ។

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងសមាជិក សមាជិកា នៃគណៈកម្មាធិការគណបក្សមូលដ្ឋានអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃគណៈកម្មាធិការគណបក្សក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមលើកហត្ថប្រណម្យ ឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក បុណ្យបារមីគ្រប់ទិសទី ព្រមទាំងទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា សូមតាមជួយការពារ ថែរក្សា និងប្រោះព្រំនូវសព្វសាធុការពរជ័យជូន **សម្តេចតេជោ** និង **សម្តេច កិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** របស់ **សម្តេច**ទាំងទ្វេ សូមមានសុខភាពល្អបរិបូណ៌ កម្លាំងកាយចិត្តមាំមួន ជន្មាយុយឺនយូរ សុភមង្គល វិបុលសុខ សិរីសួស្តី ជ័យមង្គលគ្រប់ប្រការ និងបានប្រកបនូវពុទ្ធពរទាំងបួន ប្រការ គឺ**អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

ថ្ងៃពុធ ២រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២២

**គណៈកម្មាធិការគណបក្សមូលដ្ឋាន**
**អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម**
**ប្រធាន**

**ឆាយ ឫទ្ធិសែន**

## បញ្ជីរាយនាមសប្បុរសជន ចូលរួមបច្ច័យកាន់បិណ្ឌទី ១១
## ពិធីបុណ្យភ្ជុំបិណ្ឌ នៅវត្តមង្គលវ័ន ហៅស្វាយដង្គំ
## ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០២២

| ល.រ | នាម និងគោត្តនាម | | ថវិកា | | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | រៀល | ដុល្លារ | |
| ១ | ឯកឧត្តម | ខៀវ កាញារីទ្ធ និង លោកជំទាវ ទេព ខៀវ | 8,190,000៛ | $ 640 | |
| ២ | | ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងព័ត៌មាន | 6,000,000៛ | | |
| ៣ | លោកជំទាវ | ម៉ែន សៀង សុខ ចំរើន | | $ 250 | |
| ៤ | ឯកឧត្តម | ឈុំ សុជាតិ និងលោកជំទាវ | | $ 100 | |
| ៥ | ឯកឧត្តម | ទន់ សារ៉ាត និងលោកជំទាវ | | $ 100 | |
| ៦ | | អធិការដ្ឋាន | 250,000៛ | | |
| ៧ | លោកជំទាវ | ទី ម៉ារ៉ា អ៊ុក ប្រាថ្នា | 200,000៛ | | |
| ៨ | លោកជំទាវ | សរ គីមលី | 200,000៛ | | |
| ៩ | លោកជំទាវ | លឹម មុំ | 200,000៛ | | |
| ១០ | លោកជំទាវ | ឈឹមពៅ សុភាន់ឌី | 200,000៛ | | |
| ១១ | លោកជំទាវ | នីន សុខា | 120,000៛ | | |
| ១២ | លោកជំទាវ | ម៉ៀច កន្និកា | 100,000៛ | | |
| ១៣ | លោកជំទាវ | ឡុងឌី សាន់ណារ៉ា | 100,000៛ | | |
| ១៤ | លោកជំទាវ | ជៀម ស៊ីណាន់ | 100,000៛ | | |
| ១៥ | លោកជំទាវ | សេង មួយគាង | 100,000៛ | | |
| ១៦ | ឯកឧត្តម | តន់ យ៉ាន និងលោកជំទាវ | 100,000៛ | | |
| ១៧ | លោកជំទាវ | អ៊ុក មករា | 100,000៛ | | |
| ១៨ | លោកជំទាវ | ហ៊ីង រ៉េត | 100,000៛ | | |
| ១៩ | លោកជំទាវ | ជា ស៊ុនដាណែត | 100,000៛ | | |
| ២០ | លោកស្រី | ស៊ុំ សារិទ្ធិ | 100,000៛ | | |
| ២១ | លោកជំទាវ | ប្រាក់ អេលីរតនា | 50,000៛ | | |
| សរុប | | | 16,310,000៛ | $ 1,090 | |

# ពិធីបុណ្យសពព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ទន់ ធី មាតាក្មេក ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ AKP-គណៈរដ្ឋមន្ត្រី*



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី និងលោកជំទាវ ទន់ ខុន យឹម ឆៃលី ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី មានទុក្ខជាទម្ងន់ដោយលោកយាយព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ទន់ ធី បានទទួលមរណភាពកាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ដោយជរាពាធដែលសពត្រូវបានតម្កល់និងប្រារព្ធពិធីបុណ្យតាមប្រពៃណីនៅគេហដ្ឋានភូមិពន្លៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ





ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ទន់ ធី** ត្រូវជាមាតាក្មេក ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សា ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ  បានទទួលមរណភាពនៅវេលាម៉ោង ០០:១៨នាទីយប់រំលងអាធ្រាត្រ ឈានចូលថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ក្នុងជន្មាយុ ៩០ឆ្នាំ ដោយជរាពាធ ហើយសពត្រូវបានក្រុមគ្រួសារតម្កល់ និងប្រារព្ធពិធី និងធ្វើបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនា នាគេហដ្ឋានស្ថិតនៅភូមិពន្លៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ។






លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន អញ្ជើញដឹកនាំប្រតិភូក្រសួងចូលរួមគោរពវិញ្ញាណក្ខន្ធ ព្រឹទ្ធមហាសិកាពុទ្ធសាសនូបត្ថម្ភក៍ ទន់ ធី

ក្នុងពិធីតម្កល់សព ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ទន់ ធី** នេះដែរ មានប្រតិភូគ្រប់លំដាប់ថ្នាក់ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួងស្ថាប័នរាជធានី ខេត្តជាច្រើន បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធជាបន្តបន្ទាប់ ដោយបានសម្តែងនូវសមានទុក្ខដ៏ក្រៀមក្រំ អាឡោះអាល័យ និងក្តីរន្ធត់ឥតឧបមា ចំពោះការបាត់បង់ ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ទន់ ធី** ដែលជាមាតា និងជាជីដូន ប្រកបដោយព្រហ្មវិហារធម៌ និងចរិយាធម៌ដ៏ពិសិដ្ឋ របស់កូនចៅ និងញាតិសន្តាន។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សា ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានគណៈកម្មាធិការជាតិ ជំរុញចលនាភូមិមួយផលិតផលមួយ និងលោកជំទាវ **ទន់ ខុន យឹម ឆៃលី** បានថ្លែងអំណរគុណក្នុងនាមក្រុមគ្រួសារ ខ្ញុំបាទ និងភរិយាសូមថ្លែងអំណរអរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ សម្តេច ឯកឧត្តម




ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា និងលោកជំទាវ អញ្ជើញដឹកនាំប្រតិភូក្រសួងចូលរួមគោរពវិញ្ញាណក្ខន្ធ ព្រឹទ្ធមហាសិកាពុទ្ធសាសនូបត្ថម្ភក៍ ទន់ ធី




ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងលោកជំទាវ អញ្ជើញដឹកនាំប្រតិភូក្រសួងចូលរួមគោរពវិញ្ញាណក្ខន្ធ ព្រឹទ្ធមហាសិកាពុទ្ធសាសនូបត្ថម្ភក៍ ទន់ ធី




ឯកឧត្តម លូ គឹមឈន់ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយក កំពង់ផែស្វយ័តក្រុងព្រះសីហនុ អញ្ជើញដឹកនាំប្រតិភូកំពង់ផែចូលរួមគោរពវិញ្ញាណក្ខន្ធព្រឹទ្ធមហាសិកាពុទ្ធសាសនូបត្ថម្ភក៍ ទន់ ធី

លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន រាជធានី ខេត្ត ភ្ញៀវកិត្តិយស ព្រមទាំងញាតិមិត្តជិតឆ្ងាយទាំងអស់ ដែលមានសមានចិត្ត និងមនោសញ្ចេតនាដ៏ជ្រាលជ្រៅ អញ្ជើញចូលរួមដោយផ្ទាល់ និងឬបានចាត់ប្រតិភូចូលរួមដោយផ្ទាល់ក្នុងបុណ្យសពព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ទន់ ធី** ត្រូវជា មាតា ម្ដាយក្មេក យាយ យាយទួត ជាអ្នកមានគុណរបស់យើងខ្ញុំទាំងអស់គ្នា និងបានផ្ញើសាររំលែកទុក្ខដ៏ក្រៀមក្រំ និងការសោកស្ដាយជាពន់ពេកជាមួយក្រុមគ្រួសារយើងខ្ញុំ។ ខ្ញុំបាទ និងភរិយា ព្រមទាំងក្រុមគ្រួសារ សូមលំឱនកាយសម្ដែងនៅកតញ្ញូតាធម៌ និងការដឹងគុណដ៏ជ្រៀលជ្រៅ ចំពោះកាយវិកាដ៏ប្រពៃនេះ សបញ្ជាក់ឱ្យឃើញច្បាស់នៅទឹកចិត្តស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម ចំពោះ ក្រុមគ្រួសារយើងខ្ញុំដែលធ្វើឱ្យយើងខ្ញុំទាំងអស់គ្នា មិនអាចបំភ្លេច បាននៅសមានចិត្តដ៏ប្រពៃថ្លៃថ្លានេះបានឡើយ និងសូមថ្វាយព្រះពរ និងជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន រាជធានី ខេត្ត ភ្ញៀវកិត្តិយស ព្រមទាំងញាតិមិត្តជិតឆ្ងាយ ទាំងអស់ សូមបាន ប្រកបនូវពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# ONLINE

IN TOUCH WITH YOUR WORLD

## អ្នកផ្តល់សេវាអ៊ីនធឺណិតឈានមុខគេនៅកម្ពុជា

## THE LEADING INTERNET SERVICE PROVIDER IN CAMBODIA




### BROADBAND INTERNET

ONLINE provides many packages of internet service suitable to the actual needs of the public sectors and private sectors,such as Ministries, NGOs, Banks, MFI Factories, Hotels, Casinos, etc.

### CONNECTIVITY

ONLINE provides a flexibility to transport and route several types of network traffic using latest technology and highly efficient transmit applications such as voice, data and video, etc.

### HOSTING / COLOCATION SERVICES

ONLINE provides a flexibility hosting services to customers by adapting to user's requirements which user can host their crucial date and high security. Our colocation service is fully completed and facilitated.



COGETEL Ltd.

023 / 081 72 72 72 | sales@online.com.kh | www.online.com.kh | /onlineisp